សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

Cambodian Journalists Alliance Association


# របាយការណ៍ស្ដីពី
# ស្ថានភាពសារព័ត៌មានឆ្នាំ២០២២ នៅកម្ពុជា

## កំណត់ត្រាប្រចាំឆ្នាំស្ដីពីករណីយាយីប្រឆាំងអ្នកសាព័ត៌មាន



# មាតិកា


**សេចក្តីសង្ខេប** ៣

**I. សេចក្តីផ្តើម** ៥

**II. វិធីសាស្ត្រ** ៦

១. វិធីសាស្ត្រ និងការប្រមូលទិន្នន័យ ៧

២. វិសាលភាព និងដែនកំណត់ ៨

**III. ការរកឃើញសំខាន់ៗ** ៩

១. និន្នាការនៃការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅមួយឆ្នាំ ៩

២. ទីតាំងកើតឡើងនៃករណីយាយី ៩

៣. ប្រភេទនៃការយាយី ១១

៣.១. វិធានការតាមផ្លូវច្បាប់

៣.២. ការដកអាជ្ញាប័ណ្ណ

៣.៣. អំពើហិង្សា

៣.៤. ការបំភិតបំភ័យ

៣.៥. ការរើសអើង

៣.៦. ការឃាត់ខ្លួនដើម្បីសាកសួរ

៣.៥. ការដាក់ពន្ធនាគារ

៤. ប្រភេទនៃបណ្តាញសារព័ត៌មាន ៤២

៥. ស្ថានភាពអ្នកសារព័ត៌មានក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ ៤៣

៦. ច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងសេរីភាពសារព័ត៌មាន

៦.១. សេចក្តីព្រាងច្បាប់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតរបស់ក្រសួងទូរគមនាគមន៍

៦.២. ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតរបស់កម្ពុជានៅតែស្ថិតក្រោមការត្រួតពិនិត្យ

៦.៣. ច្បាប់ស្តីពីសិទ្ធទទួលបានព័ត៌មាន នៅតែបន្តរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី

៦.៤. រដ្ឋាភិបាលថា អ្នកសារព័ត៌មានគួរជូនដំណឹងដល់អាជ្ញាធរសម្រាប់ការរាយការណ៍ព័ត៌មានតាមខេត្តជាញឹកញាប់

**IV. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៤៨

**V. ឧបសម្ព័ន្ធ** ៥២

# សេចក្តីសង្ខេប

*របាយការណ៍ឃ្លាំមើលឆ្នាំ២០២២ របស់សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) ស្តីពី ការយាយីមកលើ អ្នកសារព័ត៌មាន បានបង្ហាញនូវក្តីព្រួយបារម្ភយ៉ាងខ្លាំងជាថ្មីម្តងទៀត។ ទោះបីជាករណីយាយីមានការធ្លាក់ចុះបើប្រៀបធៀបនឹងឆ្នាំមុនក៏ដោយ ក៏សុទិដ្ឋិនិយមទៅលើសេរីភាពសារព័ត៌មាន ត្រូវបាត់បង់ទៅវិញ ដោយសារតែការបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដ៏លេចធ្លោមួយនៅប្រទេសកម្ពុជានៅដើមឆ្នាំ២០២៣នេះ។*

*យើងជំរុញឱ្យរដ្ឋាភិបាលលុបចោលការសម្រេចចិត្តរបស់ខ្លួនក្នុងការបិទវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ហើយយើងជឿថាការបិទវិទ្យុនេះជាសញ្ញាគួរឱ្យព្រួយបារម្ភ ខណៈដែលគណបក្សកាន់អំណាចនឹងស្វែងរកការគ្រប់គ្រងព័ត៌មានទាក់ទងនឹងការបោះឆ្នោតជាតិនាពេលខាងមុខ និងលើសពីនេះទៅទៀត។*

*អ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាបន្តធ្វើការ ទោះបីមានការភ័យខ្លាចពីភាពអត់ការដាក់ទោសចំពោះការធ្វើអំពើហិង្សាលើរាងកាយ និងការចាប់ដាក់ពន្ធនាគារក៏ដោយ។ ហើយក្នុងចំណោមនោះ ក៏មានអ្នកសារព័ត៌មានជាច្រើនជាសមាជិករបស់យើងផងដែរ។*

*ខេមបូចាបានកត់ត្រាករណីយាយីប្រឆាំងអ្នកសារព័ត៌មានចំនួន ៣៥ ដែលរួមមានហិង្សាមកលើរាងកាយ ការគំរាមកំហែងប្រើអំពើហិង្សា ការរើសអើង ការឃាត់ខ្លួន ការដាក់ពន្ធនាគារ និងសកម្មភាពតាមផ្លូវច្បាប់ផ្សេងទៀត ប្រឆាំងនឹងអ្នកសារព័ត៌មានចំនួន៥៥នាក់ក្នុងឆ្នាំ ២០២២ ដោយផ្អែកលើប្រភពផ្សាយព័ត៌មាន ការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ឯកសារតុលាការ និងការសម្ភាស។ យ៉ាងហោចណាស់មានអ្នកសារព័ត៌មានចំនួន២៧ នាក់ ទទួលរងការវាយប្រហារ ការបំភិតបំភ័យ ឬគំរាមកំហែងដោយការប្រើហិង្សាពេលពួកគេចុះយកព័ត៌មាន (អ្នកសារព័ត៌មាន៤នាក់ទទួលរងការវាយដំលើរាងកាយ ចំណែកឯ២៣ នាក់ផ្សេងទៀតរងការគំរាមកំហែងដោយការប្រើអំពើហិង្សា ឬការបំភិតបំភ័យ)។*

*ចំនួនករណីនៃការយាយីមកលើអ្នកសារព័ត៌មានរបស់ដែលកត់ត្រាដោយខេមបូចាមានការថយចុះ ២៨% បើធៀបនឹងឆ្នាំ២០២១ ដែលមាន៤៩ករណី ទៅលើអ្នកសារព័ត៌មានចំនួន៩៦ នាក់។*

*ទោះបីមានភាគីពាក់ព័ន្ធខ្លះ អាចមើលឃើញថារបាយការណ៍ឆ្នាំនេះ(២០២២) ជាសញ្ញានៃវឌ្ឍនភាពក៏ដោយ ក៏យើងត្រូវប្រយ័ត្នប្រយែងចំពោះការទាញយកសេចក្តីសន្និដ្ឋានណាមួយដែរ។*

*និទណ្ឌភាពចំពោះអ្នកអ្នកគំរាមកំហែង ឬវាយប្រហារលើអ្នកសារព័ត៌មាននៅតែបន្តកើតមាន ហើយគិតត្រឹមខែធ្នូ ឆ្នាំ២០២២ មានអ្នកសារព័ត៌មានចំនួន៧នាក់តកំពុងត្រូវបានជាប់ពន្ធនាគារ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ។*

ខេមបូចា មិនអាចកត់ត្រាសូម្បីតែមួយករណីដែលថា តុលាការផ្តន្ទាទោសមន្ត្រីនិងបុគ្គលផ្សេងទៀត ដែលបានយាយីមកលើអ្នកសារព័ត៌មាននៅឡើយទេ។ លើសពីនេះទៀត អាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន៤ត្រូវលុបចោលវិញ ដោយសារតែមានការចោទប្រកាន់ថាបានផ្សាយព័ត៌មានដែលបំពានលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម។

កាលពីចុងខែធ្នូ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជំរុញឲ្យមានការប្រយ័ត្នប្រយែងចំពោះការចាប់ខ្លួនអ្នកសារព័ត៌មានរបស់ទូរទស្សន៍បាយ័នដែលគាំទ្ររដ្ឋាភិបាលដោយលោកបញ្ជាក់ថាករណីដែលគួរតែដោះស្រាយតាមនិតិវិធីរដ្ឋប្បវេណី បែរទៅជារឿងព្រហ្មទណ្ឌទៅវិញ ដែលពុំមានកស្តុតាងគ្រប់គ្រាន់ទាល់តែសោះ។

ទោះជាបីយ៉ាងនេះក្តី សារបែបនោះកម្រកើតមានណាស់ សម្រាប់អ្នកសារព័ត៌មានឯករាជ្យខណៈអ្នកសារព័ត៌មានឯករាជ្យដែលប្រឈមនឹងការកាត់ទោស មិនដែលទទួលបានការការពារបែបនេះឡើយ។
ការស្រាវជ្រាវរបស់ខេមបូចា បង្ហាញថា អ្នកសារព័ត៌មានទាំងអស់ដែលត្រូវបានចាប់ខ្លួនក្នុងឆ្នាំ ២០២២ ត្រូវតុលាការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ញុះញង់ឱ្យប្រជាពលរដ្ឋតវ៉ា និងញុះញង់ឱ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈជាដើម

ការចោទពីបទព្រហ្មទណ្ឌទាំងនេះ ជារឿយៗជាឧបករណ៍នៃការបំភិតបំភ័យ។ សម្រាប់អ្នកសារព័ត៌មានទោះបីពួកគេបំពានច្បាប់ក៏គួរត្រូវបានដោះស្រាយផ្អែកតាមច្បាប់ស្តីពីរបបសារព័ត៌មានដែរប៉ុន្តែគេកម្រឃើញការប្រើច្បាប់ស្តីពីរបបសារព័ត៌មានក្នុងករណីបែបនេះណាស់។

ការចាប់ដាក់ពន្ធនាគារ ការឃុំខ្លួន និងការគំរាមកំហែងលើរាងកាយប្រឆាំងនឹងអ្នកសារព័ត៌មាននៅតែបន្តធ្វើឲ្យប៉ះពាល់ដល់តួនាទី របស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គមប្រជាធិបតេយ្យនិងធ្វើឱ្យមានការភ័យខ្លាចសម្រាប់អ្នករាយការណ៍ព័ត៌មានផ្សេងៗ ឬករណីពាក់ព័ន្ធនឹងមន្ត្រីមានអំណាច។

មិនគួរមានអ្នកសារព័ត៌មានណាម្នាក់ត្រូវជាប់ពន្ធនាគាររាប់ខែ ដោយសារតែរាយការណ៍ព័ត៌មាននោះទេ។ ហើយសមាជិកជាអ្នកសារព័ត៌មានរបស់យើងមិនគួរលះបង់ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ ដោយគ្រាន់តែដើម្បីធ្វើឲ្យប្រជាជនកម្ពុជាបានដឹងអំពីព័ត៌មានប្រទេសរបស់ពួកគេនោះឡើយ។

# I. សេចក្តីផ្តើម

ទោះបីមានការកើនឡើងនៃចំនួនប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា ជាពិសេសប្រព័ន្ធផ្សព្វផ្សាយអនឡាញ និងសមាគមសារព័ត៌មានក្តី ក៏សេរីភាពសារព័ត៌មាននៅតែជាបញ្ហាប្រឈម។

យោងតាមរបាយការណ៍របស់ក្រសួងព័ត៌មាន[1] គិតត្រឹមដំណាច់ឆ្នាំ ២០២២ មានប្រព័ន្ធផ្សព្វផ្សាយសរុបចំនួន ២១៧១ ដែលបានចុះបញ្ជី ក្នុងនោះមានស្ថានីយទូរទស្សន៍ចំនួន ២៧ ស្ថានីយទូរទស្សន៍ខ្សែកាប ចំនួន២១២ ស្ថានីយវិទ្យុ FM ចំនួន២២០ ស្ថានីយវិទ្យុជាតិចំនួន ១ តាមរយៈប្រេកង់ AM កាសែតចំនួន ៤៦៦ ទស្សនាវដ្តី ១៩៣ គេហទំព័រ ៨៧៨ ទីភ្នាក់ងារព័ត៌មានបរទេសចំនួន ២៦ ដែលមានការិយាល័យក្នុងស្រុក និងសមាគមប្រព័ន្ធផ្សព្វផ្សាយចំនួន៥១ ។

ខណៈដែលតួលេខទាំងនេះជារឿយៗត្រូវរដ្ឋាភិបាលលើកឡើងថាជាភស្តុតាងនៃសេរីភាពសារព័ត៌មាន ប៉ុន្តែតួលេខទាំងនេះលាក់បាំងនូវការបង្ក្រាបទៅលើសេរីភាពប្រព័ន្ធផ្សព្វផ្សាយចាប់តាំងពីឆ្នាំ២០១៧មកម្ល៉េះ។ការយាយីជាទ្រង់ទ្រាយតូចៗដែលកើតឡើងរាល់ថ្ងៃ និងករណីធំៗដូចជាការចាប់ខ្លួន ឬការចាប់ដាក់ពន្ធនាគារ បានធ្វើឱ្យស្ថាប័នសារព័ត៌មានជាច្រើន និងអ្នកសារព័ត៌មានខ្លួន បានដាក់កម្រិតលើកិច្ចការខ្លួនឯងឲ្យកាន់តែប្រុងប្រយ័ត។

ការរើសអើង ការបំភិតបំភ័យ ការចាប់ដាក់ពន្ធនាគារ ការចោទប្រកាន់ខុស ការយាយី និងការវាយប្រហារដោយប្រើហិង្សា កើតឡើងជាប្រចាំចំពោះអ្នកសារព័ត៌មាន។ ចំណាត់ថ្នាក់របស់កម្ពុជានៅលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកបានធ្លាក់ចុះពីលេខ១៣២ ក្នុងឆ្នាំ ២០១៧ មកនៅត្រឹម១៤២ ក្នុងចំណោម ១៨០ ប្រទេសក្នុងឆ្នាំ២០២២។

ម៉្យាងវិញទៀត ក្រមសីលធម៌ និងស្តង់ដារដែលអង្គភាពសារព័ត៌មានកម្ពុជាអនុវត្ត ជាពិសេសអ្នកសារព័ត៌មានតាមប្រព័ន្ធអនឡាញ នៅតែមិនស៊ីចង្វាក់គ្នា។ ការណ៍នេះធ្វើឲ្យមានការប្រព្រឹត្តខុសវិជ្ជាជីវៈ និងខុសក្រមសីលធម៌សារព័ត៌មាន ដែលជួនកាលឈានដល់ការប្តឹងផ្តល់តាមផ្លូវច្បាប់ និងការចោទប្រកាន់ថាបានប្រព្រឹត្តមិនសមរម្យ។ ទោះជាយ៉ាងនេះក្តី ការចោទតាមបទព្រហ្មទណ្ឌត្រូវបានអនុវត្តជាញឹកញាប់ ទោះបីវាជាបទល្មើដែលគួរតែត្រូវបានចោទតាមបទរដ្ឋប្បវេណីក៏ដោយ ។

របាយការណ៍នេះផ្តោតទៅលើករណីទាំងនោះ ដែលភស្តុតាងបានបញ្ជាក់ថា អ្នកសារព័ត៌មានរងការវាយប្រហារតាមផ្លូវកាយ ពាក្យសំដី តាមផ្លូវច្បាប់ រដ្ឋបាល ឬតាមមធ្យោបាយផ្សេងទៀត គឺដោយសារតែពួកគេប្រើសិទ្ធិ និងសេរីភាពស្របច្បាប់របស់ពួកគេ ក្រោមរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់អន្តរជាតិ។

[1] របាយការណ៍ក្រសួងព័ត៌មានផ្តល់ដោយលោកមាស សុភ័ណ្ឌតាមរយៈតេលេក្រាមកាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣



# II. វិធីសាស្ត្រ

# ១. វិធីសាស្រ្ត និងការប្រមូលទិន្នន័យ

របាយការណ៍នេះប្រើវិធីសាស្រ្តគុណវិស័យ។ ទិន្នន័យស្តីពីករណីយាយីលើអ្នកសារព័ត៌មានត្រូវបានចងក្រង ដោយប្រើករណីដែលបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងសេចក្តីប្រកាសជាសាធារណៈរបស់តុលាការ។

ករណីត្រូវបានពិនិត្យផ្ទៀងផ្ទាត់តាមរយៈការសម្ភាសតាមទូរស័ព្ទ ការអង្កេតនិងរបាយការណ៍ ការឃ្លាំមើលដំណើរការកាត់ក្តី និងការសម្ភាសជាមួយមេធាវី អ្នកសារព័ត៌មាន និងសមាជិកគ្រួសាររបស់ពួកគេ។ ក្នុងសំណុំរឿងពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ដែលរងការចោទប្រកាន់ពីបទប្រព្រឹត្តបទល្មើសនោះ ខេមបូចា ចាត់ទុករឿងទាំងនោះថាជាការយាយី ប្រសិនបើអ្នកសារព័ត៌មានម្នាក់ ឬច្រើននាក់ដែលពាក់ព័ន្ធ បដិសេធការចោទ ឬបទចោទប្រកាន់នោះ។ ក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ដែលបានរងការចោទពីការជំរិតទារប្រាក់នោះ ខេមបូចា មិនបានចាត់ទុករឿងទាំងនោះជាការយាយីនោះទេ ដោយសារតែសមត្ថភាពមានកម្រិតរបស់យើង ក្នុងការស៊ើបអង្កេតរកការពិតនេះ។

## ពាក្យគន្លឹះមួយចំនួនដែលប្រើក្នុងរបាយការណ៍នេះ ត្រូវបានកំណត់ដូចខាងក្រោម៖

- អ្នកសារព័ត៌មានរួមមាន អ្នកយកព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ ដូចជា អ្នកយកព័ត៌មាន អ្នកសារព័ត៌មានឯករាជ្យ អ្នកថតរូបសារព័ត៌មាន អ្នកសារព័ត៌មានពលរដ្ឋ បុគ្គលិកជំនួយ និងអ្នកធ្វើការសម្របសម្រួលឱ្យអ្នកសារព័ត៌មានបរទេស និងអ្នកផ្សេងទៀតដែលមានប័ណ្ណសារពត៌មានពីក្រសួងព័ត៌មាន ឬប័ណ្ណសំគាល់ខ្លួនពីស្ថាប័នរបស់ខ្លួន។ វាមិនរាប់បញ្ចូលអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដែលគ្មានលិខិតបញ្ជាក់វិជ្ជាជីវៈទាំងនេះទេ។
    - ករណីយាយី រាប់បញ្ចូលគ្រប់ទម្រង់នៃការវាយប្រហារ ចាប់ពីអំពើហិង្សា រហូតដល់ការគំរាមកំហែង ការចាប់ខ្លួន ការចាប់ដាក់ពន្ធនាគារ វិធានការផ្លូវច្បាប់ និងការដកហូតអាជ្ញាបណ្ណ។
    - ចំណាត់ការតាមផ្លូវច្បាប់ មានន័យថា ការប្រើប្រាស់ផ្លូវច្បាប់ ឬតុលាការចំពោះអ្នកសារព័ត៌មាន រួមទាំងបណ្តឹង និងដីការកោះហៅមកសាកសួរ។
    - ការលុបអាជ្ញាប័ណ្ណមានន័យថា ក្រសួងព័ត៌មានបានលុបអាជ្ញាប័ណ្ណជាផ្លូវការរបស់អង្គភាពសារព័ត៌មានណាមួយ។
    - អំពើហិង្សារួមមានហិង្សាលើរាងកាយ និងការគំរាមកំហែងនៃការប្រើអំពើហិង្សាលើរាងកាយ។
    - ការបំភិតបំភ័យរួមមានករណីដែលអាជ្ញាធរបានគំរាមកំហែងចាប់ខ្លួន ចាត់វិធានការតាមផ្លូវច្បាប់ ឬវិធានការផ្សេងទៀត ក្នុងការប៉ុនប៉ង ដើម្បីរារាំងព័ត៌មានមិនឱ្យយកទៅផ្សព្វផ្សាយ ឬរារាំងអ្នកសារព័ត៌មានមិនឱ្យចូលយកព័ត៌មាន។

- ការរើសអើងរួមមានករណីដែលមន្ត្រី ឬអង្គការ បានសំដៅលើអង្គភាពសារព័ត៌មានឯករាជ្យ ដោយចាត់ទុកពួកគេក្នុងស្ថានភាពខុសពីអ្នកសារព័ត៌មានផ្សេងទៀត ឬរារាំងមិនឲ្យទទួលបានព័ត៌មានចំពោះអ្នកសារព័ត៌មានដែលចាត់ទុកថាសរសេររិះគន់រដ្ឋាភិបាល។

- ការឃុំខ្លួន មានន័យថា ការឃុំខ្លួនដើម្បីសាកសួរពីរបីម៉ោង ឬពេញមួយយប់ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់ និងដាក់ពន្ធនាគារនៅឡើយទេ។

- ការដាក់ពន្ធនាគារ មានន័យថា ការដាក់ក្នុងពន្ធនាគារសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នតាមបទចោទប្រកាន់ជាក់លាក់មួយ ឬដាក់ពន្ធនាគារក្រោយការកាត់ឲ្យជាប់ទោស។

## ២. វិសាលភាព និងដែនកំណត់

របាយការណ៍នេះមានដែនកំណត់ និងចន្លោះប្រហោងខ្លះៗ។ វាមិនបានរាប់បញ្ចូលរាល់ករណីយាយីប្រឆាំងអ្នកសារព័ត៌មានក្នុងឆ្នាំ ២០២២ នោះទេ ប៉ុន្តែមានតែករណីរាយការណ៍ប៉ុណ្ណោះ គឺពីខែមករាដល់ខែធ្នូ ឆ្នាំ ២០២២ ដែលត្រូវបានកំណត់បង្ហាញក្នុងអំឡុងពេលស្រាវជ្រាវរបស់ ខេមបូចា ។ វាទំនងដែលថា មានករណីបន្ថែមជាច្រើនទៀតមិនបានរាយការណ៍ទេ ពីព្រោះអ្នកសារព័ត៌មានតែងតែប្រឈមមុខនឹងការយាយីនៅតាមបណ្តាខេត្តនានា ដែលនៅទីនោះហេតុការណ៍ទំនងមានការលាក់បាំង ដោយសារតែធនធានមានកម្រិតសម្រាប់ការឃ្លាំមើល និងជំនួយផ្នែកច្បាប់។

# III. ការរកឃើញសំខាន់ៗ

## ១. និន្នាការនៃករណីការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅ មួយឆ្នាំ

*អ្នកសារព័ត៌មានបានបន្តប្រឈមមុខនឹងការយាយីនៅពេលចុះយកព័ត៌មាននៅឆ្នាំ ២០២២ គឺជារឿយៗនៅពេលដែលពួកគេរាយការណ៍ព័ត៌មានទាក់ទងរឿងនយោបាយ ជម្លោះដីធ្លី និងការតវ៉ាជាសាធារណៈ។*

*ខេមបូចា បានកត់ត្រាករណីយាយីចំនួន ៣៥ ប្រឆាំងនឹងអ្នកសារព័ត៌មានចំនួន ៥៥នាក់ ដែលរួមមានការវាយប្រហារលើរាងកាយ ការគំរាមកំហែងប្រើអំពើហិង្សា ការរើសអើង ការចាប់ខ្លួន ការចាប់ដាក់ពន្ធនាគារ និងវិធានការតាមផ្លូវច្បាប់ផ្សេងទៀត។ អ្នកសារព័ត៌មានជាង ៣០នាក់ក្នុងចំណោមអ្នកសារព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ (ស្មើនឹងជាង ៥៤% នៃចំនួនសរុប) ទទួលរងអំពើហិង្សា ការគំរាមកំហែងប្រើអំពើហិង្សា ការបំភិតបំភ័យ និងការជាប់ពន្ធនាគារ។*

*ខេមបូចា ក៏បានកត់ត្រាករណី៣បន្ថែមទៀតប្រឆាំងនឹងអ្នកសារព័ត៌មាន៨នាក់ ដែលពាក់ព័ន្ធនឹងការចោទពីបទជំរិតទារប្រាក់។ អ្នកសារព័ត៌មាន៥នាក់ក្នុងចំណោមអ្នកសារព័ត៌មានទាំងនោះ ត្រូវបានចាប់ដាក់ពន្ធនាគារ (៣នាក់នៅខេត្តព្រះវិហារ និង២នាក់នៅខេត្តកំពត)។*

*ចំនួននេះបានថយចុះ ២៨% បើធៀបនឹង៤៩ករណីដែលខេមបូចាបានកត់ត្រា កាលពីឆ្នាំមុន ដែលកើតឡើងទៅលើអ្នកសារព័ត៌មាន ចំនួន៩៦ នាក់ ប៉ុន្តែវានៅតែស្ថិតក្នុងកម្រិតដូចគ្នាក្នុងឆ្នាំ២០២០ ជាឆ្នាំដំបូងដែលខេមបូចាចាប់ផ្ដើមតាមដានករណីធ្វើទុក្ខបុកម្នេញ មកលើអ្នកសារព័ត៌មាន។*

***តារាងទី១ ៖ ចំនួននៃករណីយាយីដែលកត់ត្រាក្នុងឆ្នាំ២០២០ ២០២១ និង២០២២***

| ឆ្នាំ | ចំនួនករណី | ចំនួនអ្នកកាសែត | ចំនួនអ្នកកាសែតស្ត្រី |
|---|---|---|---|
| ២០២០ | ៣៥ | ៧២ | ៣ |
| ២០២១ | ៤៩ | ៩៦ | ៤ |
| ២០២២ | ៣៥ | ៥៥ | ៨ |

## ២. ទីតាំងនៃករណីយាយី

*ករណីយាយីមកលើអ្នកសារព័ត៌មានត្រូវ បានកត់ត្រាក្នុងខេត្តចំនួន ១៤ ក្នុងចំណោម ២៥ ខេត្តក្រុងទូទាំងប្រទេសកម្ពុជា។*

*រូបភាពទី១ ៖ អ្នកសារព័ត៌មានរងការយាយីនៅក្នុងខេត្តចំនួន ១៤ ផ្សេងៗគ្នា។*




*ក្នុងចំណោមខេត្តទាំង១៤នោះ ករណីភាគច្រើនកើតមាននៅរាជធានីភ្នំពេញ រខេត្តបាត់ដំបង កំពង់ឆ្នាំង និងតាកែវ។ ទីកន្លែងទាំង៥នោះមានចំនួនជាង ៧៤% នៃអ្នកសារព័ត៌មានដែលរងការយាយី (៤១នាក់ក្នុងចំណោម ៥៥នាក់)។ ករណីភាគច្រើននៅក្នុងខេត្តទាំង៤នេះ មានពាក់ព័ន្ធនឹងអ្នកសារព័ត៌មានដែលរងការយាយីដោយសារតែរាយការណ៍ព័ត៌មានអំពីការកាប់ឈើខុសច្បាប់ ជម្លោះដីធ្លី និងការតវ៉ារបស់បុគ្គលិក។*

*អ្នកសារព័ត៌មានភាគច្រើននៅក្នុងខេត្តទាំង៤នេះ បានប្រឈមមុខនឹងការយាយី៣ប្រភេទ គឺ អំពើហិង្សាចំណាត់ការតាមផ្លូវច្បាប់ និងការចាប់ខ្លួន។*

*នៅរាជធានីភ្នំពេញ មានអ្នកសារព័ត៌មាន ២៤នាក់រងការយាយី គឺភាគច្រើននៃករណីទាំងនេះមានពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មាន និងការអត្ថាធិប្បាយពីការតវ៉ារបស់បុគ្គលិកណាហ្គាវើលដ៍ ទំនាស់ដីធ្លី និងការបោះឆ្នោតឃុំសង្កាត់។ អ្នកកាសែតភាគច្រើនដែលពាក់ព័ន្ធ បានប្រឈមនឹងការគំរាមកំហែង និងការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ។*

## ៣. ប្រភេទនៃការយាយី

តារាងខាងក្រោមបង្ហាញពីការបែងចែកករណីយាយីជា ៥ប្រភេទ ប ប្រភេទធំៗ៖ វិធានការតាមផ្លូវច្បាប់ ការដកហូតអាជ្ញាប័ណ្ណ ការគំរាមកំហែង ការរើសអើង អំពើហិង្សា (ឬការគំរាមកំហែងប្រើអំពើហិង្សា) ការឃុំខ្លួនដើម្បីសាកសួរ និងការចាប់ដាក់ពន្ធនាគារ។

**តារាងទី ២ ៖ ប្រភេទនៃការបៀតបៀន**

| ប្រភេទនៃការយាយី | ចំនួននៃករណី | ចំនួនអ្នកសារព័ត៌មាន |
|---|---|---|
| បណ្តឹងតាមផ្លូវច្បាប់ | ៧ | ៧ |
| ការលុបអាជ្ញាប័ណ្ណ | ២ | ៤ |
| អំពើហិង្សា | ៤ | ៤ |
| ការគំរាមកំហែង | ១៣ | ១៨ |
| ការរើសអើង | ២ | ៥ |
| ការឃាត់ខ្លួនដើម្បីសាកសួរ | ៣ | ៩ |
| ការចាប់ដាក់ពន្ធនាគារ | ៤ | ៨ |
| **សរុប** | **៣៥** | **៥៥** |

## កំណត់ត្រាការយាយី ឆ្នាំ២០២២




ប្រភេទឧប្បត្តិហេតុដែលកើតឡើងជាញឹកញាប់បំផុត គឺការបំភិតបំភ័យដែលមានចំនួន១៣ ករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន១៨នាក់ ឬប្រហែល ៣៣% នៃឧប្បត្តិហេតុនៃការយាយីសរុបដែលបានកត់ត្រាប្រឆាំងនឹងអ្នកសារព័ត៌មានក្នុងឆ្នាំ ២០២២ (សូមមើលបញ្ជីទាំងស្រុងនៃករណីគំរាមកំហែងខាងក្រោម)។ ក្រុមរងគ្រោះធំទីពីរគឺ វិធានការតាមផ្លូវច្បាប់ ដែលមានចំនួន ៧ ករណី ពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ៧នាក់ (សូមមើលបញ្ជីវិធានការតាមផ្លូវច្បាប់ខាងក្រោម)។

## ៣.១. វិធានការតាមផ្លូវច្បាប់

មន្ត្រី នគរបាល និងអ្នកជំនួញដែលមានអំណាចបានប្រើប្រព័ន្ធតុលាការជាឧបករណ៍ ដើម្បីបំបិទមាត់ប្រព័ន្ធផ្សព្វផ្សាយ។ អ្នកសារព័ត៌មានចំនួន៧នាក់ មកពីអង្គភាពសារព័ត៌មានអនឡាញ៧ផ្សេងគ្នា បានទទួលរងការចោទប្រកាន់តាមផ្លូវច្បាប់គួរឲ្យសង្ស័យក្នុងឆ្នាំ ២០២២។ ពួកគេត្រូវបានកោះហៅ និងសាកសួរដោយនគរបាល និងតុលាការនៅក្នុងខេត្តចំនួន៥ផ្សេងគ្នាគឺ បាត់ដំបង ឧត្តរមានជ័យ កំពត ព្រះវិហារ និងមណ្ឌលគិរី។

### តារាងទី ៣៖ ប្រភេទនៃការបៀតបៀន

| កាលបរិច្ឆេទនៃឧប្បត្តិហេតុ | ចំនួនអ្នកសារព័ត៌មាន | ព័ត៌មានសង្ខេបពីករណីនីមួយៗ |
|---|---|---|
| ថ្ងៃទី១៣ ខែតុលាឆ្នាំ២០២២ | ១ | លោក យួស សារឿន អ្នកសារព័ត៌មាន ផ្នែកជីវិតកម្សាន និងកីឡា ត្រូវបាននគរបាលខេត្តកំពតកោះហៅ បន្ទាប់ពីបានចុះផ្សាយអត្ថបទរិះគន់ស្នងការរងនគរបាលខេត្ត ថាបានប្រើពាក្យសម្តីមិនសមរម្យជាមួយក្រុមគ្រួសារជនសង្ស័យ។<br><br>លោក យាន ធន់ អធិការរងនគរបាលស្រុកទឹកឈូ បានចោទលោក យួស សារឿន ថាផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ជាសាធារណៈ។<br><br>ទោះយ៉ាងនេះក្តី លោក យួស សារឿន និយាយថា លោកផ្សាយព័ត៌មានត្រឹមត្រូវតាមវិជ្ជាជីវៈ។<br><br>លោកមិនបានបង្ហាញខ្លួននៅស្នងការដ្ឋាននគរបាលខេត្តទេ ។ លោកថា លិខិតកោះហៅគួរតែបញ្ជូនទៅអង្គភាពផ្ទាល់របស់លោក គឺមិនមែនមកបុគ្គលនោះទេ។ ( សូមមើលឧបសម្ព័ន្ធទី ២) |
| ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ | ១ | លោក សេន វីរៈ អ្នកយកព័ត៌មានរបស់ SBN Post News ប្រចាំខេត្តបាត់ដំបង ត្រូវបានតុលាការខេត្តកោះហៅកាលពីខែសីហា បន្ទាប់ពីអាជ្ញាធរមូលដ្ឋានចោទលោកពីបទញុះញង់ ដោយសារតែលោកបានផ្សាយបន្តផ្ទាល់ពីជម្លោះដីធ្លីមួយ។<br><br>លោកបានប្រាប់ ខេមបូចា ថា លោកព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចោទបែបនេះមកលើរូបលោក ដោយបញ្ជាក់ថាលោកបានទៅយកព័ត៌មានប្រកបដោយវិជ្ជាជីវៈ និងតាមការអញ្ជើញរបស់អ្នកភូមិ ហើយគ្មានចេតនាញុះញង់ ឬដឹកនាំការបះបោរណាមួយឡើយ។ ( សូមមើលឧបសម្ព័ន្ធទី ៦) |

| | | |
|---|---|---|
| ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ | ១ | លោក សេន វីរៈ អ្នកយកព័ត៌មានរបស់ SBN Post News ប្រចាំខេត្តបាត់ដំបង ត្រូវបានតុលាការខេត្តកោះហៅកាលពីខែសីហា បន្ទាប់ពីអាជ្ញាធរមូលដ្ឋានចោទលោកពីបទញុះញង់ ដោយសារតែលោកបានផ្សាយបន្តផ្ទាល់ពីជម្លោះដីធ្លីមួយ។<br><br>លោកបានប្រាប់ ខេមបូចា ថា លោកព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចោទបែបនេះមកលើរូបលោក ដោយបញ្ជាក់ថាលោកបានទៅយកព័ត៌មានប្រកបដោយវិជ្ជាជីវៈ និងតាមការអញ្ជើញរបស់អ្នកភូមិ ហើយគ្មានចេតនាញុះញង់ ឬដឹកនាំការបះបោរណាមួយឡើយ។ ( សូមមើលឧបសម្ព័ន្ធទី ៦) |
| ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ | ១ | លោក ប៊ុន រិទ្ធ អាយុ ៤៧ ឆ្នាំ ម្ចាស់គេហទំព័រសារព័ត៌មានវិទ្យុដាវដែក ត្រូវបាននគរបាលខេត្តមណ្ឌលគិរី កោះហៅដោយចោទពីបទបរិហារកេរ្តិ៍អាជ្ញាធរមូលដ្ឋានតាមបណ្ដាញសង្គម។<br><br>ការកោះហៅនេះធ្វើឡើងបន្ទាប់ពីលោកបានចុះផ្សាយព័ត៌មានពីគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ដោយចោទអាជ្ញាធរមូលដ្ឋានថាមានចេតនាមិនអើពើនឹងករណីនេះ បន្ទាប់ពីទទួលបានសំណូក។ ប៊ុន រិទ្ធ បានទទួលស្គាល់កំហុសរបស់ខ្លួន ហើយបានកែអត្ថបទបន្ទាប់ពីជួបជាមួយអាជ្ញាធរមូលដ្ឋាន។ ( សូមមើលឧបសម្ព័ន្ធ ១៦) |

| | | |
|---|---|---|
| ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ | ១ | អ្នកសារព័ត៌មាន ប្រចាំខេត្តព្រះវិហារម្នាក់និយាយថាគាត់កំពុងប្រឈមនឹងការចាប់ខ្លួន បន្ទាប់ពីថតគ្រឿងចក្រឈូសឆាយដីរដ្ឋ។ សាលាដំបូងខេត្តបាននិយាយថា ខ្លួនបានចេញដីកាបន្ទាប់ពីបុរសរូបនេះ (អ្នកសារព័ត៌មាន) មិនបានចូលខ្លួនបំភ្លឺតាមការកោះហៅចំនួន ៤ ដង។<br><br>លោក ទ្រី សុផល អ្នកយកព័ត៌មាននៃសារព័ត៌មានអនឡាញ «Everyday» និយាយថា ករណីនេះកើតឡើងតាំងពីចុងឆ្នាំ២០២១មកម្ល៉េះ នៅពេលដែលលោករាយការណ៍អំពីករណីឈូសឆាយដីរដ្ឋនៅឃុំស្រយ៉ង់ ស្រុកគូលែន។<br><br>លោកបានបន្តថា បន្ទាប់មកលោក និងអ្នកសារព័ត៌មានផ្សេងទៀតបានទទួលពាក្យបណ្ដឹងដែលត្រូវបានចោទពីបទលួច និងគំរាមកំហែង។<br><br>លោក សុផលនិយាយថា“ប៉ុន្តែខ្ញុំ [គ្រាន់តែ] បានឃើញបទល្មើស ហើយខ្ញុំបានថត និងរាយការណ៍។ ហេតុអ្វីបានជាគេចោទខ្ញុំបែបនេះ?។<br><br>សុផល បាននិយាយថា គាត់ទទួលរងការវាយដំដែរពេលនោះ ប៉ុន្តែតុលាការខេត្តបានដោះលែងអ្នកវាយនោះវិញ ហើយ។ លោកក៏បានប្ដឹងទៅអង្គភាពប្រឆាំងអំពើពុករលួយអំពីទង្វើរបស់តុលាការដែរ។ (សូមមើលឧបសម្ព័ន្ធ ១៧) |

| | | |
|---|---|---|
| ថ្ងៃទី២២ ខែមីនាឆ្នាំ២២ | ១ | លោក លឹម ផល្លី អាយុ ៤៣ ឆ្នាំ អ្នកយក ព័ត៌មានរបស់សារព័ត៌មានអនឡាញ លួស សេង (Los Seng News) ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅកាន់តុលាការ បន្ទាប់ពីការផ្សាយបន្តផ្ទាល់តាមអនឡាញ កាលពីថ្ងៃទី ១៦ ខែមករា ដែលពេលនោះគាត់បានផ្សាយពីរោងសិប្បកម្មអារឈើមួយកន្លែងនៅខេត្តបាត់ដំបងថាកែច្នៃឈើប្រណីតខុសច្បាប់។<br><br>ផល្លី និយាយថា "យើងឃើញគាត់ដឹកជញ្ជូនឈើយ៉ាងសកម្មចូល និងចេញក្រៅខេត្តបាត់ដំបងជារៀងរាល់ថ្ងៃ។ ពេលអ្នកយកព័ត៌មានរបស់យើងទៅយកព័ត៌មាន គាត់បានប្ដឹងយើង ដោយចោទយើងពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មាន [មិនពិត] ទោះបីខ្ញុំមានឯកសារ វីដេអូ និងរូបថតគាត់ដឹកឈើក៏ដោយ»។<br><br>នាយរដ្ឋបាលព្រៃឈើខេត្តបាត់ដំបង លោក ឈឹម វដ្ឋា៉ និយាយថា រោងសិប្បកម្មនោះមានអាជ្ញាប័ណ្ណ ហើយឈើទាំងអស់ដែលដឹកចូលរោងសិប្បកម្មមានលិខិតត្រឹមត្រូវ។ លោកបន្តថា៖ «បើគ្មានច្បាប់ទេ ពួកគេនឹងមិនអាចដំណើរការបានទេ។ ដូច្នេះតាមគំនិតខ្ញុំ បើវាមិនស្របច្បាប់ គេមិនអាចបើកនៅកណ្ដាលក្រុងបានទេ»។ ( សូមមើលឧបសម្ព័ន្ធ ២៥) |
| ថ្ងៃទី២២ ខែមីនាឆ្នាំ២២ | ១ | លោក ឈឿន ប៊ុនឈី អាយុ ៥២ឆ្នាំ អ្នកយកព័ត៌មាន របស់សារព័ត៌មាន កម្ពុជា ដេលី ត្រូវបានតុលាការខេត្តឧត្តរមានជ័យចេញដីកាកោះហៅ ពីបទផ្សាយព័ត៌មានមិនពិត តាមប្រព័ន្ធផ្សព្វផ្សាយសង្គម កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១។<br><br>ការកោះហៅនេះធ្វើឡើង បន្ទាប់ពីលោកចុះផ្សាយព័ត៌មានអំពីជម្លោះដីធ្លីរវាងសហគមន៍ និងរដ្ឋបាលព្រៃឈើស្រុក។<br><br>ក្នុងសវនាការកាលពីថ្ងៃទី៣១ ខែមករា សាលាដំបូងខេត្តឧត្តរមានជ័យ បានបង្គាប់ឲ្យលោក ឈឿន ប៊ុនឈី បង់ប្រាក់ចំនួន ៤លានរៀល ឬប្រហែល១ពាន់ដុល្លារអាមេរិក ទៅដើមបណ្ដឹង។ លោកប៊ុនឈីបានប្ដឹងឧទ្ធរណ៍។ ( សូមមើលឧបសម្ព័ន្ធ 28) |

| | | |
|---|---|---|
| ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ | ១ | លួស សេង ចាងហ្វាងព័ត៌មាន លួស សេង ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរយៈពេលប្រាំមួយខែដោយសារការឡាយ វីដេអូផ្សាយផ្ទាល់ដោយបុគ្គលិកពីរនាក់របស់លោកនៅខេត្តកំពត។<br><br>អ្នកយកព័ត៌មានរបស់លោកទាំងពីររូបត្រូវបានចាប់ខ្លួនដោយសារចុះយកព័ត៌មានតវ៉ានៅខាងមុខសាលាខេត្តកំពត ប្រឆាំងនឹងការចាប់ខ្លួនប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងជម្លោះដីធ្លី។<br><br>រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ ក៏ធ្លាប់បាននិយាយកាលពីខែវិច្ឆិកា ប្រឆាំងនឹងការចាប់ខ្លួននេះថា "បើ [អ្នកកាសែត] ថតរូបនៅមុខសាលាខេត្ត ម៉េចក៏មិនឲ្យពួកគេថតរូប?"។<br><br>គាត់បានបន្ត «ការចាប់ពួកគេគឺខុស តាមអំពើចិត្តពេកហើយ។ អ៊ីចឹងរដ្ឋបាលរបស់យើងក៏បំពានដែរ»។ ( សូមមើលឧបសម្ព័ន្ធ ៣១) |

អ្នកសារព័ត៌មាន ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបរិហារកេរ្តិ៍ចំនួន៦ករណី ដោយសារតែការរាយការណ៍ពីជម្លោះដីធ្លី។ អ្នកសារព័ត៌មានភាគច្រើនត្រូវបានចោទប្រកាន់ និងកាត់ឲ្យជាប់ទោសដោយសារការរាយរាយការណ៍ព័ត៌មាន និងឡាយវីដេអូផ្សាយផ្ទាល់ពីការតវ៉ា ពាក់ព័ន្ធនឹងពលរដ្ឋដែលខឹងសម្បានឹងអាជ្ញាធរមូលដ្ឋាន ដែលមិនចង់ឱ្យបញ្ហានេះលេចឮដល់សាធារណជន។ ក្នុងករណីខ្លះ CamboJA សង្កេតឃើញថា អ្នកសារព័ត៌មានមិនបានទទួលការឆ្លើយតបពីបុគ្គល ឬភាគីម្ខាងនៃជម្លោះនោះទេ ( ទោះជាយ៉ាងនេះក្តី វាមិនសមហេតុផលចំពោះការចោទតាមបទព្រហ្មទណ្ឌនោះទេ)។

## ករណីសិក្សា៖ ទ្រី សុផល ប្រឈមមុខនឹងដីកាចាប់ខ្លួន បន្ទាប់ពីថតគ្រឿងចក្រឈូសឆាយដី



គ្រឿងចក្រកំពុងឈូសឆាយដីព្រៃរដ្ឋនៅស្រុកគូលែនខេត្តសៀមរាប។ រូបថត ផ្តល់ឲ្យ

លោកទ្រី សុផលអាយុ៣១ឆ្នាំជាអ្នកសារព័ត៌មានអនឡាញ "Everyday" និយាយថា គាត់កំពុងប្រឈមមុខនឹងការចាប់ខ្លួន បន្ទាប់ពីថតគ្រឿងចក្រឈូសឆាយដីរដ្ឋ។ តុលាការនិយាយថា ដីកាត្រូវបានចេញបន្ទាប់ពីអ្នកកាសែតរូបនេះមិនចូលខ្លួនដើម្បីបំភ្លឺ ចំនួន ៤ដង។

សុផលបាននិយាយថាករណីនេះកើតឡើងកាលពីចុងឆ្នាំមុន នៅពេលដែលលោករាយការណ៍អំពីគ្រឿងចក្រឈូសឆាយដីរដ្ឋនៅឃុំស្រយ៉ង់ ស្រុកគូលែន។[2]

លោកសុផលនិយាយថា លោកនិងអ្នកសារព័ត៌មានផ្សេងទៀតត្រូវគេចោទថាលួចនិងគំរាមកំហែង។ សុផលនិយាយថា ខ្ញុំត្រូវគេចោទថាលួចបង្គន់។

មានន័យថានៅពេលនោះ ខ្ញុំបានទៅដកសោ ឬកញ្ចក់យករបស់មួយពីជនល្មើសដែលចោទខ្ញុំ។ ប៉ុន្តែខ្ញុំ [គ្រាន់តែ] បានឃើញបទល្មើស ហើយក៏បានថតរូប និងរាយការណ៍ព័ត៌មាន។ ហេតុអ្វីបានជាគេចោទខ្ញុំបែបនេះ?»។

សុផល បាននិយាយថា គាត់ក៏ត្រូវបានគេវាយដំនៅពេលនោះដែរ ប៉ុន្តែតុលាការខេត្តបានដោះលែងអ្នកវាយតប់ទាំងនោះ។

លោកក៏បានប្តឹង ទៅអង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងតុលាការដែរ។ មេធាវីរបស់លោកសុផល គឺលោក ម៉ន កែវស៊ីវិន និយាយថា កូនក្តីរបស់ លោកគ្រាន់តែរាយការណ៍ព័ត៌មាននេះប៉ុណ្ណោះ ហើយលោកក៏នឹងដាក់លិខិតទៅក្រសួងយុត្តិធម៌ ឲ្យជួយអន្តរាគមន៍ករណីនេះដែរ។



លោក ទ្រី សុផល ថតវីដេអូ ក្រុមការងាររដ្ឋបាលព្រៃឈើខេត្ត និងកងរាជអាវុធហត្ថ រឹបអូសឈើខុសច្បាប់ នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ រូបថត ផ្តល់ឲ្យ

2 អ្នកសារព័ត៌មានប្រឈមមុខពីបទចោទចំរិតទារប្រាក់" ប្រកពអ្នកសារព័ត៌មានឈ្មោះលោក ឃួន ណារីម នៃសារព័ត៌មានខេមបូចា ចេញផ្សាយថ្ងៃ២៧ ខែធ្នូ ឆ្នាំ២០២២ តំណភ្ជាប់ https://bit.ly/3Xz2uqy

ទោះយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យតុលាការខេត្ត លោក វុទ្ធ សាវី និយាយថា ដីកាចាប់ខ្លួននេះជាដំណើរការតាមផ្លូវច្បាប់ ដោយសារអ្នកសារព័ត៌មានរូបនោះមិនបានចូលបំភ្លឺតាមការកោះហៅកន្លងមក។

លោកបន្តថា "ខ្ញុំមិនមែនជាអ្នកប្តឹងគាត់ទេ។ ខ្ញុំបានទទួលពាក្យបណ្តឹង។ នៅពេលដែលព្រះរាជអាជ្ញាទទួលបណ្តឹងពីភាគីម្ខាងទៀត មិនថាបុគ្គលនោះត្រូវ ឬខុសទេ គឺភាគីទាំងពីរត្រូវតែចូលបំភ្លឺ ហើយតទល់នឹងអយ្យការ ដើម្បីរកឲ្យឃើញថានរណាប្រព្រឹត្តខុស។ ប្រសិនបើបុគ្គលនោះមិនបានប្រព្រឹត្តបទល្មើសដូចភាគីម្ខាងទៀតចោទទេ ទើបយើងអាចត្រឡប់ទៅផ្ទះវិញបាន»។

លោក សាវី បានបញ្ជាក់ថា អ្នកសារព័ត៌មានផ្សេងទៀតក្នុងករណីនេះត្រូវបានសាកសួររួចហើយបានទៅផ្ទះវិញ។ "គឺមានតែគាត់ម្នាក់ឯង ... មិនបានមកបំភ្លឺទេ" ។ ( សូមមើលឧបសម្ព័ន្ធ ១៩)

កាលពីខែសីហា សុផល ត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការពីបទចោទជំរិតទារប្រាក់។ ក្រោមលក្ខខណ្ឌនៃការនៅក្រៅឃុំរបស់គាត់ រួមនឹងការចូលមកបង្ហាញខ្លួន គាត់មិនត្រូវផ្លាស់ប្តូរអាសយដ្ឋានរបស់គាត់ទេ ហើយត្រូវមកបង្ហាញខ្លួននៅតុលាការ ពេលកោះហៅ។

ចៅក្រមបានចេញដីកាចាប់ខ្លួនលោក សុផល កាលពីខែតុលា បន្ទាប់ពីគាត់មិនបានមកបង្ហាញខ្លួនតាមបទបញ្ជារាល់ខែរបស់តុលាការ ហើយកងរាជអាវុធហត្ថកំពុងតាមរកគាត់។
លោកសុផលបាននិយាយថា៖ «ឥឡូវនេះខ្ញុំបារម្ភណាស់។ វាហាក់ដូចជាការគាបសង្កត់អ៊ីចឹង។ គេមិនចង់ឲ្យខ្ញុំយកព័ត៌មាននៅក្នុងខេត្ត [ព្រះវិហារ] នេះទេ»។

លោកសុផល បានប្រាប់ខេមបូចា ពេលទាក់ទងតាមទូរស័ព្ទពីកន្លែងលាក់ខ្លួនថា គាត់ភ្ញាក់ផ្អើលពេលឃើញដីកាតុលាការ ព្រោះគាត់មិនដែលឃើញដីកាកោះពីតុលាការពីមុនទាល់តែសោះ។
សុផល បាននិយាយថា៖ «ខ្ញុំប្រកាន់ខ្ជាប់វិជ្ជាជីវៈសារព័ត៌មាន។ ខ្ញុំមិនបានប្រព្រឹត្ត [ជំរិតទារប្រាក់] ដូចអ្វីដែលគេចោទខ្ញុំនោះទេ»។

## ៣.២. ការលុបអាជ្ញាប័ណ្ណ

ក្រសួងព័ត៌មានបានដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយយ៉ាងតិចចំនួន ៤ គឺមានអង្គភាព ៣ មកពីអង្គភាពសារព័ត៌មានដែលត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មាន ដែលបំពានលើក្រមសីលធម៌អ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម និងមួយទៀតត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអសីលធម៌ពេលកំពុងផ្សាយផ្ទាល់តាមហ្វេសប៊ុក។ ក្រសួងព័ត៌មាន នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ អនុញ្ញាតឲ្យអង្គភាពសារព័ត៌មានចំនួន៣ បន្តដំណើរការផ្សាយឡើងវិញ។

### ករណីសិក្សា៖ អង្គភាពសារព័ត៌មានអនឡាញចំនួនបីត្រូវបានលុបអាជ្ញាប័ណ្ណ

អង្គភាពសារព័ត៌មានចំនួនបីត្រូវបានលុបអាជ្ញាប័ណ្ណ។ អង្គភាពសារព័ត៌មាន Bayong Times, Khmer Cover TV (KCTV) និង Cambodia Today ត្រូវបិទ បន្ទាប់ពីក្រសួងបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា អង្គភាពសារព័ត៌ទាំងនេះ "ធ្វើការផ្សព្វផ្សាយព័ត៌មានដែលបំពានលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម"។

ប៉ុន្តែលោក ទូច យុទ្ធា និពន្ធនាយកនៃគេហទំព័រ Cambodia Today បានប្រាប់ ខេមបូចា ថា អង្គភាពសារព័ត៌របស់លោកមិនបានធ្វើអ្វីខុសទេ ហើយថារដ្ឋាភិបាលកំពុងដាក់សម្ពាធលើអង្គភាពសារព័ត៌មានឯករាជ្យ។

លោកបាននិយាយថា “Cambodia Today មានគោលបំណងផ្តល់ជូនអ្នកអានទូវប្រភពព័ត៌មានដែលអាចជឿទុកចិត្តបាន ក៏ដូចជាអ្វីដែលកំពុងកើតឡើងនៅក្នុងសង្គម”។

លោកបានបន្ថែមថា “យើងតែងតែប្រកាន់ខ្ជាប់នូវវិជ្ជាជីវៈ និងការពិត ហើយខ្ញុំគិតថា យើងមិនបានធ្វើអ្វីខុស ឬបំពានលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មានទេ ព្រោះយើងគ្រាន់តែរាយការណ៍ការពិតប៉ុណ្ណោះ”។ លោក យុទ្ធា បន្តថា បើទោះមានការគំរាមកំហែងយ៉ាងណាក្តី ក៏លោកនៅតែបន្តធ្វើការងាររបស់លោកដែរ ព្រោះបើអ្នកសារព័ត៌មានមិនហ៊ានរាយការណ៍ការពិតទេ តើមាននរណាអាចធ្វើកើតទៅ?

កាលពីដើមខែកុម្ភៈ Cambodia Today បានចុះផ្សាយរឿងស៊ើបអង្កេតមួយទាក់ទងនឹងអំពើពុករលួយនៅក្នុងក្រសួងការងារ ដែលនិពន្ធនាយកគិតថាអាចជាហេតុផលនៅពីក្រោយការលុបអាជ្ញាប័ណ្ណរបស់ខ្លួន។

លោកនិយាយថា “ខ្ញុំបានចុះផ្សាយអត្ថបទមួយអំពីដំណើរការដេញថ្លៃពុករលួយនៅក្រសួងការងារ ដែលធ្វើឲ្យខ្ទះខ្ទាយថវិកាជាតិរាប់លានដុល្លារ។ បន្ទាប់មកមន្ត្រីក្រសួងព័ត៌មានបានសុំឲ្យខ្ញុំដកអត្ថបទនេះចេញវិញ ប៉ុន្តែខ្ញុំមិនព្រម”។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

លេខ ០៩៧ ពម

ថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរព័ត៌មានទាំង២៥ រាជធានី-ខេត្ត**

**កម្មវត្ថុ:** មិនបន្តអាជ្ញាប័ណ្ណឱ្យអង្គភាពសារព័ត៌មានចំនួន ៣ រួមមាន អង្គភាពសារព័ត៌មាន Bayongtimes (www.bayongtimes.com) អង្គភាពសារព័ត៌មាន KCTV (www.khmercovertv.com) និងអង្គភាពសារព័ត៌មានកម្ពុជាសព្វថ្ងៃ (www.cambodiatoday.news) ។

**យោង:** -របាយការណ៍លេខ១៨៣/២២ ពត៌ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិកម្មនៃក្រសួងព័ត៌មាន ។

-កំណត់ឯកភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរព័ត៌មានទាំង២៥ រាជធានី-ខេត្ត ជ្រាបថា គណៈកម្មាធិការនីតិកម្មនៃក្រសួងព័ត៌មាន បានពិនិត្យ និងស្រាវជ្រាវឃើញថា អង្គភាពសារព័ត៌មានចំនួន ៣ រួមមាន អង្គភាពសារព័ត៌មាន Bayongtimes (www.bayongtimes.com) អង្គភាពសារព័ត៌មាន KCTV (www.khmercovertv.com) និងអង្គភាពសារព័ត៌មាន កម្ពុជាសព្វថ្ងៃ (www.cambodiatoday.news) បានធ្វើការផ្សព្វផ្សាយព័ត៌មានដែលបំពានលើក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្មដែលសាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន ។ ក្នុងន័យនេះ ក្រសួងព័ត៌មាន ជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរព័ត៌មានទាំង២៥ រាជធានី-ខេត្ត មិនត្រូវអនុញ្ញាតឱ្យបន្តអាជ្ញាប័ណ្ណ ដល់អង្គភាពសារព័ត៌មានទាំងបីខាងលើនេះឡើយ ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ប្រធានមន្ទីរព័ត៌មានទាំង២៥ រាជធានី-ខេត្ត ចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ប្រធានមន្ទីរព័ត៌មានទាំង២៥ រាជធានី-ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។

ជ. រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សុខ ឫសសិទ្ធិ

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

លោក ផុស សុវណ្ណ អ្នកនាំពាក្យក្រសួងព័ត៌មានបានប្រាប់ ខេមបូចា ថា អង្គភាពសារព័ត៌មានទាំង៣បានចុះផ្សាយព័ត៌មានមិនពិត ដោយចោទប្រកាន់មន្ត្រីរាជការថាប្រព្រឹត្តអំពើពុករលួយដោយគ្មានភស្តុតាង។

លោកថា នេះជាការរំលោភលើមាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ដែលផ្តល់សិទ្ធិដល់បុគ្គលក្នុងការទាមទារឲ្យដកអត្ថបទចេញ ឬដាក់ពាក្យបណ្តឹងពីបទ «បរិហារកេរ្តិ៍ មួលបង្កាច់ ឬជេរប្រមាថ»។

ក្រសួងបានស្នើឲ្យអង្គភាពសារព័ត៌មានទាំងនោះកែអត្ថបទរបស់ខ្លួនឡើងវិញ ដោយសារពួកគេបំពានលើក្រមសីលធម៌អ្នកសារព័ត៌មាន ដោយផ្សាយព័ត៌មានមិនពិត ប៉ុន្តែពួកគេបដិសេធ។ ដូច្នេះ យើងគ្មានជម្រើសអ្វីក្រៅពីធ្វើការសម្រេចចិត្តបិទនោះទេ□។

លោក ណុប វី នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) បាននិយាយថា ការលុបអាជ្ញាប័ណ្ណអង្គភាពសារព័ត៌មានទាំងបីនេះ គឺជាការបំភិតបំភ័យ និងមានបំណងរារាំងអ្នកសារព័ត៌មានមិនឱ្យធ្វើការងាររបស់ពួកគេ។

លោកបាននិយាយថា “ប្រសិនបើពួកគេរងការគំរាមកំហែង ឬអាជ្ញាប័ណ្ណរបស់ពួកគេអាចត្រូវបានដក បន្ទាប់ពីពួកគេបានចេញផ្សាយរឿងដ៏រសើបនោះ អ៊ីចឹងពួកគេនឹងមិនអាចធ្វើការងារដើម្បីលើកកម្ពស់គណនេយ្យភាពសង្គម អភិបាលកិច្ចល្អ និងកាត់បន្ថយអំពើពុករលួយបានទេ”។

## ៣.៣. អំពើហិង្សា

អ្នកសារព័ត៌មាន៤នាក់បានរងការវាយដំលើរាងកាយ ដោយសារការងាររបស់ពួកគេ។ ភាគច្រើននៃការវាយដំលើរាងកាយបានកើតឡើង នៅពេលដែលអ្នកសារព័ត៌មានធ្វើសេចក្តីរាយការណ៍ អំពីការជួញដូរឈើខុសច្បាប់ និងការដល់មាន់។

| កាលបរិច្ឆេទនៃឧប្បត្តិហេតុ | ចំនួនអ្នកសារព័ត៌មាន | សេចក្តីសង្ខេបនៃករណី |
|---|---|---|
| ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ | ១ | លោក ស៊ូ សេងហាក់ អាយុ៦០ឆ្នាំ ជាអ្នកយកព័ត៌មានរបស់សារព័ត៌មានសារមរកត ប្រចាំខេត្តព្រះវិហារ ត្រូវបានមេបញ្ជាការម្នាក់វាយធ្វើបាបកាលពីថ្ងៃទី២០ ខែសីហា បន្ទាប់ពីលោកបានឃើញនូវអ្វីដែលលោកសង្ស័យថាជាការដឹកជញ្ជូនឈើខុសច្បាប់។<br><br>លោក សេង ហាក់ សង្ស័យថាឈើនេះទទួលបានមកដោយខុសច្បាប់ ហើយគាត់មានបំណងឃាត់រថយន្តដឹកឈើដើម្បីស៊ើបអង្កេត។ ទោះយ៉ាងនេះក្តី មុនពេលគាត់ឃាត់ឡាន គាត់និយាយថា មេបញ្ជាការកងវរសេនាតូចបានចេញពីរថយន្តដើរទៅជិត សេង ហាក់ ដែលកំពុងឈរជាមួយប្រពន្ធរបស់គាត់ ហើយបានវាយពួកគេទាំងពីរ បណ្តាលឱ្យសេងហាក់ឈាមច្រមុះ។ ( សូមមើលឧបសម្ព័ន្ធទី ៨) |
| ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២២ | ១ | លោក ស៊ុន គ្វាន់ចា អ្នកយកព័ត៌មានរបស់សារព័ត៌មាន ពេញចិត្ត (Penh Chet Media) រងការគំរាមកំហែង ហើយរថយន្តរបស់គាត់ត្រូវបានជនអនាមិកម្នាក់បាញ់ចំបន្ទាប់ពីគាត់បានផ្សាយអត្ថបទស្តីពីការជល់មាន់ខុសច្បាប់។<br>ហេតុការណ៍នេះបានកើតឡើងកាលពីយប់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ នៅស្រុកក្រវាញ ខេត្តពោធិ៍សាត់ ។<br><br>នៅក្នុងអត្ថបទនោះ គេចោទ លោក តាំង សារិទ្ធ អធិការនគរបាលស្រុកថាមិនអើពើនឹងការបង្ក្រាបការជល់មាន់ខុសច្បាប់ ហើយមិនហ៊ានបង្ក្រាប ដោយលើកឡើងថា ប្រហែលជាជាប់ពាក់ព័ន្ធនឹងការជល់មាន់ខុសច្បាប់។ ( សូមមើលឧបសម្ព័ន្ធ១០) |

| | | |
|---|---|---|
| ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ | ១ | អ្នកសារព័ត៌មានប្រចាំខេត្តក្រចេះម្នាក់ត្រូវក្រុមឈ្មួញឈើតាមព្រំដែនកម្ពុជា វៀតណាមព្រួតវាយដំនៅស្រុកស្នួល ខេត្តក្រចេះ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២។<br><br>ជនរងគ្រោះឈ្មោះ សាន ស៊ីម ( ហៅវ៉ា) អាយុ៥២ឆ្នាំ ជាអ្នកយកព័ត៌មានរបស់សារព័ត៌មាន សម្រែកស្ត្រីខ្មែរ នៅស្រុកស្នួល បានប្រាប់ GN times ថា ខណៈគាត់កំពុងអង្គុយហូបជំឡុងនៅផ្ទះអ្នកភូមិ ភ្លាមនោះស្រាប់តែមានមនុស្ស៣នាក់កាន់ដំបងមកវាយគាត់។ លោកបានស្គាល់ជនដៃដល់ម្នាក់ឈ្មោះ ខ្យង ដែលគាត់ថាជាឈ្មួញឈើដ៏សកម្មដែលដឹកជញ្ជូនឈើទៅប្រទេសវៀតណាម។ យោងតាមជនរងគ្រោះ ការវាយប្រហារនេះធ្វើឡើង ដើម្បីសងសឹកនឹងលោកដែលបានព្យាយាមថតរូបឈ្មួញដឹកឈើ និងរាយការណ៍អំពីការជួញដូរឈើខុសច្បាប់របស់ពួកគេ។ ( សូមមើលឧបសម្ព័ន្ធ 12 ) |
| ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ | ១ | លោក មាស សូរ៉ា អ្នកយកព័ត៌មានរបស់គេហទំព័រព័ត៌មានមាសសូរ៉ា (Measora) រងការគំរាមប្រើហិង្សា ខណៈលោកកំពុងផ្សាយអំពីការជល់មាន់ខុសច្បាប់នៅសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។<br><br>ម្ចាស់កន្លែងជល់មាន់ត្រូវបានគេចោទថាបានវាយរថយន្តរបស់លោក មាស សូរ៉ា ឲ្យបែកកញ្ចក់ ហើយក៏បានព្យាយាមរឹបអូសទូរស័ព្ទអ្នកយកព័ត៌មាន កុំឲ្យថតរូបកន្លែងជល់មាន់ខុសច្បាប់ដែរ។ ( សូមមើលឧបសម្ព័ន្ធ 24 ) |

ក្នុងករណីហិង្សាទាំង៤នេះ ជនល្មើសមិនត្រូវបានគេនាំយកមកផ្តន្ទាទោសទេ បើទោះជាត្រូវបានគេស្គាល់អត្តសញ្ញាណ ហើយត្រូវប្តឹងដោយអ្នកសារព័ត៌មានក៏ដោយ។ ជនល្មើសដែលគេសង្ស័យ រួមមានអាជ្ញាធរមូលដ្ឋាន ដូចជា កងរាជអាវុធហត្ថ ឈ្មួញរកស៊ីឈើ អ្នកជំនួញ និងជនស៊ីវិលដទៃទៀត ដែលពាក់ព័ន្ធនឹងអំពើខុសច្បាប់។

## ករណីសិក្សា៖ ស៊ូ សេងហាក់ រងការវាយដំពីមេបញ្ជាការ



កិច្ចប្រជុំដើម្បីដោះស្រាយបញ្ហារវាងលោកវរសេនីយ៍ទោ យឿង សៃ និងលោក ស៊ូ សេងហាក់ ដែលមានការចូលរួមពីមន្ត្រីផ្សេងទៀត និងអ្នកសារព័ត៌មាន សារមរកត បានធ្វើឡើងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២។ រូបថត ផ្តល់ឲ្យ

លោក ស៊ូ សេងហាក់ អាយុ ៦០ឆ្នាំ ជាអ្នកសារព័ត៌មានសារមរកត ខេត្តព្រះវិហារ និយាយថា គាត់ត្រូវបានមេបញ្ជាការម្នាក់វាយដំ បន្ទាប់ពីគាត់បានឃើញដោយចៃដន្យនូវអ្វីដែលគាត់សង្ស័យថាជាការដឹកជញ្ជូនឈើខុសច្បាប់។

គាត់បានប្រាប់ ខេមបូឌា ថាគាត់បានកំពុងចូលរួមពិធីជប់លៀងមិត្តភ័ក្តិនៅ ទល់មុខបន្ទាយកងវរសេនាតូចលេខ ៣៩២ នៅស្រុកជាំក្សាន្ត កាលពីយប់ថ្ងៃអាទិត្យ នៅពេលនោះគាត់បានឃើញត្រាក់ទ័រដឹកឈើប្រហែល ២ ម៉ែត្រគូបដោយចៃដន្យ។

តាមលោកសេង ហាក់ លោកវរសេនីយ៍ទោ យឿង សៃ មេបញ្ជាការកងវរសេនាតូច បានជិះត្រាក់ទ័រអមដោយឈ្មួញរកស៊ីឈើម្នាក់។

លោក សេង ហាក់ បាននិយាយថា គាត់ហៀបនឹងស្រែកឃាត់ត្រាក់ទ័រឱ្យឈប់ ដើម្បីពិនិត្យមើលថាតើគេដឹកអ្វីនោះ ប៉ុន្តែមុនពេលគាត់ឃាត់ត្រាក់ទ័រ ស្រាប់តែមេបញ្ជាការបានលោតចុះពីលើត្រាក់ទ័រ ហើយវាយគាត់ និងប្រពន្ធរបស់គាត់ដែលទៅពិធីជប់លៀងជាមួយគ្នា។

លោក សេង ហាក់ បាននិយាយថា៖ «គេឈប់ត្រាក់ទ័រហើយ (វរសេនីយ៍ឯក) សៃ ក៏បានលោតចុះមកហើយវាយខ្ញុំ និងប្រពន្ធខ្ញុំតែម្តង»។ លោកបន្ថែមថា ច្រមុះគាត់ចេញឈាម។

លោក សេង ហាក់ បាននិយាយថា លោកបានដាក់ពាក្យបណ្តឹងភ្លាមៗទៅកងអាវុធហត្ថ ប៉ុន្តែមេបញ្ជាការនោះបានទូរស័ព្ទមកលោក ដើម្បីសុំដោះស្រាយបញ្ហានៅក្រៅប្រព័ន្ធតុលាការ។

លោកបាននិយាយថា៖ «គេបានហៅខ្ញុំទៅសម្រុះសម្រួល ប៉ុន្តែខ្ញុំពិបាកនឹងទទួលយក ព្រោះគាត់វាយខ្ញុំខ្លាំងពេក»។

លោក បានប្រាប់ ខេមបូឌា ថាលោក គិតថាមានឈើលាក់ទុកនៅក្នុងបន្ទាយនោះមួយរយៈមកហើយ ទោះបីជាគេមិនច្បាស់ថាជាឈើរបស់នរណាក៏ដោយ។

*លោកបានបន្តថា «ខ្ញុំមិនដឹងថានរណាជាម្ចាស់ឈើនោះទេ។ យើងគ្រាន់តែដឹងថាមានឈើនៅទីនោះ ប៉ុន្តែយើងមិនអាចចូលទៅកន្លែងនោះបានទេ»។*

*លោកបាននិយាយថា ការកាប់ឈើនិងដឹកជញ្ជូនឈើខុសច្បាប់កំពុងកើតមានច្រើននៅក្នុងតំបន់នេះ ដោយលោកបន្ថែមថា ភាគច្រើនគឺចេញពីព្រៃព្រះរកា ហើយក៏គ្មានចំណាត់ការណាមួយ ដើម្បីទប់ស្កាត់បទល្មើសនោះទេ។*

*លោក ស៊ី វុទ្ធា និពន្ធនាយកនៃសារព័ត៌មានសារមរកត បាននិយាយថា អ្នកយកព័ត៌មានរបស់លោកបានហៅទូរស័ព្ទទៅកងរាជអាវុធហត្ថស្រុកជាំក្សាន្តភ្លាមៗបន្ទាប់ពីកើតហេតុនៅវេលាម៉ោងប្រហែល១០យប់ថ្ងៃអាទិត្យ ហើយមន្ត្រីកងរាជអាវុធហត្ថម្នាក់ក៏បានប្រាប់លោកឱ្យដាក់ពាក្យបណ្ដឹងដែរ។*

*លោកបន្តថា ទោះយ៉ាងណានៅល្ងាចថ្ងៃច័ន្ទ ទី២២ ខែសីហា ភាគីទាំងពីរបានយល់ព្រមបញ្ចប់ពាក្យបណ្ដឹង។ ហើយលោក ក៏បានយល់ព្រមដកអត្ថបទអំពីរឿងវាយដំនេះចេញដែរ។*

*លោក វុទ្ធា បន្តថា មេបញ្ជាការបានពន្យល់ពីការទប់កំហឹងពុំបាន ដោយនិយាយថាលោកបានច្រឡំឈ្មោះ សេង ហាក់ ទៅនឹងអ្នកកាសែតម្នាក់ទៀតដែលជាប់ឈ្មោះជំរិតទារប្រាក់។ ហេតុដូច្នេះហើយទើបលោកវាយគាត់។*

*«គាត់ (លោក សែ) ឮថាអ្នកកាសែតបានជំរិតទារលុយពីអ្នកលក់ជ្រូកព្រៃម្នាក់ ហើយគាត់គិតថា គឺជាលោក សេង ហាក់។ អ៊ីចឹងហើយ ទើបពេលលោកឃើញលោក សេងហាក់ លោកក៏ស្ទុះទៅវាយសេងហាក់ តែម្ដង»។ ទាក់ទងសុំការបំភ្លឺ លោកវរសេនីយ៍ឯក សែ បដិសេធមិនធ្វើអត្ថាធិប្បាយទេ។*

*លោក ហ៊ឹម ខទៀត អ្នកគ្រប់គ្រងផ្នែកស្រាវជ្រាវ និងតស៊ូមតិនៅ ខេមបូចាបាននិយាយថា អ្នកសារព័ត៌មានមិនគួរក្លាយជាជនរងគ្រោះនៃអំពើហិង្សានោះទេ។*

*«ការវាយដំអ្នកកាសែតដែលរាយការណ៍អំពីបញ្ហាផ្សេងៗ ដើម្បីជាប្រយោជន៍សាធារណៈគឺជាការរំលោភសិទ្ធិសេរីភាពសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ។ អ្នកសារព័ត៌មានទាំងអស់ត្រូវតែអាចបំពេញកិច្ចការរបស់ខ្លួនប្រកបដោយសុវត្ថិភាព និងផុតពីគ្រោះថ្នាក់។ ខ្ញុំសូមថ្កោលទោសចំពោះការប្រើអំពើហិង្សាលើលោក ស៊ូ សេងហាក់ ហើយសូមអំពាវនាវដល់អាជ្ញាធរឲ្យនាំជនល្មើសមកផ្ដន្ទាទោសតាមច្បាប់□។ (សូមមើលឧបសម្ព័ន្ធទី ៩)*

*សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ* (IFJ) *បាននិយាយថា “ការប្រើអំពើហិង្សាលើអ្នកសារព័ត៌មាន គឺជាការរំលោភលើសេរីភាពសារព័ត៌មាន។ សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ សូមថ្កោលទោសចំពោះការវាយដំលើលោក ស៊ូ សេងហាក់ និងសូមជំរុញអាជ្ញាធរចាត់វិធានការជាបន្ទាន់ ដើម្បីឲ្យមេបញ្ជាការម្នាក់នោះទទួលខុសត្រូវ»។*

## ៣.៤. ការគំរាមកំហែង

អ្នកកាសែត១៨នាក់ក្នុងនោះមានអ្នកកាសែតស្ត្រី៦នាក់បានប្រឈមនឹងការបំភិតបំភ័យពេលកំពុងបំពេញការងាររបស់ខ្លួន។ អ្នកកាសែតចំនួន៥នាក់រងការបំភិតបំភ័យ និងគំរាមចាប់ខ្លួន ខណៈដែលពួកគេកំពុងយកព័ត៌មានអំពីករណីកូដកម្មបុគ្គលិករបស់ណាហ្គាវើលដ៍ក្នុងរាជធានីភ្នំពេញ។

អ្នកកាសែត៣នាក់រងការបំភិតបំភ័យ និងរារាំង និងហាមឃាត់មិនឲ្យទទួលបានព័ត៌មានអំពីការបោះឆ្នោតឃុំសង្កាត់។ ក្នុងករណីខ្លះ អ្នកសារព័ត៌មានប្រឈមមុខនឹងការគំរាមកំហែងយ៉ាងច្បាស់ពីចំណាត់ការតាមផ្លូវច្បាប់ ចំណែកឯករណីផ្សេងទៀត អ្នកកាសែតត្រូវគេប្រមាថជាសាធារណៈ ឬចំអកឱ្យពេលបំពេញការងាររបស់ពួកគេ។

| កាលបរិច្ឆេទនៃឧប្បត្តិហេតុ | ចំនួនអ្នកសារព័ត៌មាន | សេចក្តីសង្ខេបនៃករណី |
|---|---|---|
| ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ | ១ | ចាងហ្វាងអង្គភាពសារព័ត៌មានឌីជីថល KCTV លោក មីន ឃឿន ប្រឈមការប្តឹងផ្តល់ បន្ទាប់ពីបដិសេធមិនលុបអត្ថបទ និងវីដេអូដែលបង្ហោះនៅលើគេហទំព័រដែលបានចុះផ្សាយ ពីក្រុមហ៊ុន ឡេង ណាវ៉ាត្រាគ្រុប បូមខ្សាច់ចាក់លុបបឹង ដើម្បីសាងសង់ផ្លូវចាក់បេតុងសម្រាប់ចូលទៅទីតាំងគម្រោងអភិវឌ្ឍន៍នៅខេត្តកណ្តាល។<br><br>លោក មីន ឃឿន បាននិយាយថា លោកមិនបារម្ភទេ ព្រោះលោកបង្ហោះតាមអ្វីដែលអ្នកភូមិបានស្នើសុំ ហើយមិត្តរួមការងាររបស់លោកបានចុះទៅដល់កន្លែងបូមខ្សាច់នោះ ហើយបានឃើញការពិតដោយថតរូបភាព និងវីដេអូ ក៏ដូចជាបានសម្ភាសផងដែរ។<br><br>គាត់នឹងជួលមេធាវី បើគាត់នឹងត្រូវគេប្តឹង។ (សូមមើលឧបសម្ព័ន្ធ ១) |
| ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ | ១ | លោក ព្រំ រដ្ឋា អ្នកយកព័ត៌មានរបស់សារព័ត៌មានអនឡាញលួស សេង (LSN) មានមូលដ្ឋាននៅខេត្តស្វាយរៀង បាននិយាយថា លោកស្នងការនគរបាលខេត្តគំរាមចាប់ខ្លួនគាត់។<br><br>ការគំរាមកំហែងនេះបានកើតឡើងបន្ទាប់ពីអ្នកកាសែតរូបនេះបានចុះយកព័ត៌មានគ្រោះថ្នាក់ចរាចរណ៍ក្រុងបាវិត។ លោកថា មន្រ្តីនគរបាលឈ្មោះលោក ឯម សុវណ្ណារិទ្ធ បានបញ្ជាឲ្យលោកលុបរូបថត និងវីដេអូទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍ បើមិនដូច្នេះទេ លោកនឹងចាប់អ្នកយកព័ត៌មានរូបនេះ។<br><br>ពេលដែលអ្នកកាសែតបដិសេធមិនព្រមលុបរូបភាព ប៉ូលិសក៏បានកញ្ឆក់យកទូរសព្ទពី ព្រំ រដ្ឋា ហើយបានលុបវីដេអូ និងរូបថតទាំងអស់ រួចបោះទូរស័ព្ទចោល។<br><br>ចាងហ្វាងម្ចាស់ផេក LSN ឈ្មោះ លួស សេង បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តដើម្បីរកយុត្តិធម៌។ (សូមមើលឧបសម្ព័ន្ធទី ៣) |

| | | |
|---|---|---|
| ថ្ងៃទី៧ ខែតុលាឆ្នាំ២០២២ | ២ | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី លោក ជា សុផារ៉ា បានហៅអ្នកយកព័ត៌មានស្រីពីរនាក់របស់ VOD ក្នុងវេទិកាសាធារណៈ ដោយសុំឱ្យពួកគេឈរក្បែរលោក កុំកម្រើក ហើយសុំឱ្យអង្គរក្សម្នាក់សរសេរឈ្មោះពួកគេ។<br><br>ពេលជួបសំណេះសំណាលជាមួយអ្នកភូមិព្រះដាក់ក្នុងខេត្តសៀមរាប លោករដ្ឋមន្ត្រីបានចោទអង្គភាពសារព័ត៌មានឯករាជ្យនេះថាបានរាយការណ៍មិនសមរម្យ ហើយបានបញ្ជាឲ្យអ្នកកាសែតបរទេសម្នាក់ និងខ្មែរម្នាក់ឈរក្បែរលោក ដើម្បីកុំឲ្យសរសេរសម្ដីរបស់លោកខុស។<br><br>លោកក៏បាននិយាយថា អ្នកកាសែតវ័យក្មេងបកប្រែមិនត្រឹមត្រូវ និងចូលចិត្តសរសេរកុហក់ដើម្បីទាក់ទាញអ្នកអានឲ្យបានច្រើន។ លោក សុផារ៉ា បាននិយាយថា “ឈរនៅត្រង់នេះរហូតដល់កិច្ចប្រជុំចប់ ហើយមិនត្រូវដើរទៅណាទេ”។<br><br>អ្នកយកព័ត៌មានម្នាក់ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ខេមបូចាថា សម្ដីនិងការណែនាំបែបនេះធ្វើឱ្យនាងភ័យខ្លាច ហើយថានាងចាត់ទុកសកម្មភាពរបស់លោកសុផារ៉ា ថាជាការប៉ុនប៉ងគំរាមកំហែងនាង និងអ្នកសារព័ត៌មានផ្សេងទៀត។<br>(សូមមើលឧបសម្ព័ន្ធទី ៨) |
| ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ | ១ | លោក ឃួន ណារីម អ្នកសារព័ត៌មាន CamboJA News បានទទួលប្រតិកម្មជាសាធារណៈពីអ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌចំពោះអត្ថបទរបស់ខ្លួនដែលមានចំណងជើងថា “UN ថា សេរីភាពសារព័ត៌មាននៅកម្ពុជានៅតែរឹតត្បិតខ្លាំង”។<br><br>នៅក្នុងលិខិតចំហមួយផ្ញើជូន CamboJA និងលោក ឃួន ណារីម លោក មាស សោភ័ណ្ឌ បានច្រានចោលកថាខណ្ឌ "អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បានច្រានចោលការរកឃើញរបស់ OHCHR ដោយថាពួកគេបានមកតែពីការសម្ភាសជាមួយអ្នកកាសែតប្រឆាំងរដ្ឋាភិបាលប៉ុណ្ណោះ ហើយមិនបានឆ្លុះបញ្ចាំងពីការពិតទាំងមូលនៃប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសទេ"។ លោកបញ្ជាក់ថា លោកមិនបានបដិសេធការរកឃើញនោះទេ ហើយថាអ្នកកាសែតមិនបានដកស្រង់សម្ដីរបស់លោកឲ្យបានត្រឹមត្រូវទេ។ (សូមមើលឧបសម្ព័ន្ធ ១១) |

| | | |
|---|---|---|
| ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ | ១ | កាលពីថ្ងៃទី២៧ ខែមិថុនា អាជ្ញាធរបានបណ្ដេញអ្នកកាសែត និង អ្នកឃ្លាំមើលសិទ្ធិមនុស្សចេញពីកន្លែងតវ៉ារបស់ណាហ្គាវើលដ៍ ថែមទាំងមានការគំរាមកំហែងពីក្រុមសន្តិសុខខណ្ឌ និងទាមទារ ឱ្យអ្នកសារព័ត៌មាន VOD ( សុំមិនបញ្ចេញឈ្មោះ) លុបរូបថត និង វីដេអូនៃសកម្មភាពរបស់អាជ្ញាធរនៅតាមទីសាធារណៈទៀតផង។<br><br>ឆ្លើយតបនឹងចំណាត់ការនេះ ក្រសួងព័ត៌មានបាននិយាយថា អាជ្ញាធរថ្នាក់ក្រោមហាក់មិនទាន់យល់ច្បាស់ពីតួនាទីរបស់ពួកគេ និងធ្វើសកម្មភាពហួសគោលការណ៍។ លោក ផុស សុវណ្ណ អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាននៃក្រសួងព័ត៌មានបាននិយាយថា៖ «ខ្ញុំបានពិភាក្សាពីបញ្ហានេះ ហើយប្រហែលជាអាជ្ញាធរថ្នាក់ក្រោមមិនយល់ពីបញ្ហានេះនៅឡើយទេ។ ( សូមមើលឧបសម្ព័ន្ធទី ១៩) |
| ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ | ១ | លោក អ៊ួន ឈិន អ្នកយកព័ត៌មានរបស់ CamboJA ត្រូវបាន អាជ្ញាធរមូលដ្ឋានបំភិតបំភ័យ និងគំរាមកំហែងពេលចុះយក ព័ត៌មាននៅឯការជួបជុំដោយសន្តិវិធីរបស់ពលរដ្ឋបឹងតាមោក នៅមុខខុទ្ទកាល័យ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។<br><br>មន្ត្រីមូលដ្ឋានម្នាក់បានចង្អុលមុខគាត់ ហើយស្រែកថា "អ្នកមកពីណា ហ៎ាស"។ គាត់ឆ្លើយថា "ខ្ញុំមកពី ខេមបូចា "។ មន្ត្រីនោះបញ្ជាក់ថា "យកកាតកាសែតចេញមកភ្លាម" ។ លោក អ៊ួន ឈិន ក៏ដើរចេញពីមន្ត្រីនោះ ដោយសារគាត់ខ្លាចគេដកហូតកាមេរ៉ាគាត់ ហើយគាត់បានឮមន្ត្រីនិយាយគ្នាតាមអាយកូមថា "នាំគាត់មក។ នាំគាត់មក" ។<br><br>លោកចាត់ទុកករណីនេះថាជាការគំរាមកំហែងដល់រូបលោកក៏ដូចជាអ្នកសារព័ត៌មានដទៃទៀត ហើយក៏ជាការរឹតត្បិតសេរីភាពសារព័ត៌មានដែរ។ ( សូមមើលឧបសម្ព័ន្ធ ១៤) |

| | | |
|---|---|---|
| ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ | ១ | ក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់ លោក ស៊ិន សា វ៉ាត អ្នកយកព័ត៌មានរបស់ ខេមបូចា  ដែលយកព័ត៌មានអំពីការបោះឆ្នោតនៅការិយាល័យបោះឆ្នោតបឋមសិក្សាវាលស្បូវក្នុងរាជធានីភ្នំពេញ ត្រូវបានសាកសួរដោយមន្ត្រីនគរបាលដែលមានតួនាទីជាសន្តិសុខ និងជាប្រធានការិយាល័យបោះឆ្នោត។ គេហាមគាត់មិនឱ្យចូលទៅក្នុងកន្លែងបោះឆ្នោតដើម្បីថតរូបពេលគេរាប់សន្លឹកឆ្នោតទេ។ សា  វ៉ាត បាននិយាយថា៖ «ខ្ញុំត្រូវបានប៉ូលិស និងប្រធានការិយាល័យបោះឆ្នោតសួរនាំ ពេលចុះយកព័ត៌មាននៅវាលស្បូវ ហើយមិនអនុញ្ញាតឲ្យចូលទៅជិតដើម្បីថតរូបពេលរាប់សន្លឹកឆ្នោតទេ□។<br>( សូមមើលឧបសម្ព័ន្ធ 18 ) |
| ថ្ងៃទី៣ ខែនិថុនា ឆ្នាំ២០២២ | ២ | អ្នកកាសែតពីររូបមកពី VOD គឺលោក សេង ថៃ និងលោក ហ៊ុ ផៃ ត្រូវបានអាជ្ញាធរសួរនាំ ហើយបានពិនិត្យមើលកាតកាសែតរបស់ពួកគេ ពេលដែលពួកគេកំពុងសម្ភាសបេក្ខជនពីរនាក់នៅសង្កាត់ទឹកល្អក់១ រាជធានីភ្នំពេញ អំពីសកម្មភាពឃោសនារបស់គណបក្សប្រជាជនកម្ពុជា និងផែនការរបស់ពួកគេ។<br>នៅថ្ងៃបោះឆ្នោត ពេលកំពុងសម្ភាសមនុស្ស៥នាក់នៅការិយាល័យបោះឆ្នោតនៅវត្តចាក់អង្រែលើ ក៏ស្រាប់តែមានបុរសម្នាក់ស្លៀកពាក់ស៊ីវិលបានសួរពួកគេថា៖ □តើអ្នកឯងកំពុងសម្ភាសពីរឿងអ្វី? តើអ្នកនឹងចាក់ផ្សាយនៅលើប៉ុស្តិ៍ណា ហើយនៅពេលណា? ហើយតើអ្នកសួរគេថាបោះឆ្នោតឲ្យនរណាឬ?<br>លោក ថៃ បាននិយាយថា លោកយល់ថា សំណួរនេះថាជា “ការគំរាមកំហែងដល់សេរីភាពសារព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត” ដោយលោកយល់ថា ថា ប្រសិនបើគាត់សួរថាពួកគេ( អ្នកបោះឆ្នាត ) បោះឆ្នោតឱ្យនរណានោះ គាត់អាចត្រូវបានចាប់ខ្លួនឬកាត់ទោសដូចអ្នកកាសែត Cambodia Daily ពីរនាក់ ដែលត្រូវបានចោទពីបទរាយការណ៍ការបោះឆ្នោតនៅក្នុង ឆ្នាំ ២០១៧។<br>( សូមមើលឧបសម្ព័ន្ធ ១៩) |

| | | |
|---|---|---|
| ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២២ | ១ | លោក សួន វុត្ថា អ្នកសារព័ត៌មានពលរដ្ឋបាននិយាយថា លោកកំពុងធ្វើដំណើរពីខេត្តកំពតមកភ្នំពេញកាលពីថ្ងៃទី១០ ខែមេសា ពេលមកដល់ទីតាំងត្រួតពិនិត្យចរាចរណ៍ មួយនៅស្រុកលើកដែក ខេត្តកណ្ដាល ស្រាប់តែគាត់ឃើញឡានតាក់ស៊ីដឹកអ្នកដំណើរលើសចំណុះ ប៉ុន្តែប៉ូលិសចរាចរណ៍គ្រាន់តែយកលុយ ហើយធ្វើមិនដឹងមិនឮ។ ប៉ូលិសចរាចរណ៍បានគំរាមលោក សួន វុត្ថា ថាបានថតរូបពួកគេយកលុយពីអ្នកបើកបរ ហើយក៏បានបញ្ជាឲ្យលោកលុបរូបថត និងវីដេអូចេញ។ លោកត្រូវបាននាំខ្លួនទៅសាកសួរអស់រយៈពេលជាង១មួយម៉ោង។ មន្ត្រីបានទាមទាររក"សំបុត្របេសកកម្ម" របស់គាត់ក៏ដូចជាអត្តសញ្ញាណបណ្ណ ហើយបានបញ្ជាឱ្យគាត់លុបវីដេអូរបស់គាត់ និងចុះហត្ថលេខាលើកិច្ចសន្យាឈប់ថតរូបតទៅទៀត។ ( សូមមើលឧបសម្ព័ន្ធ ២៣) |
| ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ | ៣ | កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២វេលាម៉ោង៤២និង៣០នាទីរសៀល អ្នកសារព័ត៌មាន VOD ២នាក់ និងអ្នកកាសែតពលរដ្ឋម្នាក់ ត្រូវបានអាជ្ញាធររាជធានីភ្នំពេញ ឃាយី ខណៈពួកគេកំពុងចុះយកព័ត៌មានអំពីការបន្តធ្វើកូដកម្មរបស់បុគ្គលិកណាហ្គាវើលដ៍។ ស្ត្រីអ្នកសារព័ត៌មាន VOD ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ CamboJA ថា "អាជ្ញាធរហាមខ្ញុំ និង មិត្តរួមការងារជាជនបរទេសម្នាក់មិនឲ្យថតរូប សួររកលិខិតបេសកកម្ម ហើយបង្ខំឲ្យយើងលុបរូបភាព និងវីដេអូ បើមិនដូច្នេះទេ អាជ្ញាធរនឹងនាំពួកយើងទៅប៉ុស្តិ៍នគរបាល »។ ( សូមមើលឧបសម្ព័ន្ធ ២៧) |

| | | |
|---|---|---|
| ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ | ១ | លោក ឆាយា នាថ និពន្ធនាយកសារព័ត៌មាន CPC News បានទទួលការហៅទូរស័ព្ទពីមន្ត្រីនគរបាលម្នាក់ឈ្មោះ ម៉ន សុជាតិ ដែលបានតវ៉ាពីអត្ថបទព័ត៌មានទាក់ទងនឹងអំពើហិង្សាដែលប្រព្រឹត្តដោយមន្ត្រីនគរបាលរូបនេះ។ លោក ម៉ន សុជាតិ និយាយថា អត្ថបទរបស់ CPC News លំអៀង ហើយមិនពិត។ មន្ត្រីនគរបាលរូបនេះបានសុំឱ្យ CPC News បញ្ឈប់ការផ្សាយករណីរបស់គាត់ បើមិនដូច្នេះទេគាត់នឹងប្ដឹងសារព័ត៌មានរូបនេះ ប៉ុន្តែ លោកឆាយា នាថ មិនព្រមធ្វើតាម ហើយបាននិយាយថា ការតវ៉ាតាមទូរស័ព្ទ និងពាក្យបណ្ដឹងនេះជាការគំរាមកំហែងដល់វិជ្ជាជីវៈសារព័ត៌មានរបស់គាត់។ ( សូមមើលឧបសម្ព័ន្ធ ២៩) |
| ថ្ងៃទី៩ ខែកុម្ភៈឆ្នាំ២០២២ | ១ | អ្នកកាសែតបរទេសម្នាក់របស់ VOD ទទួលរងការបំភិតបំភ័យ និងគំរាមចាប់ខ្លួន ខណៈដែលគាត់កំពុងរាយការណ៍អំពីសកម្មភាពកូដកម្មនៅក្នុងរាជធានីភ្នំពេញ។ នៅរសៀលថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកសារព័ត៌មានកំពុងថតសកម្មភាពរវាងអាជ្ញាធរ និងក្រុមកូដករកាស៊ីណូណាហ្គាវើលដ៍នៅទីសាធារណៈក្នុងរាជធានី។ មន្ត្រីពាក់ឯកសណ្ឋានទាមទារមើលឯកសារដើមរបស់អ្នកកាសែត និងបានគំរាមចាប់ខ្លួនគាត់ ប្រសិនបើគាត់បន្តថតរូប និងវីដេអូ ដោយបង្ខំឲ្យអ្នកកាសែតម្នាក់នេះឈប់យកព័ត៌មាន ហើយត្រូវចាកចេញភ្លាម។ ( សូមមើលឧបសម្ព័ន្ធ ៣០) |
| ថ្ងៃទី១៩ ខែមករាឆ្នាំ២០២២ | ២ | អ្នកកាសែតពីរនាក់របស់ Cambodian Express News (CEN) បាននិយាយថា ពួកគេបានទទួលរងការគំរាមសម្លាប់ពីម្ចាស់ឆ្កែ បន្ទាប់ពីពួកគេបានផ្សាយផ្ទាល់ពីជម្លោះរវាងម្ចាស់ឆ្កែ និងជនរងគ្រោះដែលត្រូវឆ្កែរបស់គាត់ខាំ។ អ្នកកាសែត CEN ភ័យខ្លាចចំពោះការគំរាមកំហែងនេះ ហើយបានថតសំឡេងម្ចាស់ឆ្កែ ដើម្បីជាភស្តុតាង ក្នុងករណីមានអ្វីមួយកើតឡើងចំពោះពួកគេនាពេលអនាគត។ ( សូមមើលឧបសម្ព័ន្ធ ៣២) |

## ករណីសិក្សា៖ អ្នកកាសែតដែលយកព័ត៌មានអំពីកូដកម្មបុគ្គលិករងការគំរាមកំហែងចាប់ខ្លួននៅភ្នំពេញ



អ្នកកាសែតថតរូបសេរីទទួលរងការយាយីពីអាជ្ញាធរ ពេលកំពុងថតកូដកម្មបុគ្គលិកណាហ្គាវើលដ៍។ រូបភាព ផ្ដល់ឲ្យ

នៅរសៀលថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកសារព័ត៌មានបរទេសម្នាក់របស់ VOD បានរងការគំរាមកំហែង និងគំរាមចាប់ខ្លួន ខណៈដែលនាងកំពុងយកព័ត៌មានអំពីសកម្មភាព កូដកម្មបុគ្គលិកនៅរាជធានីភ្នំពេញ។ អ្នកព័ត៌មានរូបនេះបានកំពុងថតរូប និងថតសកម្មភាពរវាងអាជ្ញាធរ និងបុគ្គលិកកូដកម្មកាស៊ីណូណាហ្គាវើលដ៍នៅទីសាធារណៈក្នុងរាជធានី ពេលនោះស្រាប់តែមានបុរសស្លៀកពាក់ស៊ីវិលម្នាក់ ដែលប្រាប់ថាជាមន្ត្រីអន្តោប្រវេសន៍បានបញ្ឈប់អ្នកកាសែតរូបនេះ ដោយទាមទាររកលិខិតឆ្លងដែន និងប័ណ្ណការងារ ប៉ុន្តែមន្ត្រីរូបនោះ បដិសេធបង្ហាញអត្តសញ្ញាណផ្ទាល់ខ្លួនគាត់។

អ្នកកាសែតបានបង្ហាញប័ណ្ណដែលចេញដោយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) របស់គាត់ និងបង្ហាញច្បាប់ចម្លងលិខិតឆ្លងដែនរបស់គាត់។ យ៉ាងណាក៏ដោយ មន្ត្រីរូបនោះបានទាមទាររកមើលឯកសារដើម និងបានគំរាមចាប់គាត់ប្រសិនបើគាត់បន្តថតរូប និងវីដេអូ។ មន្ត្រីរូបនោះក៏បានបង្ខំអ្នកកាសែតរូបនេះឈប់យកព័ត៌មាន ហើយត្រូវចាកចេញពីកន្លែងតវ៉ា។

ខណៈដែលអាជ្ញាធរមានសិទ្ធិអនុវត្តច្បាប់ដោយយុត្តិធម៌ អ្នកសារព័ត៌មានក៏មានសិទ្ធិរាយការណ៍ព័ត៌មានស្មើៗគ្នា។ ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ហាមឃាត់ការត្រួតពិនិត្យ មុនការបោះពុម្ពផ្សាយ នេះដូចជាអ្វីដែលបានកើតឡើងនៅថ្ងៃទី ៩ ខែកុម្ភៈដូច្នេះដែរ។ ( សូមមើលឧបសម្ព័ន្ធ ៣២)

មានឧប្បត្តិហេតុមួយទៀត នៅថ្ងៃសុក្រ ទី១១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២ និង៣០នាទីរសៀល អ្នកសារព័ត៌មាន VOD ២នាក់ និងអ្នកសារព័ត៌មាន ពលរដ្ឋម្នាក់ ត្រូវបានអាជ្ញាធររាជធានីភ្នំពេញ រំខានយាយី ខណៈដែលពួកគេកំពុងយកព័ត៌មានកូដកម្ម បុគ្គលិកណាហ្គាវើលដ៍។

អ្នកយកព័ត៌មាន ស្រីម្នាក់របស់ VOD ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ ខេមបូចា ថា“អាជ្ញាធរហាមខ្ញុំ និងសហការីជាជនបរទេសមិនឲ្យថតរូប សួររកលិខិតបេសកកម្ម ហើយបង្ខំឲ្យយើងលុបរូបភាព និងវីដេអូ បើមិនដូច្នេះទេអាជ្ញាធរនឹងនាំពួកយើងទៅប៉ុស្តិ៍នគរបាល ។
( សូមមើលឧបសម្ព័ន្ធ ២៩)



មន្ត្រីមូលដ្ឋានរុញអ្នកកាសែតថតរូបនៅឯកន្លែងកូដកម្មបុគ្គលិកណាហ្គាវើលដ៍នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២។ រូបថត ហ៊ាន រង្សី

## ៣.៩. ការរើសអើង

អ្នកសារព័ត៌មាន ៩នាក់បានប្រឈមនឹងការរើសអើង ដែលក្នុងនោះមន្ត្រីបានសំដៅលើអ្នកសារព័ត៌មានឯករាជ្យ ដោយចាត់ទុកពួកគេខុសពីអ្នកសារព័ត៌មាន ផ្សេងទៀត ឬរាំងពួកគេមិនឲ្យទទួលបានព័ត៌មាន ដោយបានចាត់ទុក ពួកគេថារិះគន់រដ្ឋាភិបាល។ នេះគឺជាប្រភេទនៃការរើសអើងថ្មីមួយនៅក្នុងរបាយការណ៍ឆ្នាំនេះព្រោះវាហាក់ដូចជាវិធីដែលគេឃើញប្រើកាន់តែញឹកញាប់ក្នុងការចាត់ទុកអ្នកសារព័ត៌មានឯករាជ្យថាមិនសំខាន់។

### បញ្ជីនៃករណីការរើសអើង

| កាលបរិច្ឆេទនៃឧប្បត្តិហេតុ | ចំនួនអ្នកកាសែត | សេចក្តីសង្ខេបនៃករណី |
|---|---|---|
| ថ្ងៃទី១៣ វិច្ឆិកា២០២២ | ២ | បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ាននៅថ្ងៃទី ១០-១៣ ខែវិច្ឆិកា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអញ្ជើញអ្នកសារព័ត៌មានបរទេស និងក្នុងស្រុកមកចូលរួមសន្និសីទកាសែតរយៈពេល ២ ម៉ោងនៅវិមានសន្តិភាព ប៉ុន្តែបានបដិសេធមិនឲ្យ VOD និង VOA ចូលយកព័ត៌មានទេ។<br><br>អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បាននិយាយថា អ្នកយកព័ត៌មានមកពីអង្គភាពទាំងពីរ □មិនដែលចូលរួម□ សន្និសីទសារព័ត៌មានទាំងនេះទេ ហើយបានចោទថា □គាត់យកតែពីរបីចំណុចប៉ុណ្ណោះ□ ពីសន្និសីទដើម្បីយកទៅផ្សាយ។ ( សូមមើលឧបសម្ព័ន្ធ ២) |
| ថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ | ៣ | VOD, EAC, និង GN time មិនត្រូវបានអនុញ្ញាតឱ្យចូលយកព័ត៌មាននៅសន្និសីទសារព័ត៌មានស្តីពីការចាប់ខ្លួនបុគ្គលិកណាហ្គាវើលដ៍នៅព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ដែលធ្វើឡើងដោយអាជ្ញាធររាជធានីភ្នំពេញនោះទេ។<br>ប្រធានផ្នែកមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ លោក អ៊ិត សុធឿត បាននិយាយថា ការហាមអ្នកសារព័ត៌មានមិនឲ្យយកព័ត៌មានក្នុងសន្និសីទសារព័ត៌មានក្រោមលេសថាមិនបានចុះឈ្មោះ គឺជាការរឹតត្បិតសេរីភាពសារព័ត៌មាន។<br>( សូមមើលឧបសម្ព័ន្ធ ៣៩) |

## ៣.៦. ការឃាត់ខ្លួន ដើម្បីសាកសួរ

អ្នកសារព័ត៌មាន ៩នាក់ត្រូវបានឃុំខ្លួនដើម្បីសាកសួរ ដោយសារការបំពេញការងាររបស់ខ្លួន។ អ្នកសារព័ត៌មាន ៥នាក់ត្រូវបានឃុំខ្លួនពីបទរាយការណ៍ព័ត៌មានពីការឈូសឆាយដីព្រៃនៅដែនជម្រកសត្វព្រៃ ចំណែកឯ ៤នាក់ទៀតត្រូវបានឃុំខ្លួនដោយសារយកព័ត៌មានពីអាជីវកម្មខុសច្បាប់។( សូមមើលករណីសិក្សាៈអ្នកកាសែតត្រូវបានចាប់ខ្លួន និងវាយដំ)

### ករណីសិក្សាៈ អ្នកសារព័ត៌មានត្រូវឃាត់ខ្លួន និងវាយដំ




អ្នកកាសែត និងសកម្មជនបរិស្ថាន ឈរនៅមុខអធិការដ្ឋាននគរបាលស្រុកបាទី បន្ទាប់ពីប៉ូលិសសាកសួរកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២។ CamboJA/ Bun Rithy

អ្នកសារព័ត៌មាន ៥នាក់ មកពីអង្គភាពសារព័ត៌មានឯករាជ្យក្នុងស្រុក VOD ត្រូវបានឃុំខ្លួនប្រហែល ៧ម៉ោង នៅថ្ងៃទី១៦ ខែសីហា បន្ទាប់ពីពួកគេធ្វើសេចក្តីរាយការណ៍ ពីភាពចម្រូងចម្រាស់នៃការឈូសឆាយដីព្រៃនៅដែនជម្រកសត្វព្រៃ។ ពួកគេត្រូវបានចាប់ខ្លួននៅម៉ោងប្រហែល ១១ ព្រឹក នៅសួនសត្វភ្នំតាម៉ៅ ដោយកងអង្គរក្ស និងត្រូវបាននាំទៅកាន់អធិការដ្ឋាននគរបាលស្រុកបាទី ខេត្តតាកែវ ។ អាជ្ញាធរបាននិយាយថាពួកគេបានចូលទៅក្នុងតំបន់ហាមឃាត់។

អ្នកសារព័ត៌មានទាំងនោះគឺ ហ៊ី ឆាយ អាយុ ៣៤ ឆ្នាំ គាត សុខរិទ្ធ សុធារី អាយុ ២៣ ឆ្នាំ ដានីយ៉ែល គីតុន អូលសិន អាយុ ២៨ ឆ្នាំ ម៉ម មុន្នីរតន៍ អាយុ ៤០ ឆ្នាំ និង ហ៊ាន រង្សី អាយុ ២៨ ឆ្នាំ។

អ្នកថតវីដេអូ VOD ម្នាក់ត្រូវមន្ត្រីអង្គរក្ស ទះកំផ្លៀង នៅពេលអ្នកកាសែតរូបនេះបដិសេធមិនប្រគល់ទូរស័ព្ទដែលគាត់កំពុងប្រើដើម្បីថតមន្ត្រីដែលសាកសួរសហការី VOD របស់គាត់។

លោក ហ៊ី ឆាយ ជាអ្នកថតវីដេអូ និយាយថា ខ្ញុំកំពុងតែដើរទៅវត្ត [ភ្នំតាម៉ៅ] ហើយគេប្រាប់ខ្ញុំថា អ្នកយកព័ត៌មាន VOD ត្រូវឃាត់ខ្លួនហើយ។ ខ្ញុំក៏ត្រឡប់ទៅរកពួកគេវិញ ហើយខ្ញុំដកទូរសព្ទចេញ ដើម្បីថតទុកជាឯកសារ។ អង្គរក្សម្នាក់ដើរតម្រង់មករកខ្ញុំ ប្រាប់ខ្ញុំថាកុំថត ហើយគាត់ចង់យកទូរស័ព្ទពីខ្ញុំ ប៉ុន្តែខ្ញុំបដិសេធ។ គាត់ក៏បានទះចំមុខខ្ញុំ ហើយកញ្ឆក់យកទូរស័ព្ទពីដៃខ្ញុំ»។

លោក ម៉ម មុនីរតន៍ អ្នកយកព័ត៌មានរបស់ VOD ដែលត្រូវបានឃុំខ្លួន ហើយដោះលែងមកវិញនោះ បាននិយាយថា “វាជាការរំលោភសិទ្ធិអ្នកសារព័ត៌មាន ព្រោះយើងគ្រាន់តែបំពេញការងាររបស់យើងប៉ុណ្ណោះ។»

លោក មុនីរតន៍និយាយថា “គេមិនបានសួរថាយើងកំពុងធ្វើអីផង គេក៏បញ្ចេញប្រតិកម្មដោយប្រើហិង្សា” ខ្ញុំគិតថាវាអយុត្តិធម៌ព្រោះអ្វីដែលយើងកំពុងធ្វើមិនបានបំពានច្បាប់ហើយអ្នកសារព័ត៌មានមានសិទ្ធិដើរហើរ ខណៈ មិនមានការបញ្ជាក់ថា អ្នកយកព័ត៌មានត្រូវបានហាមឃាត់មិនឱ្យចូលទៅទីតាំងនោះដែរ»។

មុនីរតន៍ បន្តថា លោក និងសហការី បានទៅទីនោះ ដើម្បីយកព័ត៌មានពីការវិវឌ្ឍចុងក្រោយ ទាក់ទងនឹងការដាំដើមឈើឡើងវិញ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី បានលុបចោលសម្បទានដីសេដ្ឋកិច្ច។ លោក មុន្នីរតន៍ បាននិយាយថា“ការចាប់ខ្លួននេះធ្វើឲ្យខូចមុខមាត់រដ្ឋាភិបាល ព្រោះពួកគេគួរតែអនុញ្ញាតឲ្យអ្នកសារព័ត៌មាន មានវិជ្ជាជីវៈធ្វើការដោយគ្មានការភ័យខ្លាច”។

លោក ណុប វី នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) បាននិយាយថា មន្ត្រីដែលធ្វើការឃាត់ខ្លួនបានបំពានច្បាប់ស្តីពីរបបសារព័ត៌មាន ក៏ដូចជាសិទ្ធិរបស់អ្នកសារព័ត៌មាន។ លោកបានបន្ថែមថាអាជ្ញាធរមូលដ្ឋាននៅតែមិនទាន់យល់ពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មានហើយតែងចាត់ទុកអ្នកកាសែតជាសត្រូវ។

លោកបានថ្លែងថា៖ «ការឃុំខ្លួនទាំងនេះគឺជាការប៉ះពាល់មួយទៀតដល់សេរីភាពសារព័ត៌មានដែលត្រូវបានរឹតត្បិតរួចទៅហើយ»។

លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការសិទ្ធិមនុស្សលីកាដូ បាននិយាយថា លោកជឿថាការឃុំខ្លួនអ្នកកាសែត VOD ទាំង៥នាក់របស់អាជ្ញាធរបានរំលោភសិទ្ធិពួកគេជាអ្នកសារព័ត៌មាន និងសិទ្ធិសាធារណៈក្នុងការទទួលបានព័ត៌មាន។

លោកបន្តថា ដើម្បីឲ្យមានតម្លាភាព រដ្ឋាភិបាលគួរតែអនុញ្ញាតឲ្យអ្នកសារព័ត៌មាន រាយការណ៍ព័ត៌មានថាតើការដាំដើមឈើឡើងវិញកំពុងកើតឡើងឬយ៉ាងណា ដោយលោកបញ្ជាក់ថា បញ្ហាភ្នំតាម៉ៅរងការរិះគន់ច្រើនណាស់។

លោកថ្លែងថា៖ «ផ្ទុយទៅវិញការឃុំខ្លួនអ្នកកាសែតគឺជាការរំលោភសិទ្ធិសេរីភាពសារព័ត៌មាន។»
( សូមមើលឧបសម្ព័ន្ធ១០ )

### សាវតារ

អំពើហិង្សា និងការឃុំខ្លួនអ្នកសារព័ត៌មាន VOD ៥នាក់ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ បានកើតឡើងតែប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីព្រៃភ្នំតាម៉ៅ ទទួលរងការកាប់បំផ្លាញព្រៃឈើយ៉ាងសន្ធឹកសន្ធាប់ ដោយបាត់បង់ព្រៃឈើប្រមាណ ៥០០ហិកតា នៅលើតំបន់មានផ្ទៃដីប្រមាណ ២ ០០០ហិកតាក្នុងរយៈពេលប្រហែលតែមួយសប្តាហ៍ប៉ុណ្ណោះ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យដាំដើមឈើវិញនៅថ្ងៃទី៧ ខែសីហា ដោយលុបចោលសម្បទានដីសេដ្ឋកិច្ច ដែលរដ្ឋាភិបាលផ្តល់ឲ្យអ្នកជំនួញមួយចំនួន រួមមាន ឧកញ៉ា ឡេង ណាវ៉ាត្រា និង

ឧកញ៉ា ឃុន ស៊ា ជាដើម។ ការលុបចោលសម្បទានដីសេដ្ឋកិច្ចនេះបានកើតឡើងបន្ទាប់ពីមានអត្ថបទ VOD ចេញផ្សាយជាបន្តបន្ទាប់ដែលមានទាំងរូបភាពថតដោយដ្រូន ទាក់ទងនឹងការបំផ្លាញព្រៃឈើយ៉ាងឆាប់រហ័ស មានអត្ថបទព័ត៌មានផ្សេងទៀត និងរូបភាពថតដោយដ្រូន ជុំវិញការឈូសឆាយព្រៃ និងការខឹងសម្បារពីសាធារជននៅលើបណ្តាញផ្សព្វផ្សាយសង្គម ជុំវិញការកាប់បំផ្លាញព្រៃឈើ។

អ្នកសារព័ត៌មាន VOD ទាំង៥នាក់ដែលត្រូវបានឃុំខ្លួនកាលពីថ្ងៃអង្គារ បានកំពុងតាមដានការរាយការណ៍ព័ត៌មានមុនៗរបស់ពួកគេ ជុំវិញការឈូសឆាយព្រៃឈើ រួមមានធ្វើបទសម្ភាស ថតរូប និងថតដោយប្រើដ្រូនជាដើម។

### ៣.៧. ការចាប់ដាក់ពន្ធនាគារ

ក្នុងចំណោមអ្នកសារព័ត៌មាន ដែលរងការយាយីទាំង ៥៥នាក់ មានអ្នសារព័ត៌មាន ៨នាក់ ឬជាង ១៤% ត្រូវបានចាប់ដាក់ពន្ធនាគារ។

**រូបភាពទី ៣៖ ករណីចាប់ដាក់ពន្ធនាគារទល់នឹងករណីផ្សេងទៀត**



### ៣.៧.១. ការកាត់ឲ្យជាប់ទោសដោយប្រើក្រមព្រហ្មទណ្ឌ

អ្នកសារព័ត៌មានដែលជាប់ពន្ធនាគារទាំង៨នាក់ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ញុះញង់ប្រជាពលរដ្ឋឲ្យតវ៉ាប្រឆាំងនឹងអាជ្ញាធរ ឬញុះញង់ឱ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈ តាមមាត្រា៤៩៤ ៤៩៥ ៤៩៦ និងមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ។ ភាគច្រើននៃករណីទាំងនេះ អ្នកសារព័ត៌មាន ត្រូវបានចាប់ខ្លួនដោយគ្មានដីកា។

ទោះបីជាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជំទាស់នឹងការចាប់ខ្លួនអ្នកសារព័ត៌មាន ម្នាក់របស់ទូរទស្សន៍បាយ័នដែលគាំទ្ររដ្ឋាភិបាល ដែលទំនងជាមិនពាក់ព័ន្ធនឹងការបំពេញភារកិច្ចជាអ្នកសារព័ត៌មាន ក៏ដោយ ប៉ុន្តែ លោកនាយករដ្ឋមន្ត្រីមិនបានជំទាស់ទេ នៅពេលដែលអ្នកកាសារព័ត៌មាន ឯករាជ្យប្រឈមនឹងការផ្តន្ទាទោសនោះ។

តាមពិតអ្នកសារព័ត៌មាន បន្តប្រឈមនឹងការចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាប្រចាំ។ ក្រុមអ្នកសារព័ត៌មាន រួមទាំង ខេមបូចា ដែរ បានអំពាវនាវឱ្យរដ្ឋាភិបាលអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងករណីជាប់ពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ប៉ុន្តែទទួលបានលទ្ធផលតិចតួចបំផុត។

ក្នុងករណីឃ្លាំមើលក្នុងឆ្នាំនេះ អ្នកសារព័ត៌មានត្រូវបានកាត់ឲ្យជាប់ទោសពីបទព្រហ្មទណ្ឌ ទាក់ទងនឹងការផ្សព្វផ្សាយជុំវិញការតវ៉ាជាសាធារណៈ ការបញ្ចេញមតិជុំវិញជំងឺកូវីដ-១៩ និងការផ្សាយសម្តីចោទប្រកាន់ថាអ្នកមានអំណាចប្រព្រឹត្តអំពើពុករលួយ។ វាអាចទៅរួចដែរ ដែលអ្នកសារព័ត៌មាន មានកំហុសនៅក្នុងករណីទាំងនេះ ប៉ុន្តែមិនមែនមានន័យថា ពួកគេត្រូវជាប់ពន្ធនាគារនោះទេ។

មានដំណើរការតាមវិធីរដ្ឋប្បវេណីសម្រាប់អនុវត្តលើករណីបរិហារកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតដែលប្រព្រឹត្តដោយអ្នកសារព័ត៌មាន។ វិធីនេះគួរតែអនុវត្តឲ្យអស់សិន មុននឹងពិចារណាប្រើវិធានការព្រហ្មទណ្ឌ។

### ៣.៧.២. អ្នកកាសែតនៅជាប់ពន្ធនាគារ

គិតត្រឹមខែធ្នូ ឆ្នាំ ២០២២ មានអ្នកសារព័ត៌មាន ចំនួន ៧ នាក់នៅតែជាប់ពន្ធនាគារដោយសារការចោទពីបទព្រហ្មទណ្ឌ រួមមាន ថៃ ប៊ុនរិទ្ធ និង កៅ ពិសិដ្ឋ។ ពួកគេត្រូវបានកាត់ឲ្យជាប់ទោសពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ អ្នកសារព័ត៌មាន ៥នាក់ផ្សេងទៀត មកពីបណ្តាញសារព័ត៌មានអនឡាញ កំពុងស្ថិតនៅក្នុងពន្ធនាគារ និងឃុំខ្លួនបណ្តោះអាសន្ន ក្រោមការចោទពីបទជំរិតទារប្រាក់។ (សូមមើលឧបសម្ព័ន្ធ ១៣ និងឧបសម្ព័ន្ធ ២)

## តារាងទី ២៖ សេចក្តីសង្ខេបនៃករណីជាប់ពន្ធនាគារ

| ចំនួនអ្នកកាសែត | សេចក្តីសង្ខេបនៃករណី | ស្ថានភាព |
|---|---|---|
| ៤ | អ្នកសារព័ត៌មាន អនឡាញ ៤នាក់ ត្រូវបានប នគរបាល ខេត្តកំពង់ឆ្នាំង ចាប់ខ្លួនកាលពីថ្ងៃទី៦ និងថ្ងៃទី៧ ខែមករា ឆ្នាំ២០២២ ពីបទញុះញង់ឲ្យប្រជាពលរដ្ឋតវ៉ាប្រឆាំងនឹងអាជ្ញាធរ។<br><br>អ្នក សារព័ត៌មាន ទាំង៤នាក់នោះគឺ លោក កែវ ហួរ មកពីសារព័ត៌មាន SBT news លោក ប្រាក់ សុងហា, លោក ឈុន គង់តាព, សាង ចាន់ថន និងលោក អ៊ុក ប៉ាវ៉ាឌី នៃសារព័ត៌មាន MCTV។ អ្នកទាំង៤ត្រូវចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។<br><br>អ្នកស្រី ចាន់ គន្ធី អាយុ ៤១ ឆ្នាំ ជាប្រពន្ធរបស់លោក សាង ចាន់ថន បាននិយាយថា ការចាប់ខ្លួននេះធ្វើឡើង បន្ទាប់ពីប្តីរបស់លោកស្រី និងសហការីរបស់គាត់ចុះយកព័ត៌មានពីជម្លោះដីធ្លីនៅស្រុកកំពង់លែង។ | ពួកគេត្រូវបានដោះលែងនៅថ្ងៃទី ២៧ ខែកក្កដាឆ្នាំ ២០២២ បន្ទាប់ពីការចរចា។<br>(សូមមើលឧបសម្ព័ន្ធ ៣៤) |
| ១ | លោក សុខ សារ៉ន អាយុ ៥០ឆ្នាំ ជាអ្នកយកព័ត៌មាន កម្ពុជាពល់ថ្ងៃ ប្រចាំខេត្តបាត់ដំបង ត្រូវបានចាប់ដាក់ពន្ធនាគារនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២២ ដោយតុលាការខេត្តបាត់ដំបង ដោយចោទពីបទញុះញង់អ្នកភូមិឱ្យតវ៉ាប្រឆាំងនឹងអាជ្ញាធរមូលដ្ឋាន។ | គាត់ត្រូវបានដោះលែងនៅថ្ងៃទី ៩ ខែកក្កដាឆ្នាំ ២០២២ បន្ទាប់ពីតុលាការខេត្តបានរកឃើញថាគាត់មិនបានប្រព្រឹត្តល្មើសទេ។<br>(សូមមើលឧបសម្ព័ន្ធ ៣៣) |
| ១ | លោក ថៃ ប៊ុនរិទ្ធ អាយុ ៤១ ឆ្នាំ ជាផលិតករទូរទស្សន៍ អនឡាញ TCN ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៦ ឧសភា តាមបណ្តឹងរបស់នគរបាលខេត្តកណ្តាល។ លោកបានផ្សាយព័ត៌មានដែលអះអាងថា អាជ្ញាធរខេត្តកណ្តាលបានទទួលសំណូកពីម្ចាស់បនល្បែងស៊ីសង ខុសច្បាប់ ហើយធ្វើមិនដឹងមិនឮ។ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល លោក អាត់ ចាន់តារា បាននិយាយថា លោក ប៊ុន រិទ្ធ ត្រូវបានចោទពីបទ «ញុះញង់ឲ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈ» តាមមាត្រា ៤៩៤ ៤៩៦ និង ៣០៥ នៃក្រមព្រហ្មទណ្ឌ។<br><br>មន្ត្រីនគរបាលខេត្តកណ្តាល លោក លាង សាម៉េត និយាយថា ការផ្សាយព័ត៌មានរបស់លោក ប៊ុនរិទ្ធ បានអះអាងថា មន្ត្រីនគរបាល និងកងរាជអាវុធហត្ថ បានឃុបឃិតនជាមួយម្ចាស់បនល្បែងអនឡាញខុសច្បាប់ កត់កន្ទុយលេខឆ្នោត និងជល់មាន់ខុសច្បាប់នៅក្នុងខេត្តកណ្តាល។ | គិតត្រឹមខែធ្នូ ឆ្នាំ២០២២ គាត់នៅតែជាប់ពន្ធនាគារនៅឡើយ។<br>(សូមមើលឧបសម្ព័ន្ធ២០) |

| ចំនួនអ្នកកាសែត | សេចក្តីសង្ខេបនៃករណី | ស្ថានភាព |
|---|---|---|
| ១ | លោក សែម ឌីយ៉ា អាយុ៤៣ឆ្នាំ ជាចាងហ្វាងអង្គភាពព័ត៌មានបាត់ដំបងប៉ុស្តិ៍ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ បន្ទាប់ពីគាត់បានផ្សាយផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់គាត់ពីការតវ៉ានៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ លោក ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។<br><br>ប្រពន្ធរបស់លោក សែម ឌីយ៉ា បានប្រាប់វិទ្យុអាស៊ីសេរីថា ការចាប់ខ្លួននេះជារឿងអយុត្តិធម៌ចំពោះប្ដីរបស់គាត់ ព្រោះប្ដីអលោកស្រីមិនបានប្រព្រឹត្តខុសទេ។ លោកស្រីនិយាយថា ប្ដីរបស់អលោកស្រីត្រូវបានចាប់ខ្លួនបន្ទាប់ពីថត និងបង្ហោះវីដេអូការតវ៉ាទាមទារឲ្យអាជ្ញាធរខ្មែរបញ្ឈប់ការផាកពិន័យរថយន្តដឹកពោតរបស់ថៃ។ កសិករព្រួយបារម្ភថា ចំណាត់ការរបស់អាជ្ញាធរនឹងរារាំងឈ្មួញថៃមិនឲ្យទិញកសិផលរបស់ខ្លួន។ | គាត់ត្រូវបានដោះលែងនៅថ្ងៃទី ២១ ខែតុលាឆ្នាំ ២០២២ បន្ទាប់ពីគាត់បានជាប់ពន្ធនាគារអស់រយៈពេលជាង ៣ ខែ។ សាលាដំបូងខេត្តបាត់ដំបងបានកាត់ទោសគាត់ និងអ្នកតវ៉ាពីរនាក់ទៀតឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ប៉ុន្តែបានព្យួរទោសដែលនៅសល់។<br>(សូមមើលឧបសម្ព័ន្ធ ១៣) |
| ២ | លោក មុី ជុំនិត ចាងហ្វាងទូរទស្សន៍អនឡាញ MCN TV និងអ្នកយកព័ត៌មានរបស់លោក គឺលោក ហ៊ុន គឹមស្រេង ត្រូវបានអាជ្ញាធរខេត្តកំពត ចាប់ខ្លួនកាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២ ពីបទជំរិតទារប្រាក់។ លោក ចំណាន ដែលជាប្អូនប្រុសរបស់លោក មុី ជុំនិត បាននិយាយថា ការចាប់ខ្លួនអ្នកសារព័ត៌មានទាំងពីរនាក់នេះ គឺទាក់ទងនឹងសំណុំរឿងដីធ្លីពាក់ព័ន្ធនឹងស្នងការនគរបាលខេត្តកំពត។<br><br>ប្រធានមន្ទីរព័ត៌មានខេត្តកំពត លោក ឳក សំណាង បញ្ជាក់ថាមានការចាប់ខ្លួនមែន ដោយនិយាយថា អ្នកកាសែតទាំងពីរនាក់នេះ ត្រូវបានចាប់ខ្លួនពីបទជំរិតទារប្រាក់។ យោងតាមសាលក្រមចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ តុលាការខេត្តកំពតបានកាត់ទោសអ្នកសារព័ត៌មាន ទាំងពីរនាក់ឱ្យជាប់ពន្ធនាគាររយៈពេល១ឆ្នាំ និងព្យួរទោស១ឆ្នាំ។ | គិតត្រឹមខែធ្នូ ឆ្នាំ ២០២២ ពួកគេនៅតែស្ថិតក្នុងពន្ធនាគារនៅឡើយ។<br>(សូមមើលឧបសម្ព័ន្ធ ១៣) |

| | | |
|---|---|---|
| ៣ | អ្នកសារព័ត៌មាន បីនាក់រងការចោទថាជំរិតទារប្រាក់៤ ០០០ដុល្លារជាថ្នូរនឹងការមិនចុះផ្សាយព័ត៌មានពីការទិញឈើខុសច្បាប់ពីក្រុមហ៊ុនកាប់ឈើវៀតណាម PNT។ លោក មុំ វិបុល អាយុ ៤៤ ឆ្នាំ ទិន ទ្រី អាយុ ២៩ ឆ្នាំ និង លោក ទិន ស៊ីថា អាយុ ២៧ ឆ្នាំ អ្នកយកព័ត៌មាន អនឡាញ និងទូរទស្សន៍ក្នុងខេត្តព្រះវិហារ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៣ ខែវិច្ឆិកា និងត្រូវបានចោទពីបទជំរិតទារប្រាក់តាមបណ្តឹងរបស់ឈ្មោះ សាត ណាក់ អាយុ ៣០ ឆ្នាំ ជាតំណាងក្រុមហ៊ុន PNT ។ | គិតត្រឹមខែធ្នូ ឆ្នាំ ២០២២ ពួកគេនៅតែជាប់ពន្ធនាគារនៅឡើយ។ ( សូមមើលឧបសម្ព័ន្ធ ២) |
| ១ | លោក កៅ ពិសិដ្ឋ អាយុ ៣២ឆ្នាំ ជាអ្នកកាសែតអនឡាញ សៀមរាបទាន់ហេតុការណ៍ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ និងត្រូវបានចោទពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការរារាំងការអនុវត្តវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ បន្ទាប់ពីចុះផ្សាយរិះគន់ជាសាធារណៈទៅលើរដ្ឋាភិបាលជុំវិញការប្រើប្រាស់វ៉ាក់សាំងចិនចាក់លើប្រជាពលរដ្ឋកម្ពុជ។ គាត់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២២។<br><br>សាលាឧទ្ធរណ៍ប្រចាំតំបន់ខេត្តបាត់ដំបង កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ បានតម្កល់សាលក្រមរបស់តុលាការខេត្ត និងផ្តន្ទាទោសលោក កៅ ពិសិដ្ឋ ដោយបង្គាប់ឲ្យបង់ប្រាក់ពិន័យចំនួន ៣លានរៀល (បីលានរៀល)។<br><br>មេធាវីបាននិយាយថា ពិសិដ្ឋមិនបានដឹងថាគាត់បានប្រព្រឹត្តបទល្មើសដោយគ្រាន់តែធ្វើការអត្ថាធិប្បាយទាក់ទងនឹងវ៉ាក់សាំងកូវីដនោះទេ។ លោកបន្តថា កូនក្តីរបស់លោកបានសម្រេចប្តឹងទៅតុលាការកំពូល។<br><br>តុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍ប្រឆាំងលោក កៅ ពិសិដ្ឋ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។ | គិតត្រឹមខែធ្នូ ឆ្នាំ ២០២២ គាត់នៅតែជាប់ពន្ធនាគារនៅឡើយ។ |

## ៤. ប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយ

ក្នុងចំណោមអ្នកសារព័ត៌មាន ៩៥ នាក់ដែលត្រូវបានគេរាយការណ៍ថារងការយាយី មាន៩១ នាក់ជាអ្នកយកព័ត៌មានប្រព័ន្ធផ្សព្វផ្សាយអនឡាញ ដែលរួមមានគេហទំព័រ ទូរទស្សន៍អនឡាញ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម។ អ្នកសារព័ត៌មានបីនាក់ធ្វើការនៅស្ថានីយវិទ្យុ និងម្នាក់មកពីស្ថានីយទូរទស្សន៍។

**តារាងទី ៣៖ ចំនួនអ្នកសារព័ត៌ដែលរងការយាយីតាមប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយ**

| ប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយ | ចំនួនអ្នកសារព័ត៌មាន |
|---|---|
| ស្ថានីយទូរទស្សន៍ | ១ |
| ស្ថានីយវិទ្យុ | ៣ |
| ប្រព័ន្ធផ្សព្វផ្សាយអនឡាញ | ៩១ |

**រូបភាពទី៤៖អ្នកសារព័ត៌មានដែលរងការយាយីតាមអង្គភាពសារព័ត៌មាន**




ភាគច្រើននៃអ្នកសារព័ត៌មានអនឡាញដែលប្រឈមនឹងការយាយី ទំនងជាឆ្លុះបញ្ចាំងឲ្យឃើញនូវការកើនឡើងយ៉ាងឆាប់រហ័សនៃបណ្ដាញផ្សព្វផ្សាយអនឡាញ និងកង្វះការបណ្ដុះបណ្ដាល ឬការការពារពីអង្គភាពសារព័ត៌មានរបស់ពួកគេអ្នកសារព័ត៌មាន។

## ៥. ស្ថានភាពសារព័ត៌មានក្នុងអំឡុងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ ២០២២

*ការបោះឆ្នោតឃុំសង្កាត់នៅកម្ពុជា បានប្រព្រឹត្តិទៅនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ដោយមានគណបក្សនយោបាយចំនួន១៧ ចូលរួម រួមទាំងគណបក្សភ្លើងទៀនដែរ ដែលបក្សនេះបង្កើតឡើងដោយសមាជិកនៃអតីតគណបក្សសង្គ្រោះជាតិ។*

*ខេមបូចា បានកត់ត្រាយ៉ាងតិចបួនករណីនៃការយាយីទៅលើអ្នកសារព័ត៌មាន៥នាក់ក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់នេះ។*

*អ្នកសារព័ត៌មាន* CamboJA News *លោក ស៊ិន សា រ៉ាត ត្រូវបានអាជ្ញាធរមូលដ្ឋានហាមថតរូប និងសាកសួរនៅពេលលោកចុះយកព័ត៌មាននៅការិយាល័យបោះឆ្នោតសាលាបឋមសិក្សាវាលស្បូវរាជធានីភ្នំពេញនៅថ្ងៃបោះឆ្នោត។*

*បីថ្ងៃមុនការបោះឆ្នោត អ្នកកាសែតពីររូបរបស់* VOD *ត្រូវបានអាជ្ញាធរមូលដ្ឋានបំភិតបំភ័យ ខណៈពួកគេកំពុងសម្ភាសបេក្ខជនឃុំសង្កាត់ម្នាក់។ កាលពីថ្ងៃទី៣ ខែមិថុនា ជាថ្ងៃចុងក្រោយនៃយុទ្ធនាការឃោសនាបោះឆ្នោត អ្នកសារព័ត៌មាន* VOD *លោក សេង ថៃ និងលោក ហ៊ី ធៃ បានសម្ភាសបេក្ខជនពីររូបនៅសង្កាត់ទឹកល្អក់ទី១ រាជធានីភ្នំពេញ អំពីសកម្មភាពឃោសនារបស់គណបក្សប្រជាជនកម្ពុជា និងគម្រោងបម្រើសេវាសង្កាត់របស់ខ្លួន។ បេក្ខជនទី៣ បានសុំថតរូបអ្នកសារព័ត៌មាន និងប័ណ្ណសារព័ត៌មានដែលចេញដោយ គ.ជ.ប។*

*លោក សេង ថៃ បាននិយាយថា៖ «យើងមិនយល់ថាហេតុអ្វីពួកគេថតរូបកាតរបស់យើង ហើយសុំលេខទូរស័ព្ទនោះទេ»។ «យើងភ័យខ្លាច ព្រោះយើងមិនដឹងថាគេយកព័ត៌មាននេះទៅធ្វើអ្វីនោះទេ»។*

*លោក សេង ថៃ បាននិយាយថា នៅថ្ងៃបោះឆ្នោត លោក និងសហការីម្នាក់ទៀត ឈ្មោះ ហ៊ុយ អ៊ូសា បានសម្ភាសមនុស្ស ៥នាក់ នៅការិយាល័យបោះឆ្នោត នៅវត្តចាក់អង្រែលើ ហើយក៏មានបុរសម្នាក់ស្លៀកពាក់ស៊ីវិលបានសួរនាំពួកគេថា៖ តើអ្នកសម្ភាសអំពីអ្វី? តើអ្នកនឹងចាក់ផ្សាយនៅលើប៉ុស្តិ៍ណាហើយនៅពេលណា? តើអ្នកសួរគេថា គេបោះឆ្នោតឲ្យនរណាឬ?*

*លោក ថៃ បាននិយាយថា លោកយល់ថា សំណួរនេះជា "ការគំរាមកំហែងដល់សេរីភាពសារព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត" ដោយលោកបញ្ជាក់ថា ប្រសិនបើពួកគេសួរថាពលរដ្ឋបោះឆ្នោតឱ្យនរណានោះពួកគេអាចត្រូវបានចាប់ខ្លួន ឬផ្តន្ទាទោសដូចអ្នកកាសែត* Cambodia Daily *ពីរនាក់ដូច្នេះដែរ ដែលត្រូវបានចោទពីបទរាយការណ៍ព័ត៌មានពីការបោះឆ្នោតនៅក្នុង ឆ្នាំ ២០១៧។*

*លោក ស៊ុន ណារិន អ្នកយកព័ត៌មានរបស់* VOA *ក៏ជួបប្រទះបញ្ហាដូចគ្នាដែរ នៅពេលដែលលោកចុះទៅយកព័ត៌មាននៅតាមកន្លែងបោះឆ្នោតមួយចំនួនក្នុងស្រុកល្វាឯម ខេត្តកណ្តាល ក្នុងថ្ងៃបោះឆ្នោត។ លោកនិយាយថា លោកបានឃើញអាជ្ញាធរមូលដ្ឋានជាច្រើននៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត។*

*ពេលលោកចុះទៅថតរូបនៅការិយាល័យបោះឆ្នោតនៅអរិយក្សត្រស្រាប់តែមាននគរបាល២នាក់ហាមលោកមិនឲ្យថតរូបអ្វីទាំងអស់ រួចសុំឱ្យលោកចាំមេរបស់ពួកគេមកសិន។ បន្ទាប់ពីរង់ចាំមួយសន្ទុះ លោកក៏*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

លេខ [illegible] ព.ម

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍ និងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់**

*កម្មវត្ថុ:* បញ្ឈប់គ្រប់សកម្មភាពឃោសនាផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២ មុនបោះឆ្នោតមួយថ្ងៃ។

*យោង:* ច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍ និងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ជ្រាបថា យុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលមានរយៈពេល១៤ថ្ងៃ គិតចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ ត្រូវបិទបញ្ឈប់គ្រប់សកម្មភាពឃោសនាផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២ ទុករយៈពេល២៤ម៉ោង មុនថ្ងៃបោះឆ្នោត ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២។

ដើម្បីរក្សាភាពស្ងៀមស្ងាត់ឱ្យប្រជាពលរដ្ឋដែលជាម្ចាស់សំឡេងឆ្នោតធ្វើការសម្រេចចិត្តជ្រើសរើសតំណាងស្របច្បាប់ទៅតាមឆន្ទៈរបស់ខ្លួនតាមបទប្បញ្ញត្តិច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ក្រសួងព័ត៌មាន សូមធ្វើការណែនាំដល់ម្ចាស់ស្ថានីយវិទ្យុ ទូរទស្សន៍គ្រប់ប្រព័ន្ធ និងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ត្រូវបញ្ឈប់គ្រប់សកម្មភាពឃោសនាផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២ ជាកំហិត។ មួយវិញទៀត ចំពោះស្ថានីយវិទ្យុដែលកន្លងមកបានលក់ ឬជួលម៉ោងផ្សាយជាអចិន្ត្រៃយ៍ឱ្យវិទ្យុបរទេស ឬសមាគម អង្គការក្រៅរដ្ឋាភិបាល ឬគណបក្សនយោបាយចាក់ផ្សាយកម្មវិធីព័ត៌មាននៅតាមស្ថានីយរបស់ខ្លួន ត្រូវផ្អាករយៈពេលមួយថ្ងៃ គឺនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២២។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី សហការអនុវត្តសេចក្ដីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ ក្នុងករណីប្រព្រឹត្តិល្មើស ក្រសួងព័ត៌មាន នឹងចាត់វិធានការតាមនីតិវិធីច្បាប់។

សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានដ៏កក់ក្ដៅពីខ្ញុំ។

**រដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** [illegible]

អ៊ុក-ប្រាជ្ញា

*ចម្លងជូន:*

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យ សម្ដេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរព័ត៌មានរាជធានី ខេត្ត
- សមាគមវិទ្យុកម្ពុជា-សមាគមទូរទស្សន៍កម្ពុជា
- ឯកសារ-កាលប្បវត្តិ

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh

សម្រេចចិត្តចាកចេញពីទីនោះ។ នគរបាលក៏បានសួរគាត់ថា "តើអ្នកនឹងទៅការិយាល័យបោះឆ្នោតណាទៀត?" ហើយលោកក៏បាននិយាយថាលោកមិនទាន់ដឹងថាទៅកន្លែងណាទៀតទេ។

លោកណារិទ្ធនិយាយថា"ខ្ញុំគិតថា ករណីនេះតែងតែកើតឡើងចំពោះអ្នកសារព័ត៌មាន ហើយអាជ្ញាធរមូលដ្ឋានជាច្រើនមិនយល់ពីសិទ្ធិ និងភារកិច្ចរបស់អ្នកសារព័ត៌មាននោះទេ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានបានលើកឡើងថា ពួកគេគ្រាន់តែធ្វើតាមការណែនាំរបស់ គ.ជ.ប ប៉ុណ្ណោះ ដូច្នេះ គ.ជ.ប គួរតែចេញគោលការណ៍ណែនាំឲ្យច្បាស់លាស់ដែលបញ្ជាក់ពីសិទ្ធិរបស់អ្នកសារព័ត៌មានថាពួកគេអាចថតរូបបានដោយមិនចាំបាច់សុំការអនុញ្ញាតទេ។

និពន្ធនាយកសារព័ត៌មាន Cambojanews លោក ឆន ចាន់ស៊ី បាននិយាយថា អ្នកសារព័ត៌មាននៅតែប្រឈមនឹងបរិយាកាសរឹតត្បិតសេរីភាពក្នុងពេលបំពេញការងាររបស់ខ្លួនជាពិសេសក្នុងពេលបោះឆ្នោតឃុំសង្កាត់នេះ។

មួយថ្ងៃមុនថ្ងៃបោះឆ្នោត ដែលហៅថា «ថ្ងៃស» ក្រសួងព័ត៌មាន បានចេញលិខិតមួយ បញ្ជាឱ្យអង្គភាពសារព័ត៌មានទាំងអស់ បញ្ឈប់ការផ្សាយព័ត៌មាន ដែលពាក់ព័ន្ធនឹងការបោះឆ្នោតឃុំសង្កាត់ និងហាមគណបក្សនយោបាយមិនឲ្យធ្វើសកម្មភាពណាមួយ ដែលការណ៍នេះអាចប៉ះពាល់ដល់ការប្រើសិទ្ធិរបស់អ្នកសារព័ត៌មាន។

លោក ចាន់ស៊ី ថ្លែងថា លិខិតនេះចង់ដាក់សម្ពាធ និងរឹតត្បិតអ្នកសារព័ត៌មានមិនឲ្យយកព័ត៌មានក្នុងថ្ងៃដ៏សំខាន់នេះ។ ( សូមមើលឧបសម្ព័ន្ធ ២១ )

## ៦.ច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងសេរីភាពសារព័ត៌មាន

### ៦.១. សេចក្តីព្រាងច្បាប់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតរបស់ក្រសួងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រកាសថា ច្បាប់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតដែលរង់ចាំជាយូរហើយនោះ ត្រូវបានព្រាង ប៉ុន្តែថា ក្រសួងកំពុងរង់ចាំការឆ្លើយតបពីវិស័យឯកជន និងស្ថាប័នសាធារណៈ មុននឹងបញ្ជូនសេចក្តីព្រាងនេះទៅអន្តរក្រសួង ដើម្បីពិនិត្យ។

អ្នកនាំពាក្យក្រសួង លោក លីវ សុផាណារិទ្ធ បាននិយាយថា ក្រសួងបានបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅភាគីជាច្រើន រួមទាំងក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតធំៗ ដើម្បីជួយពិនិត្យច្បាប់នេះ។

លោក សុផាណារិទ្ធ បាននិយាយក្នុងសេចក្តីថ្លែងការណ៍ថា “សេចក្តីព្រាងច្បាប់នេះកំពុងកែសម្រួល។ ដើម្បីរៀបចំច្បាប់ថ្មី យើងត្រូវឆ្លងកាត់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់”។

ក្រសួងបានកំណត់កាលបរិច្ឆេទដើម្បីយកធាតុចូល និងមតិផ្សេងៗនៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២២ ប៉ុន្តែត្រូវពន្យារទៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៣ វិញ។

## ៦. ២. ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតរបស់កម្ពុជានៅតែស្ថិតក្រោមការត្រួតពិនិត្យ

*សុវត្ថិភាពឌីជីថលបានក្លាយជាកង្វល់ដ៏ធំមួយក្នុងយុគសម័យនៃការអភិវឌ្ឍឌីជីថលដ៏ឆាប់រហ័ស ដោយសារមនុស្សកាន់តែច្រើនឡើងៗពឹងផ្អែកលើអ៊ីនធឺណិត។ មន្ត្រីម្នាក់និយាយថា ទោះជាយ៉ាងនេះក្តី ច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតរបស់កម្ពុជានៅតែស្ថិតក្រោមការត្រួតពិនិត្យនៅឡើយចាប់តាំងពីឆ្នាំ២០១៣មកម្ល៉េះ ដោយសារការជាប់គាំងក្នុងការប្រើប្រាស់ពាក្យបច្ចេកទេស។*

*ក្នុងសម័យប្រជុំរយៈពេល៥ថ្ងៃ ដែលរៀបចំដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) នៅខេត្តសៀមរាប នោះអ្នកចូលរួមសំខាន់ៗមកពីនាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតរបស់ក្រសួងមហាផ្ទៃ តំណាងមកពីសមាគមអ្នកសារព័ត៌មាន ខេមបូចា និងមជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បានបើកកិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតនិងការវិវឌ្ឍចុងក្រោយរបស់សេចក្តីព្រាងនេះ។*

*ក្នុងកិច្ចពិភាក្សានោះ លោក ឃួន សុខពិសិដ្ឋ អនុប្រធាននាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្ម តាមប្រព័ន្ធអ៊ីនធឺណិតបាននិយាយថា សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតមិនទាន់បញ្ចប់នៅឡើយទេ ដោយសារមានបញ្ហាទាក់ទងនឹងការប្រើប្រាស់ពាក្យបច្ចេកទេស។ លោកបាននិយាយថា គិតត្រឹមពេលនេះ សេចក្តីព្រាងច្បាប់នេះមាន ៥៥ មាត្រា និង ៩ ជំពូក ដែលផ្តោតជាសំខាន់លើឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត និងការកេងប្រវ័ញ្ចលើកុមារ។*

*លោកនិយាយថា "ក្រសួងធ្វើការជាមួយដៃគូផ្សេងទៀត រួមទាំងវិស័យឯកជន និងក្រសួងយុត្តិធម៌ ដើម្បីបង្កើតក្របខ័ណ្ឌច្បាប់នេះ។ យ៉ាងណាក៏ដោយ ខ្ញុំមិនប្រាកដថាតើនឹងមានការបើកចំហឲ្យសាធារណជន និងសង្គមស៊ីវិលផ្តល់មតិលើសេចក្តីព្រាងច្បាប់នេះឬយ៉ាងណាទេ។ វាជាការសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការជ្រើសរើសថានរណាអាចធ្វើការលើសេចក្តីព្រាងច្បាប់នេះ»។*

*លោក ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងក្នុងសិក្ខាសាលានៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ ថា សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត នឹងទទួលយកធាតុចូលពីសាធារណជន បន្ទាប់ពីសេចក្តីព្រាងនេះត្រូវបញ្ចប់ដោយក្រុមការងារបច្ចេកទេសរបស់រដ្ឋាភិបាល។*

## ៦.៣. ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលរង់ចាំជាយូរ កំពុងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី

*បន្ទាប់ពីការសន្យាជាច្រើនឆ្នាំរបស់ក្រុមមន្ត្រី ដើម្បីបញ្ចប់ច្បាប់ដែលបញ្ញត្តិលើការទទួលបានកំណត់ហេតុរបស់រដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មានកាលពីថ្ងៃព្រហស្បតិ៍បាននិយាយថា សេចក្តីព្រាងច្បាប់បានឈានដល់ដំណាក់កាលត្រួតពិនិត្យនៅទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែលោកមិនបានបញ្ជាក់ថា សេចក្តីព្រាងច្បាប់នេះនឹងអនុម័តនៅពេលណាពិតប្រាកដទេ។*

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បាននិយាយថា សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន ត្រូវបានបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីប៉ុន្មានខែកន្លងមកហើយ បន្ទាប់ពីក្រុមមន្ត្រីបានបញ្ចប់ការពិភាក្សាជាមួយក្រសួងយុត្តិធម៌អំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការពិន័យមន្ត្រីដែលមិនបានផ្ដល់ព័ត៌មានតាមការស្នើសុំ។

លោក កាញារីទ្ធ បានប្រាប់អ្នកសារព័ត៌មាននៅខាងក្រៅសន្និសីទសារព័ត៌មានក្នុងទីក្រុងភ្នំពេញ ដែលរៀបចំដោយអង្គការយូណេស្កូ ដែលជាស្ថាប័នរបស់អង្គការសហប្រជាជាតិដឹកនាំពិភាក្សាលើសេចក្ដីព្រាងច្បាប់នេះជាងមួយទសវត្សរ៍មកហើយថា "យើងបានបញ្ចប់ការពិភាក្សាបញ្ហាទាំងនេះ[ជាមួយក្រសួងយុត្តិធម៌]។ យើងបានបញ្ជូនទៅកាន់គណៈរដ្ឋមន្ត្រីរួចហើយ ហើយគណៈរដ្ឋមន្ត្រីនឹងកំណត់ពេលវេលាសម្រាប់ប្រជុំ" ។

ដោយមិនបានបញ្ជាក់ថាពេលណាសេចក្ដីព្រាងច្បាប់នេះបញ្ជូនទៅគណៈរដ្ឋមន្ត្រីនោះ លោកនិយាយថា «យើងបានបញ្ជូន [សេចក្ដីព្រាងច្បាប់នេះ] កាលពីប៉ុន្មានខែមុន ប៉ុន្តែដូចដែលយើងបានដឹងស្រាប់ហើយថា យើងជាប់រវល់ការងាររៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន»។

## ៦.៤. រដ្ឋាភិបាលនិយាយថា អ្នកសារព័ត៌មាន គួរតែជូនដំណឹងដល់អាជ្ញាធររាល់ពេលចុះយកព័ត៌មានតាមខេត្តជាប្រចាំ។

អ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន បាននិយាយកាលពីថ្ងៃទី១ ខែកញ្ញា ថា អ្នកសារព័ត៌មានគួរតែជូនដំណឹងទៅមន្ទីរព័ត៌មានខេត្ត ពេលចុះយកព័ត៌មានជាញឹកញាប់នៅក្នុងដែនសមត្ថកិច្ចខេត្ត ប៉ុន្តែការលើកឡើងបែបនេះត្រូវបានអ្នកតស៊ូមតិនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបដិសេធ។

លោកផៃស៊ីផានបាននិយាយនៅក្នុងសន្និសីទសារព័ត៌មានស្ដីពីការពិនិត្យមើលសមិទ្ធផល៥ឆ្នាំរបស់ក្រសួងព័ត៌មានថា "ប្រសិនបើអ្នកសារព័ត៌មានមានបេសកកម្មញឹកញាប់នៅក្នុងខេត្តមួយ ពួកគេគួរតែដាក់លិខិតទៅមន្ទីរព័ត៌មានខេត្ត" ដើម្បីបញ្ជាក់ពីគោលបំណងរបស់ពួកគេ។

លោកបានបន្តថា មន្ត្រីអាចភិតភ័យ ដោយការទៅជួបជាញឹកញាប់ ហើយថា លិខិតជូនដំណឹងអាចមានសុពលភាពរយៈពេលមួយឆ្នាំ។

លោក ផៃ ស៊ីផាន បាននិយាយថា ៖ «ខ្ញុំបានឃើញអាកប្បកិរិយារបស់អ្នកសារព័ត៌មានខ្លះ គឺភាគច្រើនគ្រាន់តែពាក់កាតអង្គភាពសារព័ត៌មានរបស់ពួកគេ មិនមែនជាកាតដែលចេញដោយក្រសួងព័ត៌មានទេ ហើយគេអាចធ្វើឲ្យប្រជាជនក្នុងខេត្តនោះភិតភ័យ»។

ទោះជាយ៉ាងនេះក្ដី នាយកប្រតិបត្តិសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា លោក ណុប វី បាននិយាយថា មិនគួរមានការតម្រូវបែបនេះដើម្បីជូនដំណឹងដល់អាជ្ញាធរអំពីការចុះយកព័ត៌មាននោះទេ។

លោក វី ថ្លែងថា៖ «ប្រជាពលរដ្ឋមិនចាំបាច់ជូនដំណឹងអំពីវត្តមានរបស់ពួកគេដល់អាជ្ញាធរ ឬអ្នកណាម្នាក់ពេលគេធ្វើដំណើរនោះទេ ហើយយើងជាអ្នកសារព័ត៌មានក៏មិនគួរជូនដំណឹងដល់ពួកគេជាមុនដែរមុននឹងធ្វើដំណើរនោះ»។

# IV. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

យើងមានការប្រុងប្រយ័ត្នក្នុងការទាញសេចក្តីសន្និដ្ឋានណាមួយចេញពីការថយចុះជារួមនៃចំនួនករណីយាយីដែលបានរាយការណ៍ ដោយសារតែកង្វះគំនិតផ្តួចផ្តើម ឬបទបញ្ជារបស់រដ្ឋាភិបាលដែលបង្ហាញថាការធ្លាក់ចុះនេះ គឺជាលទ្ធផលដោយចេតនាកើតចេញពីអាកប្បកិរិយា ឬគោលនយោបាយផ្លូវការ។

អ្វីដែលយើងអាចនិយាយបានដោយប្រាកដប្រជា គឺថាអ្នកសារព័ត៌មានច្រើននាក់ណាស់នៅតែត្រូវរងនូវការយាយី សម្លាធ និងអំពើហិង្សាគ្រប់ទម្រង់ក្នុងឆ្នាំ២០២២។

យើងបានឃើញអង្គភាពសារព័ត៌មានឯករាជ្យកាន់តែច្រើនឡើងៗត្រូវបាន គេហាមឃាត់មិនឲ្យចូលយកព័ត៌មាននៅក្នុងពិធីផ្លូវការផ្សេងៗហើយក៏គ្មានកិច្ចខិតខំប្រឹងប្រែងណាមួយដើម្បីដាក់បុគ្គលដែលយាយីឬវាយប្រហារអ្នកសារព័ត៌មានឱ្យទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេនោះដែរ។

តាមពិតសារដែលតែងតែចេញពីថ្នាក់រដ្ឋមន្ត្រីចុះមកថ្នាក់ក្រោមគឺថាការបំភិតបំភ័យអ្នកសារព័ត៌មាន ជារឿងធម្មតា។ ហើយអ្នកនាំពាក្យរដ្ឋាភិបាលថែមទាំងបានប្រកាសវិធានការថ្មីតាមតែអំពើចិត្តដែលមានបំណងកំណត់សិទ្ធិប្រព័ន្ធផ្សព្វផ្សាយ។

អ្នកសារព័ត៌មាននៅតែរងការតាមដានមើល ការរឹតត្បិតដែលមិនចាំបាច់ និងការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋាន ក្នុងពេលដែលពួកគេកំពុងបំពេញការងាររបស់ពួកគេ។ សរុបមក ការពិតទាំងនេះច្រើនតែឈានទៅរកការដាក់កម្រិតខ្លួនឯង ដែលការណ៍នេះនឹងបំផ្លាញប្រព័ន្ធសារព័ត៌មានសេរី និងដំណើរការប្រជាធិបតេយ្យយ៉ាងស្ងាត់ស្ងៀម។

ខេមបូចា ក៏បានសង្កេតឃើញនិន្នាការគួរឱ្យព្រួយបារម្ភមួយចំនួនផងដែរ។

- ក្រុមព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ស្ទើរតែគ្រប់ករណីដែលពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ទោះបីមានច្បាប់ស្តីពីរបបសារព័ត៌មានជាមធ្យោបាយផ្លូវច្បាប់ជាក់ស្តែងក៏ដោយ។ ការណ៍នេះជះឥទ្ធិពលដោយចេតនាក្នុងការបង្កឲ្យមានការភ័យខ្លាចដល់អ្នកសារព័ត៌មាន និងមិនហ៊ានផ្សាយព័ត៌មានរិះគន់អ្នកមានអំណាចដែរ។ វាបង្ហាញផងដែរថា រដ្ឋាភិបាលកម្ពុជាខ្លាចប្រព័ន្ធផ្សព្វផ្សាយសេរី។ ក្រុមអ្នកតស៊ូមតិប្រព័ន្ធផ្សព្វផ្សាយ និងក្រុមសិទ្ធិមនុស្សបានអំពាវនាវម្តងហើយម្តងទៀតឱ្យមន្ត្រី និងតុលាការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងករណីមានការប្រព្រឹត្តខុសដោយអ្នកសារព័ត៌មាន។ ល្មមដល់ពេលដែលរដ្ឋាភិបាល និងតុលាការត្រូវស្តាប់ហើយ។

- មន្ត្រីមូលដ្ឋានគិតថាមានអំណាចក្នុងការគំរាមកំហែង និងរារាំងអ្នកសារព័ត៌មានមិនឲ្យយកព័ត៌មានអំពីសកម្មភាពសាធារណៈដ៏រសើបផ្នែកនយោបាយ ដូចជាការតវ៉ារបស់បុគ្គលិកណាហ្គាវើលដ៍នៅភ្នំពេញ និងទំនាស់ដីធ្លីនៅទូទាំងប្រទេស។ ជួនកាល ទោះបីក្រសួងព័ត៌មានបាននិយាយគាំទ្រអ្នកសារព័ត៌មាន

នៅក្នុងករណីទាំងនេះក៏ដោយ ក៏សារច្បាស់លាស់ត្រូវតែបញ្ជាក់ថា អ្នកសារព័ត៌មានមានសិទ្ធិ ហើយមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវតែគោរពសេរីភាពក្នុងការបំពេញការងាររបស់ពួកគេនៅតាមកន្លែងសាធារណៈ បើមិនដូច្នេះទេ មន្ត្រីទាំងនោះត្រូវប្រឈមមុខនឹងការទទួលខុសត្រូវចំពោះការបំពានច្បាប់។

- ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យត្រូវទទួលរងការរើសអើង ការគំរាមកំហែង និងវិធានការផ្សេងៗ។ ឧប្បត្តិហេតុទាំងនេះរួមមានអ្នកសារព័ត៌មានត្រូវបានគេហាមឃាត់មិនឲ្យយកព័ត៌មានក្នុងពិធីនានា ជាពិសេសក្នុងសន្និសីទសារព័ត៌មាន ឬការចាត់វិធានការណ៍ធ្ងន់ធ្ងរជាច្រើនទៀត មានដូចជាក្រសួងព័ត៌មានលុបអាជ្ញាប័ណ្ណរបស់អង្គភាពសារព័ត៌មានជាដើម។ ក្នុងករណីភាគច្រើន មិនមានដំណើរការច្បាស់លាស់នៅពីក្រោយការសម្រេចចិត្តហាមឃាត់ទាំងនេះទេ ហើយក៏គ្មានដំណោះស្រាយដល់អ្នកសារព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយដែរ។ នៅក្នុងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយសេរីពិតប្រាកដ អ្នកសារព័ត៌មានទាំងអស់គួរតែទទួលបានការផ្តល់សិទ្ធិ និងសេរីភាពដូចគ្នា។

រាជធានីភ្នំពេញ ដែលមានអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយប្រមូលផ្តុំច្រើនជាងគេ ត្រូវបានមើលឃើញថាករណី នៃការយាយីកើតមានខ្ពស់បំផុត។ ប៉ុន្តែការពិតថា ឧប្បត្តិហេតុត្រូវបានរាយការណ៍ថាកើតមាននៅក្នុងខេត្តចំនួន១៤គឺបង្ហាញថាបញ្ហាទាំងនេះបានកើតឡើងនៅទូទាំងប្រទេស។មានករណីច្រើនកើតឡើងក្នុងខេត្តកំពង់ឆ្នាំង ដែលជាបញ្ហាគួរឲ្យព្រួយបារម្ភចំពោះស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅទីនោះ។

គួរកត់សំគាល់ដែរថា អ្នកសារព័ត៌មាន ភាគច្រើនដែលរងការយាយីក្នុងឆ្នាំ ២០២២ គឺសុទ្ធតែធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយអនឡាញ។ ទោះបីអង្គភាពសារព័ត៌មានទាំងនេះមានទំហំតូចក៏ដោយ ក៏ពួកគេត្រូវចាត់ទុកជាប្រភពព័ត៌មានដ៏សំខាន់ និងលូតលាស់សម្រាប់ប្រជាជនកម្ពុជាដែរ ដែលពួកគេគួរតែទទួលបានការផ្តោតអារម្មណ៍ពីអង្គការណាដែលកំពុងស្វែងរកការកែលម្អវិស័យប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសនេះ។

## អនុសាសន៍សំខាន់ៗ៖

### ប្រព័ន្ធតុលាការ

- ត្រូវទម្លាក់ចោលរាល់ការចោទប្រកាន់បទព្រហ្មទណ្ឌដោយអយុត្តិធម៌ទៅលើអ្នកសារព័ត៌មាន រួមទាំងលោក កៅ ពិសិដ្ឋ និងលោក ទ្រី សុផល។
- ត្រូវប្រកាន់ខ្ជាប់នូវស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍ច្បាប់ ដោយអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មានរបស់កម្ពុជា លើករណីដែលមិនមែនជាបទព្រហ្មទណ្ឌរបស់អ្នកសារព័ត៌មាន។
- ត្រូវធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់លើការវាយប្រហារលើអ្នកសារព័ត៌មាន និងចាប់ជនល្មើសមកផ្តន្ទាទោស។
- ត្រូវផ្តល់ឱកាសបណ្តុះបណ្តាលដល់ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ នគរបាល និងមេធាវី ក្នុងការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន រួមទាំងការបណ្តុះបណ្តាលស្តីពីការវាយតម្លៃខុសផ្អែកលើយេនឌ័រ អំពើហិង្សាផ្អែកលើយេនឌ័រ និងការយាយី ជាពិសេសប្រឆាំងនឹងអ្នកសារព័ត៌មានជាស្ត្រី។

### រដ្ឋាភិបាល និងក្រសួងព័ត៌មាន

- ត្រូវធានាថាអ្នកសារព័ត៌មានទាំងអស់អាចប្រើសិទ្ធិរាយការណ៍ព័ត៌មានដោយសេរី និងគ្មានការភ័យខ្លាច ជាពិសេសរាយការណ៍ព័ត៌មានស្តីពីការបោះឆ្នោតជាតិឆ្នាំ២០២៣នេះ។
- ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយអំពើហិង្សាលើយេនឌ័រ លើអ្នកសារព័ត៌មាន រួមទាំងចាត់វិធានការនានា ដើម្បីធានាឱ្យមានដំណើរការនូវយន្តការ និងនីតិវិធីបណ្តឹង។
- ត្រូវលើកកម្ពស់ការប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មាន ជាជាងប្រើក្រមព្រហ្មទណ្ឌ ក្នុងករណីដែលទាក់ទងនឹងអ្នកសារព័ត៌មាន។
- ត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសអ្នកសារព័ត៌មាន ក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ដូចជា ការធ្វើវិសោធនកម្មច្បាប់ស្តីពីសារព័ត៌មាន និងច្បាប់ផ្សេងទៀតទាក់ទងនឹងសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងសិទ្ធិទទួលបានព័ត៌មាន។
- ក្រសួងព័ត៌មានត្រូវតែដើរតួនាទីឲ្យកាន់តែសកម្មក្នុងការគាំទ្រអ្នកសារព័ត៌មានដែលកំពុងប្រឈមនឹងការយាយី ហើយត្រូវលើកកម្ពស់ការប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មានក្នុងជម្លោះផ្លូវច្បាប់ដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ។
- ត្រូវលុប ឬបញ្ជាក់ឲ្យបានច្បាស់នូវគោលការណ៍ណែនាំដែលកំពុងជំរុញឲ្យអាជ្ញាធរមូលដ្ឋានធ្វើការរឹតត្បិតតាមតែអំពើចិត្ត និងដែលរារាំងអ្នកសារព័ត៌មានមិនឲ្យយកព័ត៌មានពីសកម្មភាពសាធារណៈ។

### អ្នកសារព័ត៌មាន អង្គភាពប្រព័ន្ធផ្សព្វផ្សាយ និងម្ចាស់ជំនួយ

- ដោយផ្តោតលើក្រុមអ្នកសារព័ត៌មានព័ត៌មានប្រព័ន្ធផ្សព្វផ្សាយអនឡាញដែលកំពុងកើនឡើង គឺត្រូវផ្តល់ការបណ្តុះបណ្តាល និងឱកាសទាក់ទងនឹងគោលការណ៍គ្រឹះនៃវិជ្ជាជីវៈសារព័ត៌មាន ក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មាន និងច្បាប់ដែលពាក់ព័ន្ធ និងសេរីភាព។
- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មានអំពីសុវត្ថិភាពរាងកាយ និងសន្តិសុខឌីជីថល។
- ត្រូវផ្តល់ជំនួយផ្លូវចិត្តដល់អ្នកសារព័ត៌មាន។
- ត្រូវផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកសារព័ត៌មាន នៅពេលដែលពួកគេរងការចោទ និងចោទប្រកាន់ដោយតុលាការ។

# V. ឧបសម្ព័ន្ធ

### ១. ថ្ងៃទី ២៣ខែធ្នូ ឆ្នាំ ២០២២៖ ភ្នំពេញ

ចាងហ្វាងទូរទស្សន៍ឌីជីថល KCTV លោក មីន ឃឿន ប្រឈមនឹងចំណាត់ការផ្លូវច្បាប់ បន្ទាប់ពីបដិសេធមិនព្រមលុបអត្ថបទ និងវីដេអូដែលបង្ហោះនៅលើគេហទំព័ររបស់ខ្លួនអំពី ក្រុមហ៊ុន ឡេង ណាវ៉ាត្រា គ្រុបដែលបូមខ្សាច់ចាក់លុបបឹង ដើម្បីចាក់ផ្លូវបេតុងសម្រាប់ចូលគម្រោងអភិវឌ្ឍន៍របស់ខ្លួននៅខេត្តកណ្តាល។

លោក មីន ឃឿន បាននិយាយថា លោកមិនបារម្ភទេ ព្រោះលោកបង្ហោះតាមអ្វីដែលអ្នកភូមិបានស្នើសុំ ហើយសហការីរបស់លោកក៏បានចុះទៅដល់ទីតាំងចាក់ខ្សាច់ដែរហើយបានឃើញការពិតដោយថតរូបភាពនិងវីដេអូក៏ដូចជាសម្ភាសដែរ។ លោកនឹងជួលមេធាវី ការពារក្តី ប្រសិនបើគេប្តឹងលោក។៦

### ២.ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២៖ រាជធានីភ្នំពេញ

បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ាននៅថ្ងៃទី ១០-១៣ ខែវិច្ឆិកា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអញ្ជើញអ្នកកាសែតសារព័ត៌មានជាតិ និង អន្តរជាតិ ចូលរួមសន្និសីទ សារព័ត៌មាន រយៈពេល ២ ម៉ោងនៅវិមានសន្តិភាព ប៉ុន្តែបានបដិសេធមិនឲ្យ VOD និង VOA ចូលរួមទេ។១

អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ និយាយថា អ្នកយកព័ត៌មានមកពីស្ថាប័នព័ត៌មានទាំងពីរ «មិនដែលចូលរួម» សន្និសីទសារព័ត៌មានទាំងនេះទេ ហើយបានចោទថា ពួកគេ □គ្រាន់តែកាត់យកតែពីរបីចំណុចប៉ុណ្ណោះ» ពីសន្និសីទ ដើម្បីយកទៅចុះផ្សាយ។

### ៣.ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២៖ ស្វាយរៀង

លោក ព្រុំ រដ្ឋា អ្នកយកព័ត៌មានរបស់សារព័ត៌មានអនឡាញលួសសេង (LSN) ប្រចាំខេត្តស្វាយរៀង បាននិយាយថា លោកត្រូវបានស្នងការនគរបាលខេត្តគំរាមចាប់ខ្លួន។

ការគំរាមកំហែងនេះបានកើតឡើងបន្ទាប់ពីអ្នកយកព័ត៌មានរូបនេះបានទៅយកព័ត៌មានគ្រោះថ្នាក់ចរាចរណ៍នៅក្រុងបាវិត។ លោកនិយាយថា មន្ត្រីនគរបាលលោក ឯម សុវណ្ណារិទ្ធ បានបញ្ជាឲ្យលោកលុបរូបថតនិងវីដេអូគ្រោះថ្នាក់ចរាចរណ៍ បើមិនដូច្នេះទេ នឹងត្រូវឃាត់ខ្លួន ។ ពេលដែលអ្នកយកព័ត៌មានមិនព្រមលុបរូបថតនោះ នគរបាលរូបនោះ បានកញ្ឆក់យកទូរស័ព្ទពី ព្រុំ រដ្ឋា ហើយលុបវីដេអូ និងរូបថតទាំងអស់ រួចក៏បោះទូរស័ព្ទចោល។

ចាងហ្វាងអង្គភាពព័ត៌មាន LSN ឈ្មោះ លួស សេង បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តដើម្បីរកយុត្តិធម៌។១

### ៤. ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០២២៖ ខេត្តកំពត

លោក យួស សារឿន អ្នកយកព័ត៌មានជីវិត និងកីឡា ត្រូវបាននគរបាលខេត្តកំពត កោះហៅ បន្ទាប់ពីបានចុះផ្សាយអត្ថបទរិះគន់ស្នងការរងនគរបាលខេត្ត ដែលប្រើពាក្យសម្តីគ្រោតគ្រាតមិនសមរម្យជាមួយក្រុមគ្រួសារជនសង្ស័យ។

លោក យៀន ធន់ អធិការរងនគរបាលស្រុកទឹកឈូ បានចោទលោក យួស សារឿន ថាផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ជាសាធារណៈ។

ទោះយ៉ាងណាក្តី លោក យួស សារឿន ថាលោកផ្សាយព័ត៌មានត្រឹមត្រូវតាមវិជ្ជាជីវៈ។ លោកមិនបានបង្ហាញខ្លួននៅស្នងការដ្ឋាននគរបាលខេត្តទេ ហើយថា លិខិតកោះហៅគួរបញ្ជូនទៅអង្គភាពសារព័ត៌មាន គឺមិនមែនមកបុគ្គលនោះទេ។

## ៥. ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០២២៖ ខេត្តសៀមរាប

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី លោក ជា សុផារ៉ា បានហៅអ្នកយកព័ត៌មានស្រីពីរនាក់របស់VOD ក្នុងវេទិកាសាធារណៈដោយបញ្ជាឲ្យពួកគេឈរក្បែរលោកកុំដើរចេញទៅណាហើយឲ្យអង្គរក្សម្នាក់សរសេរឈ្មោះអ្នកយកព័ត៌មាន។

ក្នុងពេលជួបសំណេះសំណាលជាមួយអ្នកភូមិព្រះដាក់ក្នុងខេត្តសៀមរាបលោករដ្ឋមន្ត្រីបានចោទស្ថាប័នព័ត៌មានឯករាជ្យនេះថា រាយការណ៍ព័ត៌មានមិនត្រឹមត្រូវ ហើយបានបញ្ជាឲ្យអ្នកសារព័ត៌មានបរទេស និងខ្មែរឈរក្បែរលោក ដើម្បីកុំឲ្យស្រង់ សម្តីរបស់លោកខុស។

លោកក៏និយាយថា អ្នកកាសែតវ័យក្មេងបកប្រែមិនត្រឹមត្រូវ និងចូលចិត្តសរសេរកុហកដើម្បីទាក់ទាញអ្នកអានឲ្យបានច្រើន។

លោក សុផារ៉ា បាននិយាយថា "ឈរនៅត្រង់នេះរហូតដល់ការប្រជុំចប់ ហើយមិនត្រូវដើរទៅទីណាទេ"។ អ្នកយកព័ត៌មានម្នាក់ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ខាមបូចាថាការបញ្ជាឲ្យធ្វើបែបនេះធ្វើឱ្យនាងមានអារម្មណ៍ភ័យខ្លាច ហើយថានាងចាត់ទុកទង្វើរបស់ លោក សុផារ៉ា ថាជាការប៉ុនប៉ងគំរាមកំហែងនាង និងអ្នកសារព័ត៌មានផ្សេងទៀត។

## ៦. ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០២២៖ ខេត្តបាត់ដំបង

លោក សែន វីរៈ អ្នកយកព័ត៌មានរបស់ SBN Post News ប្រចាំខេត្តបាត់ដំបង ត្រូវបានតុលាការខេត្តកោះហៅកាលពីខែសីហា បន្ទាប់ពីអាជ្ញាធរមូលដ្ឋានចោទលោកថាញុះញង់តាមរយៈការ ផ្សាយផ្ទាល់ពីជម្លោះដីធ្លី។

លោកបានប្រាប់ខេមបូចា ថា លោកព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចោទប្រកាន់បែបនេះ។ លោកថាលោកបានយកព័ត៌មានប្រកបដោយវិជ្ជាជីវៈ និងតាមការអញ្ជើញរបស់អ្នកភូមិ ហើយគ្មានចេតនាញុះញង់ ឬដឹកនាំការបះបោរណាមួយឡើយ។១១

## ៧. ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២៖ ភ្នំពេញ

អាជ្ញាប័ណ្ណផ្សាយព័ត៌មាន សាន ប៊ុនធឿន Post News ត្រូវបានលុបចោលនៅថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២ ទាក់ទងនឹង "ទង្វើអសីលធម៌" ពេលផ្សាយផ្ទាល់តាមហ្វេសប៊ុក។ លោក សាន ប៊ុនធឿន ជាអ្នកផ្សាយតាមហ្វេសប៊ុក និងជាសមាជិកនៃអង្គភាពអង្គរក្សនាយករដ្ឋមន្ត្រី។

ការសម្រេចលុបអាជ្ញាប័ណ្ណរបស់លោក សាន្ត ប៊ុនធឿន បានធ្វើឡើងតែមួយថ្ងៃប៉ុណ្ណោះបន្ទាប់ពីលោក ហ៊ុន សែន ប្រតិកម្មទឹងការផ្សាយវីដេអូផ្ទាល់តាមហ្វេសប៊ុក ដែលគាត់ផឹកស៊ី បោកបាន និងជេរប្រមាថតាមទំព័របណ្ដាញសង្គម។ លោកនាយករដ្ឋមន្ត្រីបានថ្លែងថា "ចរិតអាក្រក់របស់សាន្ត ប៊ុនធឿនកែមិនឡើងទេ" ហើយក៏បានបញ្ជាឲ្យបណ្ដេញលោកប៊ុនធឿងចេញពីអង្គភាពអង្គរក្ស និងកងទ័ព។

## ៨.ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២៖ ខេត្តព្រះវិហារ

លោក ស៊ូ សេងហាក់ អាយុ៦០ឆ្នាំ ជាអ្នកយកព័ត៌មាន ឲ្យសារព័ត៌ម សារមរកត ប្រចាំខេត្តព្រះវិហារ ត្រូវរងការវាយធ្វើបាបពីមេបញ្ជាការម្នាក់កាលពីថ្ងៃទី២០ ខែសីហា បន្ទាប់ពីលោកបានឃើញផ្ទាល់ភ្នែកនូវអ្វីដែលលោកសង្ស័យថា ជាការដឹកជញ្ជូនឈើខុសច្បាប់។

លោក សេង ហាក់ សង្ស័យថាឈើនេះកាប់ដោយខុសច្បាប់ ហើយក៏ឃាត់រថយន្តដឹកឈើដើម្បីស៊ើបអង្កេត។ ទោះយ៉ាងណាក្តី លោកនិយាយថា មុនពេលឃាត់រថយន្ត ស្រាប់តែមេបញ្ជាការកងវរសេនាតូចបានចេញពីរថយន្ត ដើរសំដៅមកលោក ដែលកំពុងឈរជាមួយប្រពន្ធ ហើយបានវាយពួកគេទាំងពីរនាក់ បណ្តាលឱ្យសេងហាក់ឈាមច្រមុះ។

## ៩.ថ្ងៃទី១៦ សីហា ២០២២៖ តាកែវ

អ្នកសារព័ត៌មាន៥នាក់ មកពីអង្គភាពសារព័ត៌មានឯករាជ្យVOD ត្រូវបានឃុំខ្លួនប្រហែល ៧ម៉ោង នៅថ្ងៃទី១៦ ខែសីហា បន្ទាប់ពីចុះយកព័ត៌មានអំពីការឈូសដីព្រៃនៅក្នុងដែនជម្រកសត្វព្រៃ។ ការចាប់ខ្លួននេះកើតឡើងនៅវេលាម៉ោងប្រហែល១១ព្រឹកនៅសួនសត្វភ្នំតាម៉ៅបន្ទាប់ពីសមត្ថកិច្ចនិយាយថាអ្នកកាសែតទាំងនោះបានចូលទៅក្នុងតំបន់ហាមឃាត់។ ពួកគេត្រូវបាននាំទៅកាន់អធិការដ្ឋាននគរបាលស្រុកបាទី។

អ្នកសារព័ត៌មានទាំងនោះគឺ៖ ហ៊ី ឆាយ អាយុ៣៤ឆ្នាំ គាត សុខវិទ្ធសុជាវី អាយុ២៣ឆ្នាំ ដានយ៉ែល គីតុនអូលសិន (Danielle Keeton Olsen) អាយុ២៨ឆ្នាំ ម៉ម មុន្នីរតន៍ អាយុ៤០ឆ្នាំ និងហ៊ាន រង្សី អាយុ២៨ឆ្នាំ។

លោក ម៉ម មុនីរតន៍ អ្នកយកព័ត៌មានម្នាក់របស់ VOD ដែលត្រូវបានឃាត់ខ្លួន ហើយដោះលែងនោះ បាននិយាយថា សហការីរបស់គាត់ជាអ្នកយកព័ត៌មានវីដេអូ ត្រូវបានទះមួយកំផ្លៀង។

## ១០. ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០២២: ពោធិ៍សាត់

លោក ស៊ិន ក្វាន់ចា អ្នកយកព័ត៌មានរបស់សារព័ត៌មាន Penh Chet Media រងការគំរាមកំហែង ហើយរថយន្តរបស់គាត់ត្រូវបានជនអនាមិកបាញ់ដោយកាំភ្លើង បន្ទាប់ពីលោកបានចុះផ្សាយអត្ថបទស្តីពីការជល់មាន់ខុសច្បាប់។ ហេតុការណ៍នេះបានកើតឡើងកាលពីយប់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ នៅស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ ។

នៅក្នុងអត្ថបទនោះ មានការចោទថា លោក តាំង សារិទ្ធ អធិការនគរបាលស្រុក មិនអើពើនឹងល្បែងជល់មាន់ខុសច្បាប់ ហើយមិនហ៊ានបង្ក្រាប ដោយលើកឡើងថា ប្រហែលជាលោកជាប់ពាក់ព័ន្ធនឹងល្បែងជល់មាន់ខុសច្បាប់នេះ។

## ១១. ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០២២: ភ្នំពេញ

លោក ឃួន ណារីម អ្នកសារព័ត៌មាន CamboJA News បានទទួលប្រតិកម្មជាសាធារណៈពីអ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សុភ័ណ្ឌ ទៅនឹងអត្ថបទរបស់លោកដែលមានចំណងជើងថា "UN ថាសេរីភាពសារព័ត៌មាននៅកម្ពុជានៅតែរឹតត្បិតខ្លាំង"។

នៅក្នុងលិខិតចំហមួយផ្ញើជូន ខេមបូចា និងលោក ឃួន ណារីម លោក មាស សោភ័ណ្ឌ បានច្រានចោលកថាខណ្ឌ "អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បានច្រានចោលការរកឃើញរបស់ OHCHR ដោយនិយាយថា ការរកឃើញនោះបានមកពីការសម្ភាសជាមួយអ្នកកាសែតប្រឆាំងរដ្ឋាភិបាលប៉ុណ្ណោះ ហើយមិនបានឆ្លុះបញ្ចាំងពីការពិតទាំងមូលនៃប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសទេ"។ លោកបញ្ជាក់ថា លោកមិនបានបដិសេធការរកឃើញនោះទេ ហើយថាអ្នកកាសែតមិនបានដកស្រង់សម្តីរបស់លោកឲ្យបានត្រឹមត្រូវ។[16]

## ១២. ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២២៖ ក្រចេះ

អ្នកកាសែតក្នុងខេត្តក្រចេះម្នាក់ត្រូវក្រុមឈ្មួញរកស៊ីដឹកឈើឆ្លងដែនព្រួតវាយនៅស្រុកស្នួល ខេត្តក្រចេះ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២។

ជនរងគ្រោះឈ្មោះ សាន ស៊ីម (ហៅប៉ា) អាយុ៥២ឆ្នាំ ជាអ្នកយកព័ត៌មានរបស់អង្គភាពសារព័ត៌មានសម្រែកស្ត្រីខ្មែរ នៅស្រុកស្នួល បានប្រាប់ GN times ថា ខណៈលោក កំពុងអង្គុយហូបជំឡួងនៅផ្ទះអ្នកភូមិក៏ស្រាប់តែមានមនុស្ស៣នាក់ ប្រដាប់ដោយដំបងព្រួតវាយគាត់។ លោកបានស្គាល់អត្តសញ្ញាណជនដៃដល់ម្នាក់ឈ្មោះ ខ្យង ដែលលោកអះអាងថាជាឈ្មួញរកស៊ីដឹកជញ្ជូនឈើទៅប្រទេសវៀតណាម។ តាមជនរងគ្រោះការវាយប្រហារនេះគឺដើម្បីសងសឹកនឹងការងាររបស់គាត់ក្នុងការព្យាយាមថតរូបឈ្មួញដឹកឈើនិងរាយការណ៍អំពីការជួញដូរឈើខុសច្បាប់របស់ពួកគេ។

## ១៣. ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០២២: ខេត្តបាត់ដំបង

លោក សែម ឌីយ៉ា អាយុ២៣ឆ្នាំ ចាងហ្វាងព័ត៌មានបាត់ដំបងប៉ុស្តិ៍ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ បន្ទាប់ពីគាត់បានផ្សាយផ្ទាល់តាមហ្វេសប៊ុកពីការតវ៉ានៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ លោក ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទល្មើស។

ប្រពន្ធរបស់លោកសែមឌីយ៉ាបានប្រាប់វិទ្យុអាស៊ីសេរីថាការចាប់ខ្លួននេះជារឿងអយុត្តិធម៌ចំពោះប្តីរបស់គាត់ ព្រោះគាត់មិនបានប្រព្រឹត្តខុសឡើយ។ លោកស្រីបន្តថា ប្តីរបស់លោកស្រីត្រូវចាប់ខ្លួនបន្ទាប់ពីបានថត និងបង្ហោះវីដេអូតវ៉ារបស់កសិករដែលឲ្យទាមទារឲ្យអាជ្ញាធរកម្ពុជាបញ្ឈប់ការផាកពិន័យរថយន្តដឹកពោតរបស់ឈ្មួញថៃ។ កសិករព្រួយបារម្ភថាចំណាត់ការរបស់អាជ្ញាធរនឹងរាំងឈ្មួញថៃមិនឲ្យទិញពោតរបស់ខ្លួន។

លោក សែម ឌីយ៉ា ត្រូវបានដោះលែងនៅថ្ងៃទី ២១ ខែតុលាឆ្នាំ ២០២២ បន្ទាប់ពីជាប់ពន្ធនាគាររយៈពេល៣ខែ។ សាលាដំបូងខេត្តបាត់ដំបងបានកាត់ទោសគាត់ និងអ្នកតវ៉ាពីរនាក់ឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ប៉ុន្តែត្រូវព្យួរទោស។

### ១៤. ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២២: ភ្នំពេញ

លោក អ៊ួន ឈិន អ្នកយកព័ត៌មានរបស់ CamboJA ត្រូវបានបំភិតបំភ័យ និងគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាននៅក្នុងការតវ៉ាដោយសន្តិវិធីមួយរបស់អ្នកភូមិបឹងតាមោក នៅមុខខុទ្ទកាល័យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

មន្ត្រីមូលដ្ឋានម្នាក់បានចង្អុលមុខគាត់ ហើយស្រែកថា "មកពីណា"។ គាត់ឆ្លើយថា "ខ្ញុំមកពី ខេមបូចា "។ មន្ត្រីនោះស្រែកថា "យកកាតកាសែតចេញមក" ។ លោក អ៊ុន ជិន អ៊ួន ឈិន ក៏ដើរចេញពីមន្ត្រីនោះ ព្រោះគាត់ខ្លាចគេរឹបអូសកាមេរ៉ារបស់គាត់ ហើយគាត់បានឮគេនិយាយតាមវិទ្យុទាក់ទងថា "នាំមក នាំគាត់មក" ។

អ្នកយកព័ត៌មានរូបនេះចាត់ទុកករណីនេះថាជាការគំរាមកំហែងដល់រូបលោក និងអ្នកសារព័ត៌មានដទៃទៀត ហើយជាការរឹតត្បិតសេរីភាពសារព័ត៌មាន។

### ១៥. ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២២: ភ្នំពេញ

កាលពីថ្ងៃទី២៧ ខែមិថុនា អាជ្ញាធរបានបណ្ដេញអ្នកសារព័ត៌មាន និងអ្នកសង្កេតការណ៍សិទ្ធិមនុស្សចេញពីកន្លែងតវ៉ានៅមុខកាស៊ីណូណាហ្គាវើលដ៍ ដោយសន្តិសុខខណ្ឌបានគំរាមពួកគេ ហើយក៏ទាមទារឱ្យអ្នកសារព័ត៌មាន VOD (សុំមិនបញ្ចេញឈ្មោះ) លុបរូបថត និងវីដេអូពីសកម្មភាពរបស់អាជ្ញាធរនៅតាមទីសាធារណៈ។

ឆ្លើយតបនឹងចំណាត់ការបែបនេះ ក្រសួងព័ត៌មានបាននិយាយថា អាជ្ញាធរថ្នាក់ក្រោមហាក់មិនទាន់យល់ច្បាស់ពីតួនាទីរបស់ពួកគេ និងអនុវត្តហួសគោលការណ៍។ លោក ផុស សុវណ្ណ អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាននៃក្រសួងព័ត៌មានបាននិយាយថា៖«ខ្ញុំនឹងពិភាក្សាពីបញ្ហានេះហើយប្រហែលជាអាជ្ញាធរថ្នាក់ក្រោមមិនយល់ពីបញ្ហានេះទេ។

### ១៦. ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២២៖ ខេត្តមណ្ឌលគិរី

លោក ប៊ុន រិទ្ធ អាយុ ៤៧ ឆ្នាំ ចាងហ្វាងអង្គភាពសារព័ត៌មានរិទ្ធីដាវដែក (Rithy Dav Dek News) ត្រូវបាននគរបាលខេត្តមណ្ឌលគិរី កោះហៅដោយចោទប្រកាន់ពីបទបរិហារកេរ្តិ៍អាជ្ញាធរមូលដ្ឋានតាមបណ្ដាញសង្គម។

ការកោះហៅនេះធ្វើឡើង បន្ទាប់ពីលោកបានចុះផ្សាយព័ត៌មានគ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ដោយចោទថាអាជ្ញាធរមូលដ្ឋានមានចេតនាមិនអើពើនឹងករណីគ្រោះថ្នាក់ចរាចរណ៍នេះ បន្ទាប់ពីបានទទួលសំណូក។ប៊ុន រិទ្ធ បានទទួលស្គាល់កំហុសរបស់ខ្លួន ហើយបានកែអត្ថបទបន្ទាប់ពីបានជួបជាមួយអាជ្ញាធរមូលដ្ឋាន។

### ១៧. ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០២២: ខេត្តព្រះវិហារ

អ្នកកាសែតប្រចាំខេត្តព្រះវិហារម្នាក់និយាយថាគាត់កំពុងប្រឈមនឹងការចាប់ខ្លួនបន្ទាប់ពីថតគ្រឿងចក្រឈូសឆាយដីរដ្ឋ។ សាលាដំបូងខេត្តបាននិយាយថា ដីកាត្រូវបានចេញបន្ទាប់ពីអ្នកកាសែតនោះមិនបានចូលខ្លួនដើម្បីសាកសួរចំនួន ៤ ដង។

លោក ទ្រី សុផល អ្នកសារព័ត៌មាននៃសារព័ត៌មានអនឡាញ «Everyday» និយាយថា ករណីនេះកើតឡើងតាំងពីចុងឆ្នាំ២០២១ នៅពេលដែលលោករាយការណ៍អំពីករណីឈូសឆាយដីរដ្ឋនៅឃុំស្រយ៉ង់ ស្រុកគូលែន។

លោកបន្តថាបន្ទាប់មកលោកនិងអ្នកកាសែតផ្សេងទៀតបានទទួលពាក្យបណ្ដឹងពីបទលួចនិងគំរាមកំហែង។ លោកសុផល និយាយថា "ប៉ុន្តែខ្ញុំ [គ្រាន់តែ] បានឃើញបទល្មើស ហើយខ្ញុំក៏បានថត និងរាយការណ៍ព័ត៌មានប៉ុណ្ណោះ។ ហេតុអ្វីបានជាគេចោទខ្ញុំបែបនេះ?»។

សុផលបាននិយាយថាគាត់ក៏ត្រូវបានគេវាយដំដែរនៅពេលនោះប៉ុន្តែតុលាការខេត្តបែរជាដោះលែងអ្នកវាយនោះទៅវិញ។ លោកក៏បានប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយអំពីតុលាការដែរ។

## ១៨. ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០២២: ភ្នំពេញ

ក្នុងអំឡុងពេលបោះឆ្នោតឃុំសង្កាត់ លោក ស៊ន សា រ៉ាត អ្នកយកព័ត៌មានរបស់ ខេមបូចា ដែលយកព័ត៌មានអំពីការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនៅសាលាបឋមសិក្សាវាលស្បូវក្នុងរាជធានីភ្នំពេញ ត្រូវបានហៅសួរដោយមន្ត្រីនគរបាលដែលមានតួនាទីជាសន្តិសុខ និងជាប្រធានការិយាល័យបោះឆ្នោត។ គាត់មិនត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងកន្លែងបោះឆ្នោតដើម្បីថតរូបនៅពេលគេរាប់សន្លឹកឆ្នោតទេ។

សារ៉ាត បាននិយាយថា៖ «ខ្ញុំត្រូវបានប៉ូលិស និងប្រធានការិយាល័យបោះឆ្នោតសួរនាំ ពេលចុះយកព័ត៌មាននៅវាលស្បូវ ហើយមិនអនុញ្ញាតឲ្យចូលទៅជិត ដើម្បីថតរូបពេលគេរាប់សន្លឹកឆ្នោតទេ»។

## ១៩ ថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០២២: ភ្នំពេញ

អ្នកសារព័ត៌មានពីររូបមកពីVOD គឺលោក សេង ថៃ និងលោក ហ៊ី ឆៃ ត្រូវបានអាជ្ញាធរសួរនាំ ហើយបានថតកាតកាសែតពួកគេ ខណៈពួកគេកំពុងសម្ភាសបេក្ខជនពីរនាក់នៅសង្កាត់ទឹកល្អក់១ រាជធានីភ្នំពេញ អំពីសកម្មភាពឃោសនារបស់គណបក្សប្រជាជនកម្ពុជា និងផែនការបម្រើសេវានៅមូលដ្ឋានរបស់គេ។

នៅថ្ងៃបោះឆ្នោត ពេលទៅសម្ភាសមនុស្ស៥នាក់នៅការិយាល័យបោះឆ្នោតនៅវត្តចាក់អង្រែលើ មានបុរសស្លៀកពាក់ស៊ីវិលបានសួរពួកគេថា៖ «តើអ្នកកំពុងសម្ភាសរឿងអ្វី? តើអ្នកនឹងចុះផ្សាយនៅលើប៉ុស្តិ៍ណា ហើយនៅពេលណា? ហើយតើអ្នកសួរពលរដ្ឋបោះថាឆ្នោតឲ្យនរណាឬ?

លោក ថៃ បាននិយាយថា លោកយល់ថា សំណួរនេះជា"ការគំរាមកំហែងដល់សេរីភាពសារព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត" ដោយកត់សម្គាល់ថា ប្រសិនបើពួកគេសួរពលរដ្ឋថាពួកគេបោះឆ្នោតឱ្យនរណានោះ ពួកគេអាចត្រូវចាប់ខ្លួន ឬផ្តន្ទាទោសដូចអ្នកកាសែត Cambodia Daily ដែលត្រូវបានចោទប្រកាន់ពីបទរាយការណ៍ព័ត៌មានពីការបោះឆ្នោតនៅក្នុង ឆ្នាំ ២០១៣ដែរ ។

## ២០. ថ្ងៃទី ២៦ ឧសភា ២០២២: ខេត្តកណ្ដាល

លោក ថៃ ប៊ុនរិទ្ធ អាយុ ៥១ ឆ្នាំ ជាផលិតករទូរទស្សន៍ TCN ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ២៦ ឧសភា តាមបណ្តឹងរបស់ នគរបាល ខេត្តកណ្តាល។ លោកបានផ្សាយព័ត៌មានដែលអះអាងថា អាជ្ញាធរខេត្តកណ្តាលបានទទួលសំណូកពីម្ចាស់បនល្បែងស៊ីសងខុសច្បាប់ ជាថ្នូរនឹងការមិនបង្ក្រាប។ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល លោក អាត់ ចាន់តារា និយាយថា លោក ប៊ុន រិទ្ធ ត្រូវបានចោទប្រកាន់ពីបទ «ញុះញង់ឲ្យមានការរើសអើង និងបរិហារកេរ្តិ៍ជាសាធារណៈ» តាមមាត្រា ៤៩៤, ៤៩៦, និង ៣០៥ នៃក្រមព្រហ្មទណ្ឌ។

មន្ត្រីនគរបាលខេត្តកណ្តាល លោក លាង សាម៉េត និយាយថា ការចុះផ្សាយរបស់លោក ប៊ុនរិទ្ធ បានចោទមន្ត្រីនគរបាល និងកងរាជអាវុធហត្ថ ថាបានឃុបឃិតកាងល្បែងស៊ីសងខុសច្បាប់ ការចាក់ឆ្នោត និងជល់មាន់នៅក្នុងខេត្តកណ្តាល។

## ២១. ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២២៖ ក្រុងព្រះសីហនុ

លោក ម៉ិច ដារ៉ា អ្នកយកព័ត៌មាន VOD ត្រូវបានអគ្គនាយកដ្ឋានអន្តោប្រវេសន៍ខេត្តព្រះសីហនុឃាត់ខ្លួនរយៈពេលប្រហែលពីរម៉ោង បន្ទាប់ពីបដិសេធមិនលុបរូបភាពដែលគាត់ថតអគារដែលត្រូវបានគេចោទថាជាកន្លែងប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ។ ទូរស័ព្ទ កាតកាសែត កាតអង្គភាពសារព័ត៌មាន ប័ណ្ណសន្តិសុខសង្គម និងម៉ូតូរបស់គាត់ត្រូវបានរឹបអូសជាបណ្តោះអាសន្ន។

លោក ដារ៉ា បាននិយាយថា៖ «គាត់ [មន្ត្រីប៉ូលិសអន្តោប្រវេសន៍] បាន [គំរាមដាក់] ខ្នោះដៃខ្ញុំ»។ «ប្រសិនបើមានច្បាប់ថតរូបជាសាធារណៈ ហើយខ្ញុំត្រូវសុំការអនុញ្ញាតបែបនេះ អ៊ីចឹងខ្ញុំឈប់ធ្វើកាសែត ធ្វើជាកសិករវិញ»។

## ២២. ថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០២២៖ ខេត្តកំពង់ឆ្នាំង

សាយ រស្មី អាយុ៣១ឆ្នាំ ទូន ឈុនលី អាយុ៥១ឆ្នាំ អ្នកយកព័ត៌មាននៅរស្មីស្ទឹងត្រែង និងអ្នកសារព័ត៌មានម្នាក់ទៀតមកពី រស្មីបន្ទាយដែក អាយុ ៤៣ឆ្នាំ ត្រូវបានអាជ្ញាធរមូលដ្ឋានខេត្តកំពង់ឆ្នាំង ឃាត់ខ្លួន ដោយរង ការចោទថាបានរំលោភសិទ្ធិឯកជន។

អ្នក សារព័ត៌មាន ទាំងបីនាក់បានទៅយកព័ត៌មាននៅហាងលក់ម៉ូតូមួយកន្លែងដែលគេសង្ស័យថាខុសច្បាប់ បន្ទាប់ពីមានការរាយ ការណ៍ពីពលរដ្ឋមួយចំនួនដែលរស់នៅជុំវិញទីនោះ (ក្រុងកំពង់ឆ្នាំង)។ ពេលចុះទៅដល់ទីនោះភ្លាម ពួកគេក៏ចាប់ផ្តើមថតរូបនៅមុខហាង ស្រាប់តែម្ចាស់ហាងឃើញ ក៏ទូរស័ព្ទទៅសមត្ថកិច្ចឱ្យចាប់ខ្លួនពួកគេ ។

នគរបាល បានឃាត់ខ្លួនពួកគេប្រហែលពីរម៉ោង ហើយដោះលែងពួកគេវិញនៅថ្ងៃដដែល ដោយនគរបាលអះអាងថា ហាងលក់ម៉ូតូមានច្បាប់ត្រឹមត្រូវ។

## ២៣. ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០២២: ខេត្តកណ្ដាល

លោក សួន វុត្ថា អ្នកសារព័ត៌មាន ពលរដ្ឋបាននិយាយថា លោកបានធ្វើដំណើរពីខេត្តកំពតទៅភ្នំពេញកាលពីថ្ងៃទី១០ ខែមេសា។ ពេលមកដល់កន្លែងប៉ុស្តិ៍ត្រួតពិនិត្យ មួយនៅស្រុកលើកដែក ខេត្តកណ្ដាល លោកក៏បានឃើញរថយន្តតាក់ស៊ីដឹកអ្នកដំណើរលើសចំណុះ ប៉ុន្តែនគរបាល ចរាចរណ៍យកលុយហើយ ធ្វើមិនដឹងមិនឮ។

នគរបាល ចរាចរណ៍បានតំរាមលោក សួន វុត្ថា ដោសារលោកថតពួកគេយកលុយពីអ្នកបើកតាក់ស៊ី ហើយពួកគេក៏បានបញ្ជាឲ្យលោកលុបរូបថត និងវីដេអូចេញ។

គាត់ត្រូវបាននគរបាលនាំខ្លួនទៅសាកសួរអស់រយៈពេលជាង់មួយម៉ោង។ មន្ត្រីនគរបាលបានទាររកលិខិតបេសកកម្មរបស់គាត់ក៏ដូចជាបណ្ណសំគាល់ខ្លួនហើយពួកគេក៏បានបញ្ជាឱ្យគាត់លុបវីដេអូហើយចុះហត្ថលេខាលើកិច្ចសន្យាឈប់ថតរូប។

## ២៤. ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២២៖ ភ្នំពេញ

លោក មាស សូរ៉ា អ្នកយកព័ត៌មានគេហទំព័រព័ត៌មាន Measora រងការគំរាមប្រើហិង្សា ពេលដែលលោកបានផ្សាយអំពីការដល់មាន់ខុសច្បាប់នៅសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ។

ម្ចាស់កន្លែងជល់មាន់ត្រូវបានគេចោទថាវាយបំបែកកញ្ចក់រថយន្តរបស់លោក មាស សូរ៉ា ហើយព្យាយាមកញ្ឆក់យកទូរស័ព្ទពី លោក មាស សូរ៉ាកុំឲ្យគាត់ថតរូបនៅកន្លែងជល់មាន់ខុសច្បាប់។

## ២៥. ថ្ងៃទី ២២ មីនា ២០២២៖ ខេត្តបាត់ដំបង

លោក លឹម ផល្លី អាយុ ២៣ ឆ្នាំ អ្នកយកព័ត៌មានសារព័ត៌មានអនឡាញ លួស សេង ត្រូវបានចោទប្រកាន់និងបញ្ជូនទៅកាន់តុលាការ បន្ទាប់ពីលោកធ្វើការផ្សាយផ្ទាល់តាមហ្វេសប៊ុក កាលពីថ្ងៃទី ១៦ ខែមករា ករណីចោទរោងសិប្បកម្មអារឈើមួយកន្លែងនៅបាត់ដំបងថាបានកែច្នៃឈើប្រណីតខុសច្បាប់។

លោកផល្លីនិយាយថា គាត់បានឃើញគេដឹកឈើចូលនិងចេញពីខេត្តបាត់ដំបងយ៉ាងសកម្មជារៀងរាល់ថ្ងៃ។ លោកបន្តថា៖ «ពេលអ្នកយកព័ត៌មានរបស់យើងចុះទៅយកព័ត៌មាន គាត់បានប្ដឹងយើង ដោយចោទយើងពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មាន [មិនពិត] ទោះបីខ្ញុំមានឯកសារ វីដេអូ និងរូបថតគាត់ដឹកឈើក៏ដោយ»។

នាយរដ្ឋបាលព្រៃឈើខេត្តបាត់ដំបង លោក ឈឹម វេងិរ៉ា បាននិយាយថា សិប្បកម្មអារឈើមានអាជ្ញាប័ណ្ណត្រឹមត្រូវ ហើយថាឈើទាំងអស់ដែលដឹកចូលរោងសិប្បកម្មមានលិខិតអនុញ្ញាតត្រឹមត្រូវ។

លោក វេងិរ៉ា បន្តថា៖ «បើគ្មានច្បាប់ទេ គេមិនអាចដំណើរការបានទេ។ ដូច្នេះតាមគំនិតខ្ញុំ បើវាមិនស្របច្បាប់ គឺមិនអាចបើកនៅកណ្ដាលក្រុងបានទេ»។

### ២៦. ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២២៖ ភ្នំពេញ

អង្គភាពសារព័ត៌មានចំនួនបីត្រូវបានដកអាជ្ញាប័ណ្ណ។ អង្គភាព BayongTimes, Khmercovertv (KCTV) និង Cambodia Today ត្រូវបានបិទ បន្ទាប់ពីក្រសួងព័ត៌មានបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយថា អង្គភាពសារព័ត៌មានទាំងនោះបាន "ធ្វើការផ្សព្វផ្សាយព័ត៌មានដែលបំពានលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន និងកិច្ចសន្យាអាជីវកម្ម"។

កាលពីដើមខែកុម្ភៈ Cambodia Today បានចុះផ្សាយរឿងស៊ើបអង្កេតមួយទាក់ទងនឹងអំពើពុករលួយនៅក្នុងក្រសួងការងារ ដែលអ្នកយកព័ត៌មានសង្ស័យថាជាហេតុផលនៅពីក្រោយការលុបអាជ្ញាបណ្ណ។

អ្នកយកព័ត៌មានរូបនេះនិយាយថា«ខ្ញុំបានចុះផ្សាយអត្ថបទមួយអំពីដំណើរការដេញថ្លៃពុករលួយនៅក្រសួងការងារ ដែលធ្វើឲ្យខ្ជះខ្ជាយថវិកាជាតិរាប់លានដុល្លារ។ បន្ទាប់មកមន្ត្រីក្រសួងព័ត៌មានបានសុំឲ្យខ្ញុំដកអត្ថបទនេះចេញវិញ ប៉ុន្តែខ្ញុំមិនព្រម»។

### ២៧. ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២២: ភ្នំពេញ

កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២និង៣០នាទីរសៀល អ្នកសារព័ត៌មាន VOD ២នាក់ និងអ្នកសារព័ត៌មានពលរដ្ឋម្នាក់ត្រូវបានអាជ្ញាធររាជធានីភ្នំពេញរំខានយាយីខណៈពួកគេកំពុងចុះយកព័ត៌មានកូដកម្មបុគ្គលិកកាស៊ីណូណាហ្គាវើលដ៍។

ស្ត្រីអ្នកសារព័ត៌មាន VOD ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ ខេមបូចា ថា “អាជ្ញាធរហាមខ្ញុំ និងអតីតមិត្តរួមការងារមិនឲ្យថតរូប សួររកលិខិតបេសកកម្ម ហើយបង្ខំយើងឲ្យលុបរូបភាព និងវីដេអូ បើមិនដូច្នេះទេ អាជ្ញាធរនឹងនាំពួកយើង ទៅប៉ុស្តិ៍ប៉ូលិស»។

### ២៨. ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០២២៖ ខេត្តឧត្តរមានជ័យ

លោក ឈឿន ប៊ុនឈី អាយុ ៥២ឆ្នាំ អ្នកយកព័ត៌មានកម្ពុជា ដេលី ត្រូវបានតុលាការខេត្តឧត្តរមានជ័យ ចេញដីកាកោះហៅ ពីបទផ្សាយព័ត៌មានមិនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១។

ការកោះហៅនេះធ្វើឡើងបន្ទាប់ពីលោកបានចុះផ្សាយព័ត៌មានអំពីជម្លោះដីធ្លីរវាងពលរដ្ឋនិងរដ្ឋបាលព្រៃឈើស្រុក។ក្នុងសវនាការកាលពីថ្ងៃទី៣១ខែមករាសាលាដំបូងខេត្តឧត្តរមានជ័យបានបង្គាប់ឲ្យលោកឈឿនប៊ុនឈីបង់ប្រាក់ចំនួន៤លានរៀល ឬប្រហែល១ពាន់ដុល្លារអាមេរិក ទៅដើមបណ្តឹង។ ប៊ុនឈី បានប្តឹងឧទ្ធរណ៍។

### ២៩. ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២២៖ ភ្នំពេញ

ឆាយា នាថ និពន្ធនាយកសារព័ត៌មាន CPC News បានទទួលការហៅទូរស័ព្ទពីមន្ត្រីនគរបាលម្នាក់ឈ្មោះ ម៉ន សុជាតិ ដែលបានតវ៉ាពីអត្ថបទព័ត៌មានទាក់ទងនឹងអំពើហិង្សាដែលប្រព្រឹត្តដោយមន្ត្រីនគរបាលរូបនេះ។ លោក ម៉ន សុជាតិ បាននិយាយថា អត្ថបទរបស់ CPC News គឺលំអៀង និងមិនពិត។ មន្ត្រីនគរបាលរូបនេះបានសុំឱ្យ CPC News ឈប់ចុះផ្សាយករណីរបស់គាត់ បើមិនដូច្នេះទេឆាយា នាថ នឹងត្រូវបានប្តឹង ប៉ុន្តែ ឆាយា នាថមិនព្រម ហើយបាននិយាយថា ការហៅទូរស័ព្ទ និងការតវ៉ានេះ គឺជាការគំរាមកំហែងដល់វិជ្ជាជីវៈអ្នកសារព័ត៌មានរបស់គាត់។

### ៣០. ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០២២: ភ្នំពេញ

*អ្នកសារព័ត៌មានបរទេសម្នាក់របស់ VOD ត្រូវបានគេបំភិតបំភ័យ និងគំរាមចាប់ខ្លួន ខណៈដែលគាត់កំពុងរាយការណ៍ព័ត៌មានកូដកម្មបុគ្គលិកកាស៊ីណូណាហ្គាវើលដ៍នៅក្នុងរាជធានីភ្នំពេញ។*

*នៅរសៀលថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ អ្នកសារព័ត៌មានរូបនេះកំពុងថតរូប និងថតវីដេអូសកម្មភាពអាជ្ញាធរ និងក្រុមកូដករកាស៊ីណូណាហ្គាវើលដ៍ នៅទីសាធារណៈក្នុងរាជធានី។*

*មន្ត្រីពាក់ឯកសណ្ឋានទាមទារមើលឯកសារដើមរបស់គាត់ និងបានគំរាមចាប់ខ្លួនគាត់ ប្រសិនបើគាត់នៅតែថតរូប និងថតវីដេអូ ហើយមិនព្រមចាកចេញពីទីនោះ ដោយបង្ខំគាត់ឱ្យឈប់ថតរូប ហើយត្រូវចាកចេញជាបន្ទាន់។35*

### ៣១. ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២២៖ ខេត្តកំពត

*លួស សេង ចាងហ្វាងព័ត៌មានលួស សេង ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការរយៈពេលប្រាំមួយខែ ដោយសារផ្សាយវីដេអូផ្ទាល់ដោយបុគ្គលិកពីរនាក់របស់លោកនៅខេត្តកំពត។*

*អ្នកយកព័ត៌មានទាំងពីររូបត្រូវបានចាប់ខ្លួនពីបទ ផ្សាយផ្ទាល់ការតវ៉ានៅខាងក្រៅសាលាខេត្តកំពត ប្រឆាំងនឹងការចាប់ខ្លួនប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ ក៏ធ្លាប់បាននិយាយកាលពីខែវិច្ឆិកា ប្រឆាំងនឹងការចាប់ខ្លួននេះថា "បើ [អ្នកកាសែត] ថតរូបនៅមុខសាលាខេត្ត ម៉េចមិនឲ្យពួកគេថតរូប?"។*

*លោកបាននិយាយបន្ថែមថា«ការចាប់ពួកគេគឺខុស តាមអំពើចិត្តហើយ។ ដូច្នេះ អាជ្ញាធរបំពានហើយ»។*

### ៣២. ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២២៖ ភ្នំពេញ

*អ្នកសារព័ត៌មានពីរនាក់របស់* Cambodia Express News (CEN) *បាននិយាយថា ពួកគេបានទទួលការគំរាមសម្លាប់ពីម្ចាស់ឆ្កែម្នាក់បន្ទាប់ពីពួកគេបានផ្សាយផ្ទាល់ពីជម្លោះរវាងម្ចាស់ឆ្កែនិងជនរងគ្រោះដែលឆ្កែគាត់ខាំ។*

*អ្នកយកព័ត៌មាន*CEN *ភ័យខ្លាចចំពោះការគំរាមកំហែងនេះ ហើយបានថតសំឡេងរបស់ម្ចាស់ឆ្កែ ដើម្បីទុកជាភស្តុតាង ក្នុងករណីមានរឿងអ្វីមួយកើតឡើងចំពោះគាត់នាពេលអនាគត។៣៧*

### ៣៣. ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០២២: ខេត្តបាត់ដំបង

*លោក សុខ សារ៉ាន់ អាយុ ៥០ឆ្នាំ ជាអ្នកយកព័ត៌មាន «កម្ពុជារាល់ថ្ងៃ» ប្រចាំខេត្តបាត់ដំបង ត្រូវបានតុលាការខេត្តបាត់ដំបង ឃុំខ្លួនកាលពីថ្ងៃទី៩ ខែមករា ឆ្នាំ២០២២ ដោយចោទពីបទញុះញង់ពលរដ្ឋឱ្យតវ៉ាប្រឆាំងនឹងអាជ្ញាធរមូលដ្ឋាននៅតំបន់ព្រៃលិចទឹក។ គាត់ត្រូវបានដោះលែងនៅថ្ងៃទី ៩ ខែកក្កដាឆ្នាំ២០២២ បន្ទាប់ពីតុលាការខេត្តបានរកឃើញថាគាត់មិនបានប្រព្រឹត្តបទល្មើស។៣៨*

### ៣៨. ថ្ងៃទី៦ ខែមករា ឆ្នាំ២០២២

អ្នកសារព័ត៌មានអនឡាញ ៥នាក់ ត្រូវបាននគរបាលខេត្តកំពង់ឆ្នាំង ចាប់ខ្លួនកាលពីថ្ងៃទី៦ និងថ្ងៃទី៧ ខែមករា ឆ្នាំ២០២២ ពីបទញុះញង់ឲ្យអ្នកភូមិតវ៉ាប្រឆាំងនឹងអាជ្ញាធរ។

អ្នកសារព័ត៌មាន ទាំង៥នាក់នោះរួមមាន កែវ ហួរ នៃអង្គភាព SBT news ប្រាក់ សុងហា, ឆន គង់តារា, សាង ចាន់ថន និងលោក អ៊ុក ប៉ាវ៉ាឌី នៃអង្គភាព MCTV។ អ្នកទាំង៥នាក់ត្រូវតុលាការចោទពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។

លោក ស្រី ចាន់ គន្ធី អាយុ ៥១ ឆ្នាំ ជាភរិយារបស់លោក សាង ចាន់ថន បាននិយាយថា ការចាប់ខ្លួននេះធ្វើឡើងបន្ទាប់ពីប្តីរបស់គាត់ និងសហការីបានចុះយកព័ត៌មានពីទំនាស់ដីធ្លីនៅស្រុកកំពង់លែង។ ពួកគេត្រូវបានដោះលែងនៅថ្ងៃទី ២៧ ខែកក្កដាឆ្នាំ ២០២២ ។

### ៣៩. ថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ភ្នំពេញ

VOD, EAC, និង GN time មិនត្រូវបានអនុញ្ញាតឱ្យចូលរួមសន្និសីទកាសែតស្តីពីការចាប់ខ្លួនបុគ្គលិកណាហ្គាវើលដ៍នៅព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ដែលធ្វើឡើងដោយអាជ្ញាធររាជធានីភ្នំពេញនោះទេ។

ប្រធានមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ លោក អ៊ិត សុធឿត និយាយថា ការហាមប្រាមអ្នកសារព័ត៌មានមិនឲ្យចូលយកព័ត៌មាននៅសន្និសីទកាសែតក្រោមលេសមិនបានចុះឈ្មោះ គឺជាការរឹតត្បិតសេរីភាពសារព័ត៌មាន។

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association


## ទំនាក់ទំនង

+(៨៥៥) ២៣ ៨៨ ២៣ ១១

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ